# វិធីថ្វាយបង្គំព្រះ

## បាលី - ប្រែ

ផ្សាយចេញពី

## ក្រសួងព្រះសង្ឃរាជ

## គណៈធម្មយុត្តិកនិកាយ

នៃ

ព្រះរាជាណាចក្រកម្ពុជា

ព.ស. ២៥៥៨ គ.ស. ២០១៥

Printed for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
Mobile Web: m.budaedu.org
**This book is strictly for free distribution, it is not to be sold.**
**សំរាប់ជាធម្មទានតែប៉ុណ្ណោះ**

# បុព្វកថា

មុននឹងអោយទេវតាជួយអ្នក ត្រូវអ្នកជួយខ្លួនអ្នកជាមុនសិន (ពាក្យអ្នកបស្ចិមប្រទេស)

ព្រះធម៌នៃព្រះសម្មាសម្ពុទ្ធ ប្រាកដជាទ្រទ្រង់នូវមនុស្សលោក ។ ប៉ុន្តែ មុននឹងអោយព្រះធម៌នៃព្រះពុទ្ធអង្គជួយអ្នក ត្រូវអ្នកសិក្សារៀនសូត្រព្រះធម៌វិន័យ ជាពិសេសគឺការគោរពប្រតិបត្តិតាមព្រះឱវាទជាមុនសិន ។

អាស្រ័យដូចនេះហើយបានជា ទូលព្រះបង្គំ ខ្ញុំព្រះករុណា អាត្មាភាព បានដកស្រង់រៀបចំ បោះពុម្ពសៀវភៅថ្វាយបង្គំព្រះជាថ្មីឡើងវិញ ដើម្បីចែកជាធម្មទាន ។

សៀវភៅដែលព្រះករុណា អស់លោកអ្នកកំពុងអាននេះ ខ្ញុំបានបញ្ចូលធម៌ខ្លះបន្ថែមពីគណៈកម្មការរៀបចំមុន ដូចជារបៀបធ្វើវិសាខ និងមាឃបូជា **យំភិញ្ញា ភឹសុ** សរសើរព្រះរតនត្រៃសង្ខេប ព្រះរាជជីវប្រវត្តិសម្តេចប៉ាន និងបុរាណភាសិត ពុទ្ធភាសិត ។

តាំងតែពី ព.ស ២៥៣៤ គ.ស ១៩៩១ ដែលប្រទេសជាតិផ្តល់អោយមាន និកាយធម្មយុត្ត សម្តេចព្រះសង្ឃរាជ **ប៊ួរ គ្រី** បានព្រះរាជានុញ្ញាតអោយបោះពុម្ពចម្លងតាមច្បាប់ដើម និងបញ្ចូលបន្ថែមខ្លះ ៗ តម្រូវទៅតាមការខ្វះខាត ចំនួនបីលើក លើកទីមួយ ចំនួន ៥០០ ច្បាប់ លើកទីពីរ ចំនួន ៥០០ ច្បាប់ និងលើកទីបីនេះចំនួន ៥ ០០០ ច្បាប់ ។

ក្នុងគោលបំណង:

-សូមអោយព្រះពុទ្ធសាសនាប្រតិស្ឋានគ្រប់ ៥០០០ ព្រះវស្សា ។

-សូមអោយពុទ្ធមាមកជន បានជ្រាបច្បាស់នូវព្រះឱវាទ ដ៏បរិសុទ្ធនៃព្រះបរមសម្មាសម្ពុទ្ធជាអម្ចាស់ ។

-សូមអោយអ្នកដឹកនាំខ្មែរ នៃពុទ្ធចក្រ និងអាណាចក្រ ប្រកបដោយទសពិធរាជធម៌ជាអមតៈ ដើម្បីអោយទឹកដីសុវណ្ណភូមិ (កម្ពុជា) បានស្ថិតស្ថេរ និងប្រជារាស្ត្រមានរស្មីសន្តិភាព ។

-ព្រះពុទ្ធសាសនាមានស្ថេរភាពរុងរឿងអាស្រ័យដោយជនបុត្តម្ពព្រះពុទ្ធ-សាសនាបានជ្រាបច្បាស់ ព្រមទាំងបដិបត្តិជាសច្ចធម៌ តាមពាក្យប្រៀនប្រដៅនៃព្រះបរមពុទ្ធោវាទ ។

-ព្រះរាជាណាចក្រកម្ពុជា មានវឌ្ឍនភាពរុងរឿងជឿនលឿនទៅមុខបានអាស្រ័យដោយពលរដ្ឋព្រមទាំងមន្ត្រីតូចធំ និងប្រជារាស្ត្រមានសមត្ថភាពគឺការយល់ដឹងទាំងផ្លូវពុទ្ធចក្រ និងអាណាចក្រ ហើយត្រូវមានសច្ចយុត្តិធម៌ ។

**ឯតេន បុញ្ញតេជេន វុឌ្ឍី បប្បោន្តុ សព្វទា**

ដោយតេជៈ នៃបុណ្យនេះសូមពុទ្ធសាសនូបត្ថម្ភក៍ទាំងឡាយ បាននូវសុភមង្គលគ្រប់ប្រការ ។

ភ្នំពេញ ថ្ងៃទី ៨ ៗ ៣ ឆ្នាំ ចរស័ក ព.ស. ២៥៣៨

ថ្ងៃទី ១ កុម្ភៈ ឆ្នាំ ១៩៩៥

ចាត់ការ

ព្រះធម្មត្រ័យលោកាចារ្យ

**ពុត សុភក្ត្រ៏ គិរិបុត្តោ**

# ព្រះថេរដីកា

សៀវភៅវិធីថ្វាយបង្គំព្រះបាលី-ប្រែនេះ កើតឡើងដោយគណៈកម្មការសង្ឃ សុទ្ធតែជារាជាគណៈ និងឋានានុក្រម ក្នុងព្រះរាជធានីភ្នំពេញ ។ ខ្ញុំបានចាត់តាំងគណៈកម្មការនេះ ដោយមានយោបល់ស្របនឹងព្រះថេរានុត្ថេរៈ ទាំងឡាយ ដែលបានសន្និបាតក្រោមអធិបតីភាពនៃខ្ញុំ ដូចតទៅនេះ ៖

១- សៀវភៅធម៌ប្រែកើតឡើងច្រើន ។ ឯសៀវភៅទាំងនោះមានសេចក្ដីប្រែពុំស្របគ្នាដោយកន្លែងខ្លះដូចបាលីថា **សម្មាសម្ពុទ្ធោ ភគវា** ជាដើម ។ សៀវភៅខ្លះ **សម្មាសម្ពុទ្ធោ** ប្រែថាព្រះសម្មាសម្ពុទ្ធ, សៀវភៅខ្លះប្រែថា ព្រះអង្គត្រាស់ដឹងនូវព្រះធម៌ដ៏ប្រពៃដោយព្រះអង្គឯង ។ **ភគវា** សៀវភៅខ្លះប្រែថា ព្រះដ៏មានព្រះភាគ, សៀវភៅខ្លះប្រែថា ព្រះដ៏មានបុណ្យ ។ ឯពាក្យប្រែទាំងនេះ បើទុកជាពុំខុសគ្នាដោយសេចក្ដី ក៏គង់ជាហេតុនាំឲ្យអ្នកសិក្សាលះបង់ការរៀនសូធ្យធម៌ប្រែនេះចោលអស់ស្ទើរតែគ្រប់វត្ត ព្រោះរៀនហើយសូធ្យរួមជាមួយគ្នាពុំកើត ។

២- ធម៌ថ្វាយបង្គំព្រះវត្តព្រឹក - ល្ងាចប្រែ អាចស្វាធ្យាយជាកិច្ចវត្តយ៉ាងល្អណាស់ បើអ្នកណាបានយល់អត្ថរសច្បាស់ ហើយបានសូធ្យ

ធម៌ថ្វាយបង្គំព្រះដរាបចប់ចុងវត្ត អ្នកនោះឈ្មោះថាបានចម្រើនអារក្ខកម្មដ្ឋាន (កម្មដ្ឋានដែលគួររក្សាជាប់ជានិច្ច) គ្រប់ទាំង ៤, ទាំងអាចញ៉ាំងសេចក្តីជ្រះថ្លានិងសេចក្តីសង្វេគដែលជាបច្ច័យនៃសម្មាបដិបត្តិឲ្យកើតមាន ហើយបានសម្រេចផលានិសង្សយ៉ាងប្រសើរ ដែលហូរមកអំពីការថ្វាយបង្គំព្រះនេះផង ។

៣- គួរចាត់តាំងគណៈកម្មការមួយ ដែលអាចរៀបចំធម៌ថ្វាយបង្គំព្រះប្រែឲ្យបានត្រឹមត្រូវទាំងបាលីទាំងសម្រាយ រួចបោះពុម្ពផ្សាយឲ្យពួកពុទ្ធបរិស័ទរៀនសូត្យត្រូវគ្នាតែមួយបែប ។ ឯសៀវភៅធម៌ប្រែក្រៅពីនេះទាំងប៉ុន្មាន ទុកជាក្បួនសិក្សាសម្រាប់បដិបត្តិ និងជាគ្រឿងបំភ្លឺឲ្យមានសេចក្តីចេះដឹងផ្ទាល់ខ្លួន ។ កាលអនុវត្តបានដូច្នេះ នឹងបានសុខសាមគ្គី គួរជាទីគោរពនិងគួរជាទីជ្រះថ្លានៃពួកជនទូទៅ ។

ហេតុនេះ ខ្ញុំសូមពួកពុទ្ធបរិស័ទខំយកចិត្តទុកដាក់រៀនតាមសៀវភៅនេះឲ្យបានចេះចាំយ៉ាងស្ទាត់ ហើយអនុវត្តសូត្យថ្វាយបង្គំព្រះប្រែរួមគ្នាដើម្បីលើកតម្កើងគុណព្រះរតនត្រ័យគឺ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃផង ដើម្បីសេចក្តីសុខចម្រើនដល់យើងទាំងអស់គ្នាផង ទាំងដើម្បីប្រកាសគុណបុព្វាចារ្យទាំងឡាយ មានសម្តេចព្រះសុគន្ធាសង្ឃរាជាធិបតីជាដើមផង ។

ន័យមួយទៀត ការថ្វាយបង្គំព្រះនេះ លោកទុកជាកិច្ចវត្តមួយសម្រាប់

លើកស្ដួយយើងអ្នកធ្វើឲ្យរដោះផុតចាកទុក្ខបាន ។ ដូច្នេះក្នុងមួយថ្ងៃ ៗ គួរធ្វើឲ្យបានច្រើនលើក បើពុំសូវមានឱកាស គួរធៀតបំពេញឲ្យបានពីរលើកយ៉ាងតិច គឺព្រឹកមួយលើក ល្ងាចមួយលើក ទើបសមគួរដល់ឋានៈនៃយើងជាពុទ្ធសាសនិក ។ វេលាសម្រាប់ធ្វើវត្តព្រឹកគឺបច្ឆិមយាម[១] និងបុព្វណ្ហសម័យ[២], វេលាសម្រាប់ធ្វើវត្តល្ងាច គឺសាយណ្ហសម័យ[៣] និងបឋមយាម[៤] ។ វេលាសេសពីនេះនឹងទុកជាវេលាសម្រាកក៏គួរ ។

ទីបំផុតនេះ ខ្ញុំសូមថ្លែងអំណរដោយសង្ឃឹមទុកជាមុនថា ពួកពុទ្ធបរិស័ទ មុខជានឹងនាំគ្នាយកសៀវភៅថ្វាយបង្គំព្រះប្រែនេះ ទៅអនុវត្តហាត់សូត្យឲ្យស្រុះស្របគ្នា ដើម្បីលើកតម្កើងនូវព្រះពុទ្ធសាសនាឲ្យបានថ្កើងរុងរឿងតាមគោលបំណងនៃគណៈកម្មការនេះពុំខានឡើយ ។

**ឯតេន បុញ្ញតេជេន វុឌ្ឍឹ បប្បោន្តុ សព្វទា**

ដោយតេជះនៃបុណ្យនេះ សូមពួកពុទ្ធបរិស័ទទាំងឡាយដល់នូវសេចក្ដីចម្រើនគ្រប់កាល ។

ធ្វើនៅថ្ងៃទី ២៧ ខែវិច្ឆិកា $\frac{\text{ព.ស. ២៥០២}}{\text{គ.ស. ១៩៥៩}}$

សម្ដេចព្រះសុធម្មាធិបតីសង្ឃនាយក **ឥន្ទញាណោ "កុល ងេស"**

---

១-បច្ឆិមយាម កំណត់ពេលពីម៉ោង ២ ទៅដល់ម៉ោង ៦ ។ ២-បុព្វណ្ហសម័យ កំណត់ពេលពី ម៉ោង ៦ ទៅដល់ម៉ោង ១០ ។ ៣-សាយណ្ហសម័យ កំណត់ពេលពីម៉ោង ១៤ ទៅដល់ម៉ោង ១៨ ។ ៤-បឋមយាម កំណត់ពេលពីម៉ោង ១៨ ទៅដល់ម៉ោង ២២ ។

# សេចក្តីប្រារព្ធ

សៀវភៅវិធីថ្វាយបង្គំព្រះបាលី-ប្រែ (នមស្ការព្រះរតនត្រ័យ) វត្តព្រឹក-ល្ងាចនេះ កើតឡើងដោយហេតុមានដើមដូចតទៅនេះ ៖

១-កាលពីថ្ងៃអង្គារទី ១៤ កញ្ញា គ.ស ១៩៥៩ ត្រូវនឹងថ្ងៃ ១៣ កើត ខែភទ្របទ ឆ្នាំកុរឯកស័ក ព.ស ២៥០២ គណៈកម្មការកែប្រែកិច្ចប្រជុំអនុសំវច្ឆរមហាសន្និបាតនៃមន្ត្រីសង្ឃ ដែលមានលោកអនុរដ្ឋលេខាធិការក្រសួងធម្មការ សូ-ណែម ជាប្រធាន បានជំនុំពិភាក្សាសម្រេចថា ក្នុងកិច្ចប្រជុំនេះ រៀងរាល់ឆ្នាំតទៅ ត្រូវនិមន្តព្រះសង្ឃខាងគណៈធម្មយុត្តជាតំណាងព្រះសង្ឃក្នុងខែត្រមួយ ៗ ឲ្យបានក្នុងមួយខែត្រមួយរូប តាមខែត្រដែលមានព្រះសង្ឃខាងគណៈនេះ មកប្រជុំនៅព្រះរាជធានីភ្នំពេញរួមជាមួយសេនាបតីក្រសួងធម្មការម្តង, ក្នុងទីចំពោះព្រះកត្រ្តព្រះករុណាជាម្ចាស់ជីវិត, និងទទួលការអប់រំក្រោមអធិបតីភាព នៃសម្តេចព្រះសុធម្មាធិបតី សង្ឃនាយក វត្តបទុមវតី ។ ក្នុងការប្រជុំខាងក្រោយនេះ ព្រះសង្ឃតំណាងខែត្រនានា ត្រូវថ្លែងយោបល់ដោយលាយល័ក្ខអក្សរអំពីព្រឹត្តិការណ៍ផ្សេង ៗ ដែលនាំឲ្យចម្រើនព្រះពុទ្ធសាសនា ព្រមទាំងថ្លែងអំពីមធ្យោបាយយ៉ាងណា ដែលអាចញ៉ាំងព្រះពុទ្ធសាសនាឲ្យរុងរឿងដោយបរិយត្តិនិងដោយសម្មាបដិបត្តិ ។ ចំណែកព្រះថេរានុត្ថេរៈក្រៅពីនេះ

កាលបានទទួលអនុញ្ញាតអំពីសម្តេចព្រះសង្ឃនាយកហើយ ក៏អាចថ្លែងយោបល់បែបនេះបាន តាមសមគួរដល់ហេតុការណ៍ ។ បើមានបញ្ហាណាជាការចាំបាច់ត្រូវដោះស្រាយច្រើន គប្បីនៅប្រជុំតាមកាលគួរតទៅ ។

២- ដល់មកថ្ងៃសៅរ៍ទី ២៦ កញ្ញា ឆ្នាំដដែល សម្តេចព្រះសង្ឃ-នាយក បាននិមន្តព្រះថេរានុត្ថេរៈក្នុងក្រុងភ្នំពេញមកប្រជុំនៅវត្តបទុមវតីរួចសម្តេចបានស្នើដល់ទីប្រជុំនេះ អំពីការជំនុំសម្រេចនៃគណៈកម្មការកែប្រែកិច្ចប្រជុំអនុសំវច្ឆរមហាសន្និបាតនៃមន្ត្រីសង្ឃនោះ តាមសេចក្តីកត់ហេតុដែលផ្ញើមកពីក្រសួងធម្មការ ។ ទីប្រជុំក៏មានសេចក្តីត្រេកអរ រួចពិ-ភាក្សាសម្រេចដោយឯកច្ឆ័ន្ទថាត្រូវសូមឲ្យក្រសួងនេះ និមន្តព្រះសង្ឃជាតំណាងវត្តនានាខាងគណៈធម្មយុត្ត ក្នុងព្រះរាជអាណាចក្រ ឲ្យបានមួយវត្ត មួយរូប មកកាន់មហាសន្និបាតនេះតាមផ្លូវការ ព្រោះវត្តខាងគណៈធម្មយុត្តនេះមានចំនួនតិចទេ (ជាងមួយរយវត្តប៉ុណ្ណោះ) ។ តពីនេះទើបពិភាក្សាអំពីសៀវភៅធម៌អាថ៌ ដែលត្រូវបោះពុម្ពចែកជាទីរលឹកក្នុងមហាសន្និបាត ក៏សម្រេចដោយឯកច្ឆ័ន្ទទៀតថា ត្រូវចាត់តាំងគណៈកម្មការមួយ ដែលមានករណីយកិច្ចប្រជុំប្រែធម៌ថ្វាយបង្គំព្រះវត្ត-ព្រឹក - ល្ងាច រៀបរៀងឲ្យមានឃ្លាល្បះ ល្មមប្រកាសឲ្យពួកពុទ្ធបរិស័ទយក

ទៅអនុវត្តហាត់សូធ្យឲ្យបានរត់មាត់បាក់ផ្នត់តែមួយបែប ដើម្បីសូធ្យរួមគ្នាបានដោយស្រួល ។

អាស្រ័យការប្រជុំពិភាក្សាសម្រេចនេះ ទើបសម្តេចព្រះសង្ឃនាយកចាត់តាំងគណៈកម្មការមួយដែលមានប្រធាន អនុប្រធាន និងសមាជិកសុទ្ធតែជាព្រះថេរានុត្ថេរៈ ចំនួន ១៩ រូប នៅទីក្រុងភ្នំពេញ ដើម្បីប្រជុំរៀបរៀងធម៌វិធីថ្វាយបង្គំព្រះបាលី ប្រែ ។

៣-នៅថ្ងៃអាទិត្យ ទី ២៧ ខែកញ្ញា ឆ្នាំដដែល គណៈកម្មការនេះបានចាប់ប្រជុំប្រែរៀបរៀងធម៌ នៅមន្ទីរសង្ឃបណ្ណាល័យ វត្តបទុមវតី គឺយកធម៌ដែលប្រែខ្លះ មិនទាន់ប្រែខ្លះ មកពិភាក្សា រួចកែសម្រួលខ្លះ កែតម្រូវខ្លះ និងប្រែជាថ្មីខ្លះ ហើយនាំគ្នាអានសូធ្យពិសោធមើល កាលឃើញព្រមគ្នាថា ល្មមសូធ្យត្រូវតាមបាលីគាថា និងបាលីចុណ្ណិយបទ (វេយ្យាករណ៍) ព្រមទាំងឃ្លាល្បះស្រួលហើយ ទើបអនុម័តយកជាបានការធ្វើដូច្នេះ ទាល់តែចប់ធម៌ថ្វាយបង្គំព្រះវត្តព្រឹក-ល្ងាច ព្រមទាំងបន្ថែមធម៌ចុងវត្តខ្លះ ដើម្បីបំពេញឲ្យគ្រប់ជាចតុរារក្ខកម្មដ្ឋាន គឺ ពុទ្ធានុស្សតិ (ការរលឹកនូវព្រះពុទ្ធ) ១; មេត្តា (ការផ្សាយនូវមេត្តា) ១; អសុភៈ (ការពិចារណារាងកាយឲ្យឃើញថា ជារបស់មិនស្អាត) ១; មរណស្សតិ (ការរលឹកដល់សេចក្តីស្លាប់) ១; ព្រមទាំងធម៌ដទៃខ្លះទៀត ដែល

សម្រាប់សូធ្យជាកិច្ចបត្តិទាន, កិច្ចតាំងប្រាថ្នា, និងវិធីឧបាសកឧបាសិកា ដោយសង្ខេប ។ គណៈកម្មការធ្វើសង្ខេបត្រឹមប៉ុណ្ណោះ ដើម្បីបោះពុម្ព ឲ្យទាន់ពេលធ្វើកិច្ចអនុសំវច្ឆរមហាសន្និបាត ក្នុង ថ្ងៃទី ១៣ ខែមករា គ.ស. ១៩៦០ ព.ស. ២៥០២ ។

មុននឹងបោះពុម្ព សម្ដេចព្រះសង្ឃនាយក បាននិមន្ត អញ្ជើញ លោកអ្នកចេះដឹងទាំងខាងខ្មែរ ទាំងខាងបាលី គឺព្រះគ្រូវិសុទ្ធិវង្ស ម៉ៅ-ខាន់ ១ ឯកឧត្តម ញ៉ុក-ធួរ ១ អ្នកឧកញ៉ា អ៊ុត-ម៉ូត ១ អ្នកឧកញ៉ាព្រះស្ដេច កឹម-សាយ ១ ព្រះសុធម្មប្រីជា កេត ធន អាចារ្យវត្តបទុមវតី ១ ឃុនបណ្ណា-នុរក្ស ប៊ូ-ប៉ូ ១ លោកសុខ-សាប អាចារ្យវត្តពុទ្ធឃោសារាម ១ លោក សៅ-យ៉ា អាចារ្យវត្តប្រយូរវង្សារាម ១ លោក ប្រាជ្ញ-ហ៊ឹម អាចារ្យវត្ត នួនមណីរាម ១ និងសមាជិកគណៈកម្មការខ្លះដែលមានធុរៈមិនអាចមក ជួយប្រែរៀបរៀងពីពេលមុន ឲ្យមកជួបជុំនៅថ្ងៃទី ២៦-២៧ ខែវិច្ឆិកា ឆ្នាំដដែល ដើម្បីជួយពិនិត្យកែសម្រួលធម៌ប្រែនេះ ដែលសម្ដេចចាត់ ឲ្យអានជូនទីប្រជុំស្ដាប់ កាលបានទទួលអនុម័តិពីទីប្រជុំនេះហើយ ទើប ចាត់ការបោះពុម្ពចំនួន ៤.០០០ចប់ សម្រាប់ចែកផ្សាយឲ្យបានទូទៅ ច្រើនគ្នា ។

ការប្រែធម៌បោះពុម្ពផ្សាយបែបនេះ នាំឲ្យគណៈកម្មការនឹកព្រះ

គុណដ៏ធំធេងនៃសម្តេចព្រះសុគន្ធាសង្ឃរាជាធិបតីព្រះនាម **បញ្ញាសីលោ "ចាំង"** ជាបុព្វាចារ្យនិងជាព្រះឧបជ្ឈាយ៍ដើម ដែលទ្រង់បាននាំធម្មយុត្តិកវង្សមកប្រតិស្ឋានក្នុងកម្ពុជរដ្ឋនេះ និងនឹកស្តាយជាទីបំផុតនូវសម្តេចក្រុមព្រះ **ឧពេត្តម-ភាណុវង្ស** កាលដែលទ្រង់គង់ព្រះជន្មនៅឡើយ ទ្រង់បានព្យាយាមស្ថាបនារោងពុម្ពមួយឡើង ហើយផ្តើមរៀបរៀងវិនយវណ្ណនា វិវិធធម្មសង្គហៈ ឧបោសថកថា និងសៀវភៅដទៃទៀតជាច្រើន បោះពុម្ពផ្សាយដល់ពួកពុទ្ធបរិស័ទទូទៅក្នុងកម្ពុជរដ្ឋ ដើម្បីឧទ្ទិសចំពោះព្រះពុទ្ធសាសនាឲ្យបានស្ថាពរ ទាំងនិមន្តព្រះសង្ឃអំពីអារាមផ្សេង ៗ មានវត្តបទុមវតីជាដើម ទៅប្រជុំឯធម្មមន្ទីរដំណាក់ទ្រង់ ដើម្បីសាកច្ឆាធម៌ ប្រែធម៌ សមសូធ្យធម៌ ហាត់វិធីអក្ខរៈ ឲ្យត្រឹមត្រូវតាមមគធភាសា រាល់សប្តាហៈនៃថ្ងៃកិច្ចវត្ត ទាំងបានបរិច្ចាគព្រះរាជទ្រព្យឧបត្ថម្ភករណីយកិច្ចនោះជានិរន្តរ៍ ដោយមានព្រះយោបល់ថា ការបំពេញសុធម្មចរិយាវត្តនេះ ជាឧបាយដ៏ឧត្តមនាំមកនូវសាមគ្គីធម៌និងសន្តិសុខរវាងពុទ្ធបរិស័ទទូទៅគ្រប់កាល ទាំងអាចធ្វើព្រះពុទ្ធសាសនាឲ្យរុងរឿងជាកិយ្យោភាពតរៀងទៅ ។

ព្រមទាំងនឹកស្តាយពុំភ្លេចដល់សម្តេចព្រះរាជអយ្យកោ វរចក្ររណោរិទ្ធិ **ឧពេត្តម-សុជាវស** អធិបតីពុទ្ធសាសនបណ្ឌិតសភា ដែលជា

ព្រះវររាជបិតានៃព្រះករុណាជាម្ចាស់ជីវិត ព្រះបាទសម្តេចព្រះ **នរោត្តម-សុរាម្រិត** ព្រោះដំណើរនេះស្របតាមព្រះរាជបំណង ដ្បិតកាលទ្រង់គង់ព្រះជន្មនៅឡើយ តែងទ្រង់រិះរកមធ្យោបាយឲ្យបានទទួលសាមគ្គីរសវាងក្រុមនិងវាងគណៈជាដរាប ទាំងមានព្រះរាជចុតហ្មាយមកប្រគេនសម្តេចព្រះមង្គលទេពាចារ្យ ព្រះនាម **បញ្ញាជីថោ "ស៊ុក"** ស្នើសុំចាត់ព្រះសង្ឃជាតំណាងមួយរូប ៗ គ្រប់ក្រុមទៅប្រជុំនៅព្រះមន្ទីរធម្មសកានាព្រះដំណាក់វាំងទក្ខិណាភិរម្យនៃព្រះអង្គ រាល់រាត្រីថ្ងៃ ៧ កើត ៧ រោចនិងរាល់ថ្ងៃកោរខ្មៅ-រនោច ដើម្បីពិភាក្សាធម៌ សមសូធ្យធម៌ឲ្យបានចុះសម្រុងគ្នាជារបៀបតែមួយ ។ សម្តេចព្រះរាជអយ្យកោ ព្រមទាំងសម្តេចព្រះរាជអយ្យិកាព្រះខត្តិយកល្យាណរាជសុតាភគវតី **នរោត្តម-ជាជ៉ាជ៉ាម** ជាព្រះជាយា ទ្រង់បានប្រកាសព្រះអង្គជាសាសនូបត្ថម្ភក៍ ក្នុងកិច្ចនេះដោយទ្រង់មានព្រះយោបល់ថាធ្វើដូច្នេះ ពិតជានឹងនាំមកនូវសាមគ្គីរសយ៉ាងប្រសើរ ហើយលូតលាស់ចម្រើនក្នុងព្រះពុទ្ធសាសនាទាំងអស់គ្នា ។

ដោយនឹកព្រះគុណធ្ងន់នេះ គណៈកម្មការ សូមឧទ្ទិសផលអំពីកុសលរាសីនេះ ថ្វាយចំពោះសម្តេចគ្រប់ព្រះអង្គនោះ ។ មួយទៀតសូមទ្រង់ អស់លោក-អ្នក ដែលបានបរិច្ចាគធនធានជួយឧបត្ថម្ភក្នុងការកុសលនេះ បានជួបប្រសព្វតែនូវសុភមង្គលរាល់ទិវារាត្រីកុំបីឃ្លាត ។

*ក្នុងទីបំផុតនេះ គណៈកម្មការសូមថ្វាយព្រះរាជកុសលអំពីមហាបុញ្ញរាសីនេះ ចំពោះព្រះករុណាជាម្ចាស់ជីវិត ព្រះបាទសម្តេចព្រះ* **នរោត្តម សុរាម្រិត** *សម្តេចព្រះមហាក្សត្រិយានី* **ស៊ីសុវត្ថិមុនីវង្សកុសុម-នារីរតនសិរីវឌ្ឍនា** *និងសម្តេចព្រះឧបយុវរាជ* **នរោត្តម សីហនុវរ្ម័ន** *ដែលជាព្រះអគ្គសាសនូបត្ថម្ភក៍ និងជាទីពឹងយ៉ាងខ្ពង់ខ្ពស់នៃពុទ្ធសាសនិកទូទៅ សូមទ្រង់គង់នៅជាសុខក្សេមក្សាន្តព្រះរាជហឫទ័យក្នុងព្រះសិរីរាជសម្បត្តិ ដើម្បីជាម្លប់ដ៏ត្រជាក់ នៃប្រជាពលរដ្ឋក្នុងព្រះរាជ-អាណាចក្រអស់កាលជាអង្វែងតទៅ ។*

**ឥតោ ជេន សុបុញ្ញេន សោត្ថិ ហោតុ សទាបិ នោ**
**សាសនំ សត្ថុ អម្ហាកំ ចិរំ ទិប្បតុ តាទិនោ**

*ដោយបុញ្ញរាសី ដែលកើតអំពីសេចក្តីខ្វល់ខ្វាយនៃយើងនេះ សូមសួស្តីកើតមានដល់យើងគ្រប់កាល, ទាំងសាសនានៃព្រះសាស្តា ដែលប្រកបដោយតាទិគុណរបស់យើង ក៏សូមរុងរឿងអស់កាលជាអង្វែងតរៀងទៅ កុំបីខានឡើយ ។*

*ធ្វើនៅថ្ងៃសុក្រទី ២៨ ខែវិច្ឆិកា គ.ស. ១៩៥៩ (ថ្ងៃ ៦ ១៣ ១២ ឆ្នាំកុរឯកស័ក ព.ស. ២៥០២)*

---

-ផ-

# គណៈកម្មការ

១- ព្រះពុធាចារ្យ ទេព-សឿង វត្តទួនមណីរាម ជាប្រធាន

២- ព្រះមង្គលទេពាចារ្យ កែវ-អ៊ុច វត្តបទុមវតី ជាអនុប្រធាន

៣- ព្រះធម្មឧត្តម ហ៊ី-ជា វត្តបទុមវតី ជាសមាជិក

៤- ព្រះអរិយវង្ស មាស-សុវណ្ណ វត្តស្វាយពពែ ជាសមាជិក

៥- ព្រះមហាវីរវង្សាចារ្យ វ៉ាន់-សាឧុម វត្តទួនមណីរាម ជាសមាជិក

៦- ព្រះញាណរង្សី ឡុង-ឈាវ វត្តបទុមវតី ជាសមាជិក

៧- ព្រះធម្មត្រៃលោកាចារ្យ កោត-តោ វត្តបទុមវតី ជាសមាជិក

៨- ព្រះអរិយមុនី ចាន់-សូ វត្តបទុមវតី ជាសមាជិក

៩- ព្រះបទុមវង្សា សុខ-យឹន វត្តបទុមវតី ជាសមាជិក

១០- ព្រះធម្មវរោត្តម តុង-ឈួន វត្តបទុមវតី ជាសមាជិក

១១- ព្រះសុធម្មត្ថេរ សំ-ពៅ វត្តពុទ្ធឃោសារាម ជាសមាជិក

១២- ព្រះអមរាភិរក្ខិត កែវ-ស៊ុម វត្តបទុមវតី ជាសមាជិក

១៣-ព្រះវជិរមេធា ម៉ា-ឡុង វត្តប្រយូរវង្សារាម ជាសមាជិក

១៤-ព្រះគ្រូវជិរបញ្ញាមុនី ងូ-យ៉ង វត្តបទុមវតី ជាសមាជិក

១៥- ព្រះគ្រូមហាឧត្តុល កោក-ផង វត្តបទុមវតី ជាសមាជិក

១៦- ព្រះគ្រូសាសនសោភ័ណចាន់-សាលី វត្តបទុមវតី ជាសមាជិក

១៧- ព្រះគ្រូសមាធិញាណ **មាស-តង់** វត្តបទុមវតី ជាសមាជិក

១៨- ព្រះបាឡាត់ពុធាចារ្យ ឡេ-ឡុង វត្តនួនមណីរាម ជាសមាជិក

១៩- ព្រះគ្រូញាណមុនី ឡេង-រៀម វត្តស្វាយពពែជាលេខាធិការ

**ឲ★ឲ**

# បញ្ជីរឿង


| លេខរៀង | ឈ្មោះ អត្ថបទ | ទំព័រ |
|---|---|---|
| ១ | កិច្ចប្រកាសខ្លួន...................................................................... | ១ |
| ២ | កិច្ចថ្វាយបង្គំព្រះរតនត្រ័យ................................................. | ២ |
| ៣ | កិច្ចថ្វាយគ្រឿងសក្ការៈ ថ្វាយចំពោះព្រះពុទ្ធ.......................... | ៣ |
| ៤ | កិច្ចថ្វាយគ្រឿងសក្ការៈ ថ្វាយចំពោះព្រះរតនត្រ័យ.............. | ៥ |
| ៥ | កិច្ចថ្វាយបង្គំព្រះរតនត្រ័យវត្តព្រឹក...................................... | ៦ |
| ៦ | កិច្ចថ្វាយបង្គំព្រះរតនត្រ័យវត្តល្ងាច...................................... | ១៨ |
| ៧ | គោតមកចេតិយធម្មបរិយាយ............................................ | ៣០ |
| ៨ | សីលុទ្ទេសបាឋ.................................................................. | ៣១ |
| ៩ | មេត្តាភាវនា......................................................................... | ៣២ |
| ១០ | ឧបេក្ខាភាវនា...................................................................... | ៣៣ |
| ១១ | អសុភភាវនា......................................................................... | ៣៤ |
| ១២ | មរណស្សតិភាវនា................................................................ | ៣៥ |
| ១៣ | អភិណ្ហបច្ចវេក្ខណៈ.............................................................. | ៣៥ |
| ១៤ | សំវេគវត្ថុបរិកិត្តនគាថា......................................................... | ៣៦ |
| ១៥ | ខេមាខេមស្សរណទីបិកាគាថា............................................ | ៣៧ |
| ១៦ | សច្ចកិរិយគាថា..................................................................... | ៣៨ |
| ១៧ | មហាការុណិកគាថា.............................................................. | ៣៩ |
| ១៨ | បក្ខគណនាវិធានគាថា........................................................ | ៤០ |
| ១៩ | ទេវតាទិបត្តិទានគាថា.......................................................... | ៤២ |
| ២០ | បត្តិទានគាថា....................................................................... | ៤៣ |
| ២១ | ទេវតាទិបត្តិទានគាថា.......................................................... | ៤៤ |
| ២២ | បណិធានគាថា...................................................................... | ៤៥ |

| | | |
|---|---|---|
| ២៣ | វិធីសូមខមាទោស.......................................................................... | ៤៧ |
| ២៤ | វិធីថ្វាយខ្លួន.............................................................................. | ៤៩ |
| ២៥ | ការសមាទាននិច្ចសីល និងសរណគមន៍...................................... | ៥០ |
| ២៦ | ការសមាទានឧបោសថសីល និងសរណគមន៍............................. | ៥៤ |
| ២៧ | វិធីអារាធនាបរិត្ត........................................................................ | ៥៨ |
| ២៨ | វិធីអារាធនាធម្មទេសនា.............................................................. | ៥៩ |
| ២៩ | វិធីវេរភត្តថ្វាយសង្ឃ.................................................................... | ៦១ |
| ៣០ | របៀបធ្វើមាឃបូជា........................................................................ | ៦៣ |
| ៣១ | វិធីប្រកាសមាឃបូជា.................................................................... | ៦៤ |
| ៣២ | របៀបធ្វើវិសាខបូជា...................................................................... | ៦៦ |
| ៣៣ | វិធីប្រកាសវិសាខបូជា.................................................................. | ៦៨ |
| ៣៤ | នមោ ៨បទ.................................................................................... | ៧០ |
| ៣៥ | វិធីសូត្រវិសាខបូជា...................................................................... | ៧១ |
| ៣៦ | វិធីសូត្រមាឃបូជា........................................................................ | ៧២ |
| ៣៧ | ពាក្យសូត្រថ្វាយសក្ការៈក្នុងថ្ងៃវិសាខបូជា.................................... | ៧៥ |
| ៣៨ | ពាក្យសូត្រថ្វាយសក្ការៈក្នុងថ្ងៃមាឃបូជា........................................ | ៧៩ |
| ៣៩ | ទេវតាទិបត្តិទានគាថា.................................................................. | ៨១ |
| ៤០ | សរសើរព្រះរតនត្រ័យសង្ខេប....................................................... | ៨២ |
| ៤១ | ព្រះរាជប្រវត្តិនៃសម្តេចព្រះសុគន្ធាធិបតីបញ្ញាសីលោប៉ាន.............. | ៨៣ |
| ៤២ | ព្រះឱវាទនៃសម្តេចព្រះសុគន្ធាធិបតីបញ្ញាសីលោប៉ាន................... | ៨៨ |
| ៤៣ | ពុទ្ធភាសិត.................................................................................. | ៨៩ |
| ៤៤ | សិទ្ធីការ្យគណៈធម្មយុត្តិកនិកាយ................................................. | ៩៨ |
| ៤៥ | គាថាអាឡវកយក្ខ........................................................................ | ១០០ |
| ៤៦ | បេមតោ....................................................................................... | ១០៤ |

១

# វិធីថ្វាយបង្គំព្រះវត្តព្រឹក

## ប្រែ

## កិច្ចប្រកាសខ្លួន

**អហំ ពុទ្ធញ្ច ធម្មញ្ច, សង្ឃញ្ច សរណំ** { **គតោ**[១] / **គតា,** }

{ **ឧបាសកតំ**[២] / **ឧបាសិកតំ** } *ខ្ញុំដល់ហើយនូវព្រះពុទ្ធព្រះធម៌និងព្រះសង្ឃជាទីពឹង,*

**វេទេមិ, ភិក្ខុសង្ឃស្ស សម្មុខា,** *ហើយប្រកាសខ្លួនជា* { *ឧបាសក* / *ឧបាសិកា* } *ក្នុងទីចំពោះព្រះភក្ត្រនៃភិក្ខុសង្ឃ,* **ឯតំ ខោ សរណំ ខេមំ,** *នេះជាទីពឹងដ៏ក្សេមនិងជាទីពឹងដ៏ឧត្តមរបស់ខ្ញុំ,* **ឯតំ សរណមុត្តមំ,** **ឯតំ សរណមាគម្ម, សព្វទុក្ខា បមុច្ចយេ,** *អាស្រ័យនូវទីពឹងនេះហើយ គប្បីរួចចាកទុក្ខទាំងពួង,* **យថាពលំ ការេយ្យាហំ, សម្មាសម្ពុទ្ធសាសនំ,** *ខ្ញុំគប្បីធ្វើតាមនូវសាសនានៃព្រះសម្មាសម្ពុទ្ធ, ដ៏សមគួរដល់កម្លាំង,* **ទុក្ខនិស្សរណស្សេវ,**

១- គតោ សម្រាប់បុរសថា, គតា សម្រាប់ស្ត្រីថា ។ ២- ឧបាសកតំ សម្រាប់បុរសថា, ឧបាសិកតំ សម្រាប់ស្ត្រីថា, ។

**ភាគី**[១]
**ហោមិ អនាគតេ**, *ខ្ញុំសូមបានចំណែកនៃព្រះនិព្វាន,*
**ភាគិនី**
*ជាទីរលាស់ចាកទុក្ខក្នុងកាលជាអនាគត កុំខានឡើយ ។*

**- កិច្ចថ្វាយបង្គំព្រះរតនត្រ័យ**

*កាលដល់ពេលធ្វើវត្តព្រឹក គប្បីប្រជុំគ្នាក្នុងបូជនីយស្ថាន មានព្រះវិហារជាដើម ហើយតាក់តែងគ្រឿងសក្ការបូជា មានទៀន ធូបជាដើម ចំពោះព្រះភក្ត្រព្រះពុទ្ធរូប រួចហើយមេនាំគប្បីអង្គុយលុតជង្គង់ លើកដៃប្រណម្យអំពីមុខបរិស័ទទាំងពួ នាំសូធ្យធម៌ថ្វាយបង្គំព្រះរតនត្រ័យ ដូចន័យតទៅនេះ ៖*

**កិច្ចថ្វាយបង្គំព្រះរតនត្រ័យ**

**អរហំ សម្មាសម្ពុទ្ធោ ភគវា**, *ព្រះពុទ្ធជាម្ចាស់ព្រះអង្គឆ្ងាយចាកកិលេសហើយ, ត្រាស់ដឹងនូវព្រះធម៌ដ៏ប្រពៃដោយព្រះអង្គឯង, ទ្រង់ចែកធម៌ដល់សត្វទាំងឡាយ,* **ពុទ្ធំ ភគវន្តំ អភិវាទេមិ**, *ខ្ញុំក្រាបថ្វាយបង្គំនូវព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ។*

ក្រាបថ្វាយបង្គំម្តង

---

ឯកិច្ចប្រកាសខ្លួននេះ សម្រាប់តែពួកគ្រហស្ថដែលដល់ព្រះត្រៃសរណគមន៍ហើយ គប្បីសូធ្យក្នុងពិធីធ្វើកិច្ចជាកុសលណាមួយ មានការសមាទានសីល ឬ ថ្វាយបង្គំព្រះវត្តព្រឹកល្ងាចជាដើម, ឯពួកបព្វជិតគឺភិក្ខុ-សាមណេរ មិនត្រូវសូធ្យទេ ។

១- **ភាគី** សម្រាប់បុរសថា, **ភាគិនី**- សម្រាប់ស្ត្រីថា ។

**ស្វាក្ខាតោ ភគវតា ធម្មោ,** *ព្រះធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សម្ដែងប្រពៃហើយ,* **ធម្មំ នមស្សាមិ,** *ខ្ញុំក្រាបថ្វាយបង្គំនូវព្រះធម៌ ។*

ក្រាបថ្វាយបង្គំម្ដង

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ,** *ព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគលោកបដិបត្តិប្រពៃហើយ,* **សង្ឃំ វន្ទាមិ,** *ខ្ញុំក្រាបថ្វាយបង្គំនូវព្រះសង្ឃ ។*

ក្រាបថ្វាយបង្គំម្ដង

**-ថ្វាយគ្រឿងសក្ការៈ**

ថ្វាយចំពោះព្រះពុទ្ធ

**ឥមានិ** { **អហំ**[1] / **មយំ** } **បដិមារូបានិ, តំ ភគវន្តំ ធរមា-**

**នំ វិយ មញ្ញមា** { **ណោ**[2] *ខ្ញុំ* / **ណា,** *យើងខ្ញុំ* } *សម្គាល់នូវពិម្ពព្រះពុទ្ធរូប*

*ទាំងឡាយនេះ, ថាដូចជាព្រះដ៏មានព្រះភាគព្រះអង្គគង់ព្រះជន្មនៅ*

---

ពាក្យថា **ឥមានិ** និង **បដិមារូបានិ** សម្រាប់ព្រះពុទ្ធរូបច្រើនអង្គ, បើមានតែព្រះពុទ្ធរូបមួយអង្គត្រូវផ្លាស់ **ឥមានិ** ជា **ឥមំ**, **បដិមារូបានិ** ជា **បដិមារូបំ** ។ ១ **អហំ** សម្រាប់បុរសឬស្ត្រីម្នាក់ឯងថា, **មយំ** សម្រាប់គ្នាច្រើនថា, ២ **មាណោ** សម្រាប់បុរសម្នាក់ឯងថា, **មាណា** សម្រាប់ ស្ត្រីម្នាក់ ឬ ស្ត្រី បុរសច្រើនថា ។

*ឡើយ,* **ទីបធូបាទិសក្ការេហិ អភិបូជយា** { **មិ** / **ម**, } *ហើយបូជា*

*ដោយសក្ការៈទាំងឡាយមានទៀនធូបជាដើម,* **សាធុ** { **មេ** / **នោ** } **ភន្តេ ភគវា, សុចិរបរិនិព្វុតោបិ, ឥមំ ទីបធូបាទិសក្ការំ បដិ-គ្គណ្ហាតុ,** *បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន សូម្បីព្រះអង្គបរិនិព្វានកន្លងទៅហើយអស់កាលយូរ, សូមទ្រង់ទទួលយកនូវសក្ការៈមានទៀនធូបជាដើមនេះរបស់* { *ខ្ញុំ,* **មេ** / *យើងខ្ញុំ,* **នោ** } **មាតាបិតុគរុអាទីនញ្ច,**

{ **មយ្ហញ្ច** / **អម្ហាកញ្ច** } **ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ,** *ដើម្បីជាប្រយោជន៍ ជាគុណ និងសេចក្ដីសុខ, ដល់លោកដ៏មានគុណទាំងឡាយ, មានមាតាបិតាគ្រូឧបជ្ឈាយាចារ្យជាដើមរបស់* { *ខ្ញុំ* / *យើងខ្ញុំ* } *ផង,*

*ដល់* { *ខ្ញុំ* / *យើងខ្ញុំ* } *ផង, អស់រាត្រីដ៏វែងតរៀងទៅ ។*

---

មិ, មេ, មយ្ហញ្ច, សម្រាប់ បុរស ឬ ស្ត្រីម្នាក់ឯងថា ។ ម, នោ, អម្ហាកញ្ច សម្រាប់គ្នាច្រើនថា ។

៥

# ថ្វាយចំពោះព្រះរតនត្រ័យ

**យមហំ សម្មាសម្ពុទ្ធំ ភគវន្តំ សរណំ** { **គតោ**[១] / **គតា**, } *ខ្ញុំដល់*

*ហើយនូវព្រះដ៏មានព្រះភាគអង្គណា, ដែលព្រះអង្គត្រាស់ដឹងនូវព្រះធម៌ដ៏ប្រពៃដោយព្រះអង្គឯងជាទីពឹង,* **តំ ភគវន្តំ ឥមេហិ សក្ការេហិ អភិបូជយាមិ,** *ខ្ញុំបូជានូវព្រះដ៏មានព្រះភាគអង្គនោះដោយសក្ការៈទាំងឡាយនេះ,* **តំ ភគវន្តំ អភិវាទេមិ,** *ខ្ញុំក្រាបថ្វាយបង្គំនូវព្រះដ៏មានព្រះភាគអង្គនោះ ។*

ក្រាបថ្វាយបង្គំម្តង

**យមហំ ស្វាក្ខាតំ ភគវតា ធម្មំ សរណំ** { **គតោ**[២] / **គតា**, } *ខ្ញុំ*

*ដល់ហើយនូវព្រះធម៌ណា, ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងប្រពៃហើយជាទីពឹង,* **តំ ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ** *ខ្ញុំបូជានូវព្រះធម៌នោះដោយសក្ការៈទាំងឡាយនេះ,* **តំ ធម្មំ នមស្សាមិ,** *ខ្ញុំក្រាបថ្វាយបង្គំនូវព្រះធម៌នោះ ។*

ក្រាបថ្វាយបង្គំម្តង

---

១-២- គតោ, សម្រាប់បុរសថា, គតា សម្រាប់ស្ត្រីថា ។

**យមហំ សុបដិបន្នំ សង្ឃំ សរណំ** { **គតោ**[១] / **គតា**, } *ខ្ញុំដល់*

*ហើយនូវព្រះសង្ឃអង្គណា, ដែលលោកបដិបត្តិប្រពៃហើយជាទីពឹង,* **តំ សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ,** *ខ្ញុំបូជានូវព្រះសង្ឃអង្គនោះដោយសក្ការៈទាំងឡាយនេះ,* **តំ សង្ឃំ វន្ទាមិ,** *ខ្ញុំក្រាបថ្វាយបង្គំនូវព្រះសង្ឃអង្គនោះ ។*

ក្រាបថ្វាយបង្គំម្ដង

- កិច្ចថ្វាយបង្គំព្រះរតនត្រ័យវត្តព្រឹក

ប្រែ

---

*មេនាំ សូធ្យបណាមវចនៈថា*

**ហន្ទ មយំ ពុទ្ធស្ស ភគវតោ បុព្វភាគនមការំ ករោម សេ,** *មុនដំបូងយើងទាំងឡាយនមស្ការចំពោះព្រះដ៏មានព្រះភាគ ដែលព្រះអង្គត្រាស់ដឹងហើយ ។*

*សូធ្យនមស្ការព្រមគ្នា*

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**[២] ។

---

១- គតោ សម្រាប់បុរសថា, គតា សម្រាប់ស្ត្រីថា ។ ២- សូធ្យបីដង ។

សូមនមស្ការចំពោះព្រះពុទ្ធជាម្ចាស់អង្គនោះ, ព្រះអង្គឆ្ងាយចាកកិលេសហើយ, ត្រាស់ដឹងនូវព្រះធម៌ដ៏ប្រពៃដោយព្រះអង្គឯង, ទ្រង់ចែកធម៌ដល់សត្វទាំងឡាយ ។

## ពាក្យសរសើរព្រះពុទ្ធគុណ

មេនាំ សូធ្យថា

**ហន្ទ មយំ ពុទ្ធាភិថុតឹ ករោម សេ,** យើងទាំងឡាយសរសើរព្រះពុទ្ធគុណ ។

សូធ្យព្រមគ្នា

**យោ សោ តថាគតោ,** រីព្រះតថាគតអង្គណា, **អរហំ,** ព្រះអង្គឆ្ងាយចាកកិលេសហើយ, **សម្មាសម្ពុទ្ធោ,** ព្រះអង្គត្រាស់ដឹងនូវព្រះធម៌ដ៏ប្រពៃដោយព្រះអង្គឯង, **វិជ្ជាចរណសម្បន្នោ,** ព្រះអង្គដល់ព្រមដោយវិជ្ជានិងចរណៈហើយ, **សុគតោ,** ព្រះអង្គយាងទៅប្រពៃហើយ, **លោកវិទូ,** ព្រះអង្គទ្រង់ជ្រាបច្បាស់នូវលោកហើយ, **អនុត្តរោ បុរិសទម្មសារថិ,** ព្រះអង្គទ្រង់ទូន្មាននូវបុរសដ៏គួរទូន្មានពុំមានអ្នកណាលើស, **សត្ថា ទេវមនុស្សានំ,** ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ, **ពុទ្ធោ,** ព្រះអង្គមានព្រះគុណរីកពេញ

*ហើយ,* **ភគវា,** *ព្រះអង្គទ្រង់ចែកធម៌ដល់សត្វទាំងឡាយ,* **យោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ, សស្ស-មណព្រាហ្មណឹ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេសិ,** *ព្រះតថាគតអង្គណាទ្រង់ប្រកាសនូវលោកនេះ ព្រមទាំងទេវតាមារព្រហ្ម, នូវពពួកសត្វព្រមទាំងសមណព្រាហ្មណ៍និងមនុស្សជាសម្មតិទេព, និងមនុស្សដ៏សេសឲ្យប្រាកដហើយ ព្រោះទ្រង់ធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ក្រៃពេកចំពោះព្រះអង្គឯង,* **យោ ធម្មំ ទេសេសិ,** *ព្រះតថាគតអង្គណាទ្រង់សម្ដែងហើយនូវធម៌,* **អាទិកល្យាណំ,** *ជាធម៌ពីរោះខាងដើម,* **មជ្ឈេកល្យាណំ,** *ជាធម៌ពីរោះត្រង់កណ្ដាល* **បរិយោសានកល្យាណំ,** *ជាធម៌ពីរោះក្នុងទីបំផុត,* **សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិ-សុទ្ធំ ព្រហ្មចរិយំ បកាសេសិ,** *ទ្រង់ប្រកាសហើយនូវព្រហ្ម-ចរិយធម៌ព្រមទាំងអត្ថនិងព្យញ្ជនៈ, ដ៏បរិសុទ្ធបរិបូណ៌ពុំមានសេសសល់ ។* **តមហំ ភគវន្តំ អភិបូជយាមិ,** *ខ្ញុំបូជានូវព្រះតថាគតដ៏មានព្រះភាគអង្គនោះ,* **តមហំ ភគវន្តំ សិរសា នមាមិ,** *ខ្ញុំក្រាបថ្វាយបង្គំនូវព្រះតថាគតដ៏មានព្រះភាគអង្គនោះដោយសិរសា ។*

ក្រាបថ្វាយបង្គំម្ដង

៩

# ពាក្យសរសើរព្រះធម្មគុណ

*មេនាំ សូធ្យថា*

**ហន្ទ មយំ ធម្មាភិថុតឹ ករោម សេ,** *យើងទាំង-ឡាយសរសើរព្រះធម្មគុណ ។*

សូធ្យព្រមគ្នា

**យោ សោ ស្វាក្ខាតោ ភគវតា ធម្មោ,** *ព្រះធម៌ណាដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងប្រពៃហើយ* **សន្ទិដ្ឋិកោ,** *ជាធម៌ដែលអ្នកបដិបត្តិឃើញច្បាស់ដោយខ្លួនឯង,* **អកាលិកោ,** *ជាធម៌ឲ្យផលពុំមានកំណត់កាល,* **ឯហិបស្សិកោ,** *ជាធម៌មានអាការៈអាចហៅអ្នកដទៃមកមើលបាន,* **ឱបនយិកោ,** *ជាធម៌គួរបង្អោនមកដាក់ក្នុងចិត្តបាន,* **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ,** *ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយគប្បីដឹងចំពោះខ្លួន ។* **តមហំ ធម្មំ អភិបូជយាមិ,** *ខ្ញុំបូជានូវព្រះធម៌នោះ,* **តមហំ ធម្មំ សិរសា នមាមិ,** *ខ្ញុំក្រាបថ្វាយបង្គំនូវព្រះធម៌នោះ ដោយសិរសា ។*

ក្រាបថ្វាយបង្គំម្តង

## ពាក្យសរសើរព្រះសង្ឃគុណ

*មេនាំ សូធ្យថា*

**ហន្ទ មយំ សង្ឃាភិថុតឹ ករោម សេ,** *យើងទាំង-ឡាយសរសើរព្រះសង្ឃគុណ ។*

សូធ្យព្រមគ្នា

**យោ សោ សុបដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃសាវកអង្គណានៃព្រះដ៏មានព្រះភាគលោកបដិបត្តិប្រពៃហើយ* **ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ,** *ព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគលោកបដិបត្តិត្រង់ហើយ,* **ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ,** *ព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគលោកបដិបត្តិដើម្បីចេញចាកសង្សារទុក្ខហើយ,* **សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ,** *ព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគលោកបដិបត្តិសមគួរនឹងព្រះនិព្វានហើយ,* **យទិទំ,** *ព្រះសង្ឃសាវ័កអង្គនោះគឺ* **ចត្តារិ បុរិសយុគានិ,** *បើរាប់ជាគូនៃបុរសមានបួនគូ,* **អដ្ឋ បុរិសបុគ្គលា,** *បើរាប់រៀងបុរសបុគ្គលមានប្រាំបី,* **ឯស ភគវតោ សាវកសង្ឃោ,** *នេះជាព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ,* **អាហុនេយ្យោ,** *លោកគួរទទួលរបស់ដែលគេ*

*នាំមកបូជា,* **ចាហុនេយ្យោ,** *លោកគួរទទួលរបស់ដែលគេនាំមកទទួលភ្ញៀវ,* **ទក្ខិណេយ្យោ** *លោកគួរទទួលទក្ខិណាទាន,* **អញ្ជលិករណីយោ,** *លោកគួរទទួលអញ្ជលីប្រណម្យ,* **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស,** *លោកជាស្រែបុណ្យដ៏ប្រសើរលើសនៃសត្វលោក ។* **តមហំ សង្ឃំ អភិបូជយាមិ,** *ខ្ញុំបូជានូវព្រះសង្ឃអង្គនោះ,* **តមហំ សង្ឃំ សិរសា នមាមិ,** *ខ្ញុំក្រាបថ្វាយបង្គំនូវព្រះសង្ឃអង្គនោះដោយសិរសា ។*

ក្រាបថ្វាយបង្គំម្តង

ហើយអង្គុយរាប

## រតនត្តយប្បណាមគាថា

*មេនាំ សូធ្យថា*

**ហន្ទ មយំ រតនត្តយប្បណាមគាថាយោ ចេវ សំវេគវត្ថុបរិកិត្តនបាឋញ្ច ភណាម សេ,** *យើងទាំងឡាយសូធ្យគាថានមស្ការព្រះរតនត្រ័យនិងបាលីសម្តែងនូវសេចក្តីសង្វេគ ។*

សូធ្យព្រមគ្នា

**ពុទ្ធោ សុសុទ្ធោ ករុណាមហណ្ណវោ,** *ព្រះពុទ្ធជាម្ចាស់*

ទ្រង់មានព្រះទ័យដ៏បរិសុទ្ធ, មានព្រះករុណាដូចជាអន្លង់ដ៏ធំ យោច្ចន្ត-សុទ្ធព្វរញ្ញាណលោចនោ, ទ្រង់មានព្រះនេត្រគឺញាណដ៏បរិសុទ្ធក្រៃពេក, លោកស្ស បាបូបកិលេសឃាតកោ, ទ្រង់កម្ចាត់[១] បង់នូវសេចក្តីអាក្រក់ជាគ្រឿងសៅហ្មងរបស់សត្វលោក, វន្ទាមិ ពុទ្ធំ អហមាទរេន តំ, ខ្ញុំក្រាបថ្វាយបង្គំនូវព្រះពុទ្ធជាម្ចាស់អង្គនោះដោយគោរព, ធម្មោ បទីបោ វិយ តស្ស សត្ថុនោ, ព្រះធម៌នៃព្រះសាស្តាអង្គនោះដូចជាប្រទីបដ៏រុងរឿង, យោ មគ្គបាកាម-តភេទភិន្នកោ, ជាធម៌ផ្សេងដោយប្រភេទ គឺមគ្គផល ព្រះនិព្វាន, លោកុត្តរោ យោ ច តទត្ថទីបនោ, និងជាធម៌បំភ្លឺនូវអត្ថនៃលោកុត្តរធម៌នោះ, វន្ទាមិ ធម្មំ អហមាទរេន តំ, ខ្ញុំក្រាបថ្វាយបង្គំនូវព្រះធម៌នោះដោយគោរព, សង្ឃោ សុខេត្តាភ្យតិខេត្ត-សញ្ញិតោ, ព្រះសង្ឃជាស្រែបុណ្យដ៏ល្អនិងឈ្មោះថាជាស្រែបុណ្យដ៏ប្រ-សើរលើស យោ ទិដ្ឋសន្តោ សុគតានុពោធកោ, បានឃើញធម៌ស្ងប់ហើយត្រាស់ដឹងតាមព្រះសុគត, លោលប្បហីនោ អរិយោ សុមេធសោ, ជាព្រះអរិយៈមានប្រាជ្ញាល្អ លះបង់គ្រឿងល្មោភអស់ហើយ, វន្ទាមិ សង្ឃំ អហមាទរេន តំ, ខ្ញុំក្រាបថ្វាយបង្គំនូវព្រះសង្ឃអង្គនោះដោយគោរព, ឥច្ចេវមេកន្តភិបូជនេយ្យកំ, វត្ថុត្តយំ វន្ទយតាភិសង្ខតំ, បុញ្ញំ មយា យំ មម

**សព្ពុបទ្ទវា, មា ហោន្តុ មេ តស្ស បការស្សិទ្ធិយា,** *បុណ្យណាដែលខ្ញុំបានធ្វើហើយដោយកិរិយាថ្វាយបង្គំ នូវប្រជុំបីនៃវត្ថុគួរបូជាដោយពិតយ៉ាងនេះ, ដោយអានុភាពនៃបុណ្យនោះ ឧបទ្រពចង្រៃទាំងពួងចូរកុំមានដល់ខ្ញុំឡើយ ។*

**៩ជ តថាគតោ លោកេ ឧប្បន្នោ,** *ព្រះតថាគតកើតឡើងហើយក្នុងលោកនេះ,* **អរហំ,** *ព្រះអង្គឆ្ងាយចាកកិលេសហើយ,* **សម្មាសម្ពុទ្ធោ,** *ព្រះអង្គត្រាស់ដឹងនូវព្រះធម៌ដ៏ប្រពៃដោយព្រះអង្គឯង,* **ធម្មោ ច ទេសិតោ,** *ព្រះធម៌ដែលព្រះអង្គទ្រង់សម្តែងហើយ,* **និយ្យានិកោ,** *ជាធម៌នាំសត្វចេញចាកសង្សារទុក្ខ,* **ឧបសមិកោ,** *ជាធម៌ប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់,* **បរិនិព្វានិកោ,** *ជាធម៌ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន,* **សម្ពោធគាមី,** *ជាធម៌ប្រព្រឹត្តទៅដើម្បីសេចក្តីត្រាស់ដឹង,* **សុគតប្បវេទិតោ,** *ព្រះសុគតទ្រង់ប្រកាសហើយ,* **មយន្តំ ធម្មំ សុត្វា ឯវំ ជានាម,** *យើងខ្ញុំបានស្តាប់ធម៌នោះហើយទើបដឹងយ៉ាងនេះថា,* **ជាតិបិ ទុក្ខា,** *សេចក្តីកើតក៏ជាទុក្ខ,* **ជរាបិ ទុក្ខា,** *សេចក្តីចាស់គ្រាំគ្រាក៏ជាទុក្ខ,* **មរណម្បិ ទុក្ខំ,** *សេចក្តីស្លាប់ក៏ជាទុក្ខ,* **សោកបរិទេវទុក្ខ-ទោមនស្សុបាយាសាបិ ទុក្ខា,** *សេចក្តីក្រៀមក្រំ យំរៀបរាប់*

លំបាកកាយ លំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្តក៏ជាទុក្ខ, **អប្បិយេហិ សម្បយោគោ ទុក្ខោ,** ការជួបប្រសព្វដោយសត្វនិងសង្ខារដែលមិនជាទីស្រឡាញ់ក៏ជាទុក្ខ, **បិយេហិ វិប្បយោគោ ទុក្ខោ,** ការព្រាត់ប្រាសចាកសត្វនិងសង្ខារដែលជាទីស្រឡាញ់ក៏ជាទុក្ខ, **យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ,** កាលប្រាថ្នារបស់ណាមិនបាន នោះក៏ជាទុក្ខ, **សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា,** ពោលដោយបំប្រួញឧបាទានក្ខន្ធទាំងប្រាំជាទុក្ខ, **សេយ្យថីទំ?** ឧបាទានក្ខន្ធទាំងប្រាំនោះដូចម្តេចខ្លះ? **រូបូបាទានក្ខន្ធោ,** ឧបាទានក្ខន្ធគឺរូប ១, **វេទនូបាទានក្ខន្ធោ,** ឧបាទានក្ខន្ធគឺវេទនា ១, **សញ្ញូបាទានក្ខន្ធោ,** ឧបាទានក្ខន្ធគឺសញ្ញា ១, **សង្ខារូបាទានក្ខន្ធោ,** ឧបាទានក្ខន្ធគឺសង្ខារ ១, **វិញ្ញាណូបាទានក្ខន្ធោ,** ឧបាទានក្ខន្ធគឺវិញ្ញាណ ១, **យេសំ បរិញ្ញាយ, ធរមានោ សោ ភគវា, ឯវំ ពហុលំ សាវកេ វិនេតិ,** ព្រះដ៏មានព្រះភាគអង្គនោះ, កាលគង់ព្រះជន្មនៅឡើយ, ទ្រង់ទូន្មាននូវសាវ័កទាំងឡាយ ដើម្បីឲ្យកំណត់ដឹងនូវឧបាទានក្ខន្ធទាំងប្រាំដោយច្រើន, **ឯវំ ភាគា ច បនស្ស ភគវតោ សាវកេសុ អនុសាសនី, ពហុលា បវត្តតិ,** ទាំងអនុសាសនី

ពាក្យប្រៀនប្រដៅដ៏ច្រើនរបស់ព្រះដ៏មានព្រះភាគអង្គនោះ, ក៏ប្រព្រឹត្តទៅក្នុងពួកសាវ័កយ៉ាងនេះថា, **រូបំ អនិច្ចំ**, រូបមិនទៀង, **វេទនា អនិច្ចា**, វេទនាមិនទៀង, **សញ្ញា អនិច្ចា**, សញ្ញាមិនទៀង, **សង្ខារា អនិច្ចា**, សង្ខារទាំងឡាយមិនទៀង, **វិញ្ញាណំ អនិច្ចំ**, វិញ្ញាណមិនទៀង, **រូបំ អនត្តា**, រូបមិនមែនខ្លួន, **វេទនា អនត្តា**, វេទនាមិនមែនខ្លួន **សញ្ញា អនត្តា** សញ្ញាមិនមែនខ្លួន, **សង្ខារា អនត្តា**, សង្ខារទាំងឡាយមិនមែនខ្លួន, **វិញ្ញាណំ អនត្តា**, វិញ្ញាណមិនមែនខ្លួន ។ **សព្វេ សង្ខារា អនិច្ចា**, សង្ខារទាំងឡាយទាំងពួងមិនទៀង ។ **សព្វេ ធម្មា អនត្តាតិ**, ធម៌ទាំងឡាយទាំងពួងមិនមែនខ្លួន ។ **{តេ[១] / តា} មយំ**, **ឱតិណ្ណាម្ហ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ**, យើងខ្ញុំទាំងឡាយនោះគឺសេចក្ដីកើត ចាស់ ស្លាប់, និងសេចក្ដីក្រៀមក្រំ យំរៀបរាប់ លំបាកកាយ លំបាកចិត្ត, និងសេចក្ដីចង្អៀតចង្អល់ចិត្ត គ្របសង្កត់ហើយ, **ទុក្ខោតិណ្ណា** ជាអ្នកគឺទុក្ខគ្របសង្កត់ហើយ **ទុក្ខបរេតា**, ជាអ្នកគឺទុក្ខបៀតបៀនហើយ, **អប្បេវនាមិមស្ស**

១- តេ សម្រាប់បុរសថា, តា សម្រាប់ស្ត្រីថា ។

**កោវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយា បញ្ញាយេថាតិ,** *ដូចម្តេចនឹងគប្បីធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះឲ្យប្រាកដបាន,* **ចិរ-បរិនិព្វុតម្បិ តំ ភគវន្តំ ឧទ្ទិស្ស អរហន្តំ សម្មាសម្ពុទ្ធំ, សទ្ធា អគារស្មា អនគារិយំ បព្វជិតា,** *យើងខ្ញុំមានសទ្ធាចេញចាកផ្ទះ, ហើយបួសជាអ្នកមិនមានផ្ទះ, ឧទ្ទិសចំពោះព្រះពុទ្ធជាម្ចាស់អង្គនោះ, ដែលព្រះអង្គឆ្ងាយចាកកិលេសហើយ, ត្រាស់ដឹងនូវព្រះធម៌ដ៏ប្រពៃដោយព្រះអង្គឯង, ទ្រង់ចែកធម៌ដល់សត្វទាំងឡាយ, សូម្បីទ្រង់បរិនិព្វានហើយអស់កាលដ៏យូរ,* **តស្មិំ ភគវតិ ព្រហ្ម-ចរិយំ ចរាម,** *ហើយប្រព្រឹត្តនូវព្រហ្មចរិយធម៌ក្នុងសំណាក់នៃព្រះដ៏មានព្រះភាគអង្គនោះ,* **ភិក្ខូនំ សិក្ខាសាជីវសមាបន្នា**[១] *ជាអ្នកដល់ព្រមហើយដោយសិក្ខានិងសាជីវៈរបស់ភិក្ខុទាំងឡាយ,* **តំ នោ ព្រហ្មចរិយំ, ឥមស្ស កោវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយាយ សំវត្តតុ,** *រីព្រហ្មចរិយធម៌នោះរបស់យើងខ្ញុំ, ចូរប្រព្រឹត្តទៅដើម្បីធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះ ។*

---

១- បើសាមណេរ សូធ្យមកដល់ ព្រហ្មចរិយំ ចរាម ត្រូវឈប់បង្អង់កុំសូធ្យ ថា ភិក្ខូនំ សិក្ខាសាជីវសមាបន្នា ត្រូវចាប់សូធ្យពី តំ នោ ព្រហ្មចរិយំ ទៅ ទល់និងចប់ ។

បើគ្រហស្ថ សូធ្យមកដល់បាលីថា **បញ្ញាយេថាតិ** ហើយ ត្រូវសូធ្យបន្តទៅទៀតដូច្នេះថា ៖

**ចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គតា, ធម្មញ្ច ភិក្ខុសង្ឃញ្ច,** *យើងខ្ញុំដល់ហើយនូវព្រះដ៏មានព្រះភាគអង្គនោះ, សូម្បីទ្រង់បរិនិព្វានហើយអស់កាលដ៏យូរ, ព្រមទាំងព្រះធម៌និងព្រះសង្ឃ ជាទីពឹង* **តស្ស ភគវតោ សាសនំ, យថាសត្តិ យថាពលំ មនសិករោម អនុបដិបជ្ជាម,** *ហើយយកចិត្តទុកដាក់បដិបត្តិតាម, នូវសាសនានៃព្រះដ៏មានព្រះភាគអង្គនោះ តាមសេចក្ដីអាចនិងកម្លាំង,* **សា សា នោ បដិបត្តិ,** *សេចក្ដីបដិបត្តិនោះៗរបស់យើងខ្ញុំ,* **ឥមស្ស កេវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយាយ សំវត្តតុ,** *ចូរប្រព្រឹត្តទៅដើម្បីធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះ ។*

*វត្តព្រឹកប្រែ ចប់តែប៉ុណ្ណោះ*

# ថ្វាយបង្គំព្រះរតនត្រ័យវត្តល្ងាច

## ប្រែ

*ឯវិធីថ្វាយបង្គំព្រះវត្តល្ងាច ក៏មានកិច្ចដែលត្រូវធ្វើជាខាងដើមដូចវិធីថ្វាយបង្គំព្រះវត្តព្រឹកដែរ, បើឧបាសកឧបាសិកា ត្រូវធ្វើកិច្ចទី ១ ទី ២ ទី ៣ ជាមុនសិន សឹមធ្វើកិច្ចទី ៤ គឺថ្វាយបង្គំព្រះវត្តល្ងាចតទៅ ។*

*បើភិក្ខុសាមណេរ ត្រូវធ្វើកិច្ចទី ២ ទី ៣ ជាមុនសិន សឹមធ្វើកិច្ចទី ៤ តទៅ ដូចន័យខាងក្រោមនេះ ៖*

## - កិច្ចថ្វាយបង្គំព្រះរតនត្រ័យវត្តល្ងាច

## ប្រែ

*មេនាំ សូធ្យបណាមវចនៈថា*

**ហន្ទ មយំ ពុទ្ធស្ស ភគវតោ បុព្វភាគនមការំ ករោម សេ,** *មុនដំបូងយើងទាំងឡាយ នមស្ការចំពោះព្រះដ៏មានព្រះភាគដែលព្រះអង្គត្រាស់ដឹងហើយ ។*

សូធ្យនមស្ការព្រមគ្នា

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**

*សូមនមស្ការចំពោះព្រះពុទ្ធជាម្ចាស់អង្គនោះ, ព្រះអង្គឆ្ងាយចាកកិលេសហើយ, ត្រាស់ដឹងនូវព្រះធម៌ដ៏ប្រពៃដោយព្រះអង្គឯង, ទ្រង់ចែកធម៌ដល់សត្វទាំងឡាយ*[១] ។

## ពុទ្ធានុស្សតិ

*មេនាំ សូធ្យថា*

**ហន្ទ មយំ ពុទ្ធានុស្សតិនយំ ករោម សេ,** *យើងទាំងឡាយនឹកព្រះពុទ្ធគុណ ។*

*សូធ្យព្រមគ្នា*

**តំ ខោ បន ភគវន្តំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ,** *រីកិត្តិស័ព្ទសរសើរព្រះដ៏មានព្រះភាគអង្គនោះ, ពីរោះខ្ទរខ្ទាយទៅយ៉ាងនេះថា* **ឥតិ បិ,** *ពិតដូច្នេះ,* **សោ ភគវា,** *រីព្រះដ៏មានព្រះភាគអង្គនោះ,* **អរហំ,** *ព្រះអង្គឆ្ងាយចាកកិលេសហើយ,* **សម្មាសម្ពុទ្ធោ,** *ព្រះអង្គត្រាស់ដឹងនូវព្រះធម៌ដ៏ប្រពៃដោយព្រះអង្គឯង,* **វិជ្ជាចរណសម្បន្នោ,** *ព្រះអង្គដល់ព្រមដោយវិជ្ជានិងចរណៈហើយ,* **សុគតោ,** *ព្រះអង្គយាងទៅប្រពៃហើយ,* **លោកវិទូ,** *ព្រះអង្គទ្រង់ជ្រាបច្បាស់នូវលោកហើយ,* **អនុត្តរោ**

---

១- កិច្ចនមស្ការនេះ បើបាលីនមោគួរសូធ្យ ៣ ដង, ឯសម្រាយនឹងសូធ្យតែម្ដងក៏គួរ ។

**បុរិសទម្មសារថិ,** *ព្រះអង្គទ្រង់ទូន្មាននូវបុរសដ៏គួរទូន្មានពុំមានអ្នកណាលើស,* **សត្ថា ទេវមនុស្សានំ,** *ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ,* **ពុទ្ធោ,** *ព្រះអង្គមានព្រះគុណរីកពេញហើយ,* **ភគវាតិ,** *ព្រះអង្គទ្រង់ចែកធម៌ដល់សត្វទាំងឡាយ ។*

ឈប់រំពឹងព្រះពុទ្ធគុណ

## ពាក្យសូធ្យសរសើរព្រះពុទ្ធគុណ

*មេនាំ សូធ្យថា*

**ហន្ទ មយំ ពុទ្ធាភិថុតឹ ករោម សេ,** *យើងទាំងឡាយសូធ្យគាថាសរសើរព្រះពុទ្ធគុណ ។*

*សូធ្យព្រមគ្នា*

**ពុទ្ធ្វារហន្តវរតាទិគុណាភិយុត្តោ,** *ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រកបដោយគុណ មានភាពជាព្រះអរហន្តដ៏ប្រសើរជាដើម,* **សុទ្ធាភិញាណករុណាហិ សមាគតត្តោ,** *ទ្រង់មានព្រះទ័យប្រកបដោយព្រះវិសុទ្ធិគុណ បញ្ញាគុណ និងករុណាគុណ,* **ពោធេសិ យោ សុជនតំ កមលំវ សូរោ,** *ទ្រង់ញ៉ាំងប្រជុំជនឲ្យត្រាស់ដឹងហើយ, ដូចព្រះអាទិត្យញ៉ាំងផ្កាឈូកឲ្យរីក,* **វន្ទាមហំ តមរណំ**

**សិរសា ជិនេន្ទំ**, *ខ្ញុំក្រាបថ្វាយបង្គំនូវព្រះពុទ្ធជាម្ចាស់អង្គនោះ, ព្រះអង្គជាធំជាងអ្នកឈ្នះមារមិនមានកិលេសជាសត្រូវដោយសិរសា*, **ពុទ្ធោ យោ សព្វចាណីនំ, សរណំ ខេមមុត្តមំ**, *ព្រះពុទ្ធជាម្ចាស់អង្គណាជាទីពឹងដ៏ក្សេមនិងឧត្តមរបស់សព្វសត្វទាំងឡាយ*, **បឋមានុស្សតិដ្ឋានំ, វន្ទាមិ តំ សិរេនហំ**, *ខ្ញុំក្រាបថ្វាយបង្គំនូវព្រះពុទ្ធជាម្ចាស់អង្គនោះ, ដែលជាទីតាំងនៃអនុស្សតិទីមួយដោយសិរសា*,

**ពុទ្ធស្សាហស្មិ { ទាសោ(១) / ទាសី } វ, ពុទ្ធោ មេ សាមិកិស្សរោ**,

*ខ្ញុំជា { ទាសៈ / ទាសី } នៃព្រះពុទ្ធជាម្ចាស់, ព្រះពុទ្ធជាម្ចាស់ជាធំរបស់ខ្ញុំ*,

**ពុទ្ធោ ទុក្ខស្ស ឃាតា ច, វិធាតា ច ហិតស្ស មេ**, *ព្រះពុទ្ធជាម្ចាស់ទ្រង់កម្ចាត់បង់នូវទុក្ខ ហើយធ្វើប្រយោជន៍ដល់ខ្ញុំ*, **ពុទ្ធស្សាហំ និយ្យាទេមិ, សរីរញ្ជីវិតញ្ចិទំ**, *ខ្ញុំប្រគល់កាយថ្វាយជីវិតនេះដល់ព្រះពុទ្ធជាម្ចាស់*, **{ វន្ទន្តោ(១) / វន្ទន្តី } ហំ ចរិស្សាមិ, ពុទ្ធស្សេវ សុពោធិតំ**, *ខ្ញុំនឹងប្រព្រឹត្តក្រាបថ្វាយបង្គំ, នូវសេចក្តី*

---

១- ទាសោ សម្រាប់បុរសថា, ទាសី សម្រាប់ស្ត្រីថា ។ ២- វន្ទន្តោ សម្រាប់បុរសថា វន្ទន្តី សម្រាប់ស្ត្រីថា ។

ត្រាស់ដឹងដោយប្រពៃនៃព្រះពុទ្ធជាម្ចាស់អង្គនោះ, នត្ថិ មេ សរណំ អញ្ញំ, ពុទ្ធោ មេ សរណំ វរំ, ទីពឹងដទៃរបស់ខ្ញុំមិនមាន, ព្រះពុទ្ធជាម្ចាស់ជាទីពឹងដ៏ប្រសើររបស់ខ្ញុំ, ឯតេន សច្ចវជ្ជេន, វឌ្ឍេយ្យំ សត្ថុ សាសនេ, ដោយការពោលនូវពាក្យសច្ចៈនេះ, សូមឲ្យខ្ញុំចម្រើនក្នុងសាសនានៃព្រះសាស្តា, ពុទ្ធំ

មេ វន្ទមា { នេន(១) / នាយ } យំ បុញ្ញំ បសុតំ ឥធ, បុណ្យណា

ដែលខ្ញុំបានហើយ, ដោយកិរិយាថ្វាយបង្គំនូវព្រះពុទ្ធជាម្ចាស់ក្នុងទីនេះ, សព្វេបិ អន្តរាយា មេ, មាហេសុំ តស្ស តេជសា, ដោយតេជះនៃបុណ្យនោះ, អន្តរាយទាំងឡាយទាំងពួងកុំកើតមានដល់ខ្ញុំឡើយ ។

គប្បីក្រាបចុះហើយសូធ្យតិចៗ ថា

កាយេន វាចាយ វ ចេតសា វា, ពុទ្ធេ កុកម្មំ បកតំ មយា យំ, អំពើអាក្រក់ណាដែលខ្ញុំធ្វើហើយដោយកាយវាចាចិត្តចំពោះព្រះពុទ្ធជាម្ចាស់, ពុទ្ធោ បដិគ្គណ្ហាតុ អច្ចយន្តំ, កាលន្តរេ សំវរិតុំ វ ពុទ្ធេ, សូមព្រះពុទ្ធជាម្ចាស់ទ្រង់ទទួលអត់នូវទោសនោះ, ដើម្បីនឹងសង្រួមក្នុងព្រះពុទ្ធជាម្ចាស់អស់កាលតរៀងទៅ ។

---

១- វន្ទមានេន សម្រាប់បុរសថា, វន្ទមានាយ សម្រាប់ស្ត្រីថា ។

# **ធម្មានុស្សតិ**

*មេនាំ សូធ្យថា*

**ហន្ទ មយំ ធម្មានុស្សតិនយំ ករោម សេ,** *យើង ទាំងឡាយនឹកព្រះធម្មគុណ ។*

*សូធ្យព្រមគ្នា*

**ស្វាក្ខាតោ ភគវតា ធម្មោ,** *ព្រះធម៌ដែលព្រះដ៏មានព្រះ ភាគទ្រង់សម្តែងប្រពៃហើយ,* **សន្ទិដ្ឋិកោ,** *ជាធម៌ដែលអ្នកបដិបត្តិ ឃើញច្បាស់ដោយខ្លួនឯង,* **អកាលិកោ,** *ជាធម៌ឲ្យផលពុំមាន កំណត់កាល,* **ឯហិបស្សិកោ,** *ជាធម៌មានអាការៈអាចហៅអ្នក ដទៃមកមើលបាន,* **ឱបនយិកោ,** *ជាធម៌គួរបង្អោនមកដាក់ក្នុង ចិត្តបាន,* **បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ,** *ជាធម៌ដែលអ្នកប្រាជ្ញ ទាំងឡាយគប្បីដឹងចំពោះខ្លួន ។*

ឈប់រំពឹងព្រះធម្មគុណ

## ពាក្យសរសើរព្រះធម្មគុណ

*មេនាំ សូធ្យថា*

**ហន្ទ មយំ ធម្មាភិគីតឹ ករោម សេ,** *យើងទាំងឡាយ សូធ្យគាថាសរសើរព្រះធម្មគុណ ។*

២៤

*សូធ្យព្រមគ្នា*

**ស្វាក្ខាតតាទិគុណយោគវសេន សេយ្យោ,** *ព្រះធម៌ដ៏ប្រសើរព្រោះប្រកបដោយគុណ, មានភាពជាធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងប្រពៃហើយជាដើម,* **យោ មគ្គបាកបរិយត្តិវិមោក្ខ-ភេទោ,** *ជាធម៌ផ្សេងគ្នាដោយបរិយត្តិមគ្គផលនិងព្រះនិព្វាន,* **ធម្មោ កុលោកបតនា តទធារិធារី,** *ជាធម៌ទ្រង់ទុកនូវអ្នកទ្រង់ធម៌មិនឲ្យធ្លាក់ទៅក្នុងលោកដ៏អាក្រក់,* **វន្ទាមហំ តមហរំ វរធម្មមេតំ** *ខ្ញុំក្រាបថ្វាយបង្គំនូវព្រះធម៌ដ៏ប្រសើរនោះ, ដែលជាធម៌កម្ចាត់បង់នូវងងឹត,* **ធម្មោ យោ សព្វបាណីនំ, សរណំ ខេមមុត្តមំ,** *ព្រះធម៌ណាជាទីពឹងដ៏ក្សេមនិងឧត្តមរបស់សព្វសត្វទាំងឡាយ,* **ទុតិយានុស្ស-តិដ្ឋានំ, វន្ទាមិ តំ សិរេនហំ,** *ខ្ញុំក្រាបថ្វាយបង្គំនូវព្រះធម៌នោះ, ដែលជាទីតាំងនៃអនុស្សតិទីពីរដោយសិរសា,* **ធម្មស្សាហស្មិ**

**ទាសោ**<br>**ទាសី** } **វ, ធម្មោ មេ សាមិកិស្សរោ,** *ខ្ញុំជា* { *ទាសៈ*<br>*ទាសី* } *នៃព្រះធម៌,*

*ព្រះធម៌ជាម្ចាស់ជាធំរបស់ខ្ញុំ,* **ធម្មោ ទុក្ខស្ស ឃាតា ច, វិធាតា ច ហិតស្ស មេ,** *ព្រះធម៌កម្ចាត់បង់នូវទុក្ខហើយធ្វើប្រយោជន៍ដល់ខ្ញុំ,* **ធម្មស្សាហំ និយ្យាទេមិ សរីរញ្ជីវិតញ្ចិទំ,** *ខ្ញុំប្រគល់កាយ*

*ថ្វាយជីវិតនេះដល់ព្រះធម៌,* **វន្ទន្តោ / វន្ទន្តី** **ហំ ចរិស្សាមិ, ធម្មស្សេវ សុធម្មតំ,** *ខ្ញុំនឹងប្រព្រឹត្តក្រាបថ្វាយបង្គំ, នូវសេចក្តីទ្រទ្រង់ដោយប្រពៃនៃព្រះធម៌នោះ,* **នត្ថិ មេ សរណំ អញ្ញំ, ធម្មោ មេ សរណំ វរំ,** *ទីពឹងដទៃរបស់ខ្ញុំមិនមាន, ព្រះធម៌ជាទីពឹងដ៏ប្រសើររបស់ខ្ញុំ* **ឯតេន សច្ចវជ្ជេន, វឌ្ឍេយ្យំ សត្ថុ សាសនេ,** *ដោយការពោលនូវពាក្យសច្ចៈនេះ, សូមឲ្យខ្ញុំចម្រើនក្នុងសាសនានៃព្រះសាស្តា,*

**ធម្មំ មេ វន្ទមា នេន / នាយ, យំ បុញ្ញំ បសុតំ ឥធ,** *បុណ្យណាដែលខ្ញុំបានហើយ, ដោយកិរិយាថ្វាយបង្គំនូវព្រះធម៌ក្នុងទីនេះ,* **សព្វេបិ អន្តរាយា មេ, មាហេសុំ តស្ស តេជសា,** *ដោយតេជៈនៃបុណ្យនោះ, អន្តរាយទាំងឡាយទាំងពួងកុំកើតមានដល់ខ្ញុំឡើយ ។*

គប្បីក្រាបចុះហើយសូធ្យតិច ៗ ថា

**កាយេន វាចាយ វ ចេតសា វា, ធម្មេ កុកម្មំ បកតំ មយា យំ,** *អំពើអាក្រក់ណាដែលខ្ញុំធ្វើហើយដោយកាយវាចាចិត្តចំពោះព្រះធម៌,* **ធម្មោ បដិគ្គណ្ហាតុ អច្ចយន្តំ, កាលន្តរេ សំវរិតុំ វ ធម្មេ,** *សូមព្រះធម៌ទទួលអត់នូវទោសនោះ, ដើម្បីនឹងសង្រួមក្នុងព្រះធម៌អស់កាលតរៀងទៅ ។*

# សង្ឃានុស្សតិ

*មេនាំ សូធ្យថា*

**ហន្ទ មយំ សង្ឃានុស្សតិនយំ ករោម សេ,** *យើងទាំងឡាយនឹកព្រះសង្ឃគុណ ។*

*សូធ្យព្រមគ្នា*

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ,** *ព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគលោកបដិបត្តិប្រពៃហើយ,* **ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ,** *ព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគលោកបដិបត្តិត្រង់ហើយ,* **ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ,** *ព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគលោកបដិបត្តិដើម្បីចេញចាកសង្សារទុក្ខហើយ,* **សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ,** *ព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគលោកបដិបត្តិសមគួរនឹងព្រះនិព្វានហើយ,* **យទិទំ,** *ព្រះសង្ឃសាវ័កអង្គនោះគឺ,* **ចត្តារិ បុរិសយុគានិ,** *បើរាប់ជាគូនៃបុរសមានបួនគូ,* **អដ្ឋ បុរិសបុគ្គលា,** *បើរាប់រៀងបុរសបុគ្គលមានប្រាំបី,* **ឯស ភគវតោ សាវកសង្ឃោ,** *នេះជាព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ,* **អាហុ-**

ឧនេយ្យោ, *លោកគួរទទួលរបស់ដែលគេនាំមកបូជា*, **ចាហុនេយ្យោ**, *លោកគួរទទួលរបស់ដែលគេនាំមកទទួលភ្ញៀវ*, **ទក្ខិណេយ្យោ**, *លោកគួរទទួលទក្ខិណាទាន*, **អញ្ជលិករណីយោ**, *លោកគួរទទួលអញ្ជលីប្រណម្យ*, **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ**, *លោកជាស្រែបុណ្យដ៏ប្រសើរលើសនៃសត្វលោក ។*

ឈប់រំពឹងព្រះសង្ឃគុណ

## ពាក្យសូធ្យសរសើរព្រះសង្ឃគុណ

*មេនាំ សូធ្យថា*

**ហន្ទ មយំ សង្ឃាភិកិត្តឹ ករោម សេ**, *យើងទាំងឡាយសូធ្យគាថាសរសើរព្រះសង្ឃគុណ ។*

*សូធ្យព្រមគ្នា*

**សទ្ធម្មជោ សុបដិបត្តិគុណាភិយុត្តោ**, *ព្រះសង្ឃកើតអំពីព្រះសទ្ធម្ម, ប្រកបដោយគុណមានសេចក្តីបដិបត្តិប្រពៃជាដើម*, **យោដ្ឋព្វិធោ អរិយបុគ្គលសង្ឃសេដ្ឋោ**, *ជាពួកព្រះអរិយបុគ្គលដ៏ប្រសើរទាំងប្រាំបី*, **សីលាទិធម្មបវរាសយកាយចិត្តោ**, *មានកាយនិងចិត្ត ជាទីអាស្រ័យនៅនៃព្រះធម៌ដ៏ប្រសើរមានសីលជាដើម*, **វន្ទាមហំ តមរិយានគណំ សុសុទ្ធំ**, *ខ្ញុំក្រាបថ្វាយបង្គំនូវព្រះ*

*សង្ឃអង្គនោះ, ដែលជាពួកនៃព្រះអរិយៈដ៏បរិសុទ្ធប្រពៃ,* **សង្ឃោ យោ សព្វចាណីនំ, សរណំ ខេមមុត្តមំ,** *ព្រះសង្ឃអង្គណា ជាទីពឹងដ៏ក្សេមនិងឧត្តមរបស់សព្វសត្វទាំងឡាយ,* **តតិយានុស្សតិដ្ឋានំ, វន្ទាមិ តំ សិរេនហំ,** *ខ្ញុំក្រាបថ្វាយបង្គំនូវព្រះសង្ឃអង្គនោះ, ដែលជាទីតាំងនៃអនុស្សតិទីបីដោយសិរសា,* **សង្ឃស្សាហស្មិ**

**ទាសោ** / **ទាសី** } **វ, សង្ឃោ មេ សាមិកិស្សរោ,** *ខ្ញុំជា* { *ទាសៈ* / *ទាសី*

*នៃព្រះសង្ឃ, ព្រះសង្ឃជាម្ចាស់ជាធំរបស់ខ្ញុំ,* **សង្ឃោ ទុក្ខស្ស ឃាតា ច, វិធាតា ច ហិតស្ស មេ,** *ព្រះសង្ឃកម្ចាត់បង់នូវទុក្ខ ហើយធ្វើប្រយោជន៍ដល់ខ្ញុំ,* **សង្ឃស្សាហំ និយ្យាទេមិ, សរីរញ្ជីវិតញ្ចិទំ,** *ខ្ញុំប្រគល់កាយថ្វាយជីវិតនេះដល់ព្រះសង្ឃ,* { **វន្ទន្តោ** / **វន្ទន្តី** } **ហំ ចរិស្សាមិ, សង្ឃស្សោបដិបន្នតំ,** *ខ្ញុំនឹងប្រព្រឹត្តក្រាបថ្វាយបង្គំនូវសេចក្តីបដិបត្តិដោយប្រពៃនៃព្រះសង្ឃអង្គនោះ,* **នត្ថិ មេ សរណំ អញ្ញំ, សង្ឃោ មេ សរណំ វរំ,** *ទីពឹងដទៃរបស់ខ្ញុំមិនមាន, ព្រះសង្ឃជាទីពឹងដ៏ប្រសើររបស់ខ្ញុំ,* **ឯតេន សច្ចវជ្ជេន, វឌ្ឍេយ្យំ សត្ថុ សាសនេ,** *ដោយការពោលនូវពាក្យសច្ចៈនេះ, សូមឲ្យខ្ញុំចម្រើន*

*ក្នុងសាសនានៃព្រះសាស្តា,* **សង្ឃំ មេ វន្ទមា** { **នេន** / **នាយ,** } **យំ បុញ្ញំ បសុតំ ឥធ,** *បុណ្យណាដែលខ្ញុំបានហើយ, ដោយកិរិយាថ្វាយបង្គំនូវព្រះសង្ឃក្នុងទីនេះ,* **សព្វេបិ អន្តរាយា មេ, មាហេសុំ តស្ស តេជសា,** *ដោយតេជះនៃបុណ្យនោះ, អន្តរាយទាំងឡាយទាំងពួងកុំកើតមានដល់ខ្ញុំឡើយ ។*

*ក្រាបចុះហើយសូធ្យតិច ៗ ថា*

**កាយេន វាចាយ វ ចេតសា វា, សង្ឃេ កុកម្មំ បកតំ មយា យំ,** *អំពើអាក្រក់ណាដែលខ្ញុំធ្វើហើយដោយកាយវាចាចិត្តចំពោះព្រះសង្ឃ* **សង្ឃោ បដិគ្គណ្ហាតុ អច្ចយន្តំ, កាលន្តរេ សំវរិតុំ វ សង្ឃេ,** *សូមព្រះសង្ឃទទួលអត់នូវទោសនោះ, ដើម្បីនឹងសង្រួមក្នុងព្រះសង្ឃអស់កាលតរៀងទៅ ។*

*វត្តល្វាចប្រែ ចប់តែប៉ុណ្ណោះ ។*

៣០

# គោតមកចេតិយធម្មបរិយាយ

**អភិញ្ញាយ ខោ សោ ភគវា, ធម្មំ ទេសេតិ នោ អនភិញ្ញាយ**, *ព្រះដ៏មានព្រះភាគអង្គនោះ, ទ្រង់សម្តែងធម៌ដើម្បីឲ្យដឹងច្បាស់, មិនមែនដើម្បីមិនឲ្យដឹងច្បាស់ឡើយ,* **សនិទានំ ធម្មំ ទេសេតិ នោ អនិទានំ**, *ទ្រង់សម្តែងធម៌ប្រកបដោយហេតុ, មិនមែនជាមិនប្រកបដោយហេតុឡើយ,* **សប្បាដិហារិយំ ធម្មំ ទេសេតិ នោ អប្បាដិហារិយំ**, *ទ្រង់សម្តែងធម៌ប្រកបដោយសេចក្តីអស្ចារ្យ, មិនមែនជាមិនប្រកបដោយសេចក្តីអស្ចារ្យឡើយ,* **តស្ស ខោ បន ភគវតោ**, *កាលបើព្រះដ៏មានព្រះភាគអង្គនោះ,* **អភិញ្ញាយ ធម្មំ ទេសយតោ នោ អនភិញ្ញាយ**, *ទ្រង់សម្តែងធម៌ដើម្បីឱ្យដឹងច្បាស់, មិនមែនដើម្បីមិនឲ្យដឹងច្បាស់ឡើយ,* **សនិទានំ ធម្មំ ទេសយតោ នោ អនិទានំ**, *ទ្រង់សម្តែងធម៌ប្រកបដោយហេតុ, មិនមែនជាមិនប្រកបដោយហេតុឡើយ,* **សប្បាដិហារិយំ ធម្មំ ទេសយតោ នោ អប្បាដិហារិយំ**, *ទ្រង់សម្តែងធម៌ប្រកបដោយសេចក្តីអស្ចារ្យ, មិនមែនជាមិនប្រកបដោយសេចក្តីអស្ចារ្យឡើយ,* **ករណីយោ ឱវាទោ**, *ឱវាទរបស់ព្រះអង្គគួរយើងធ្វើតាម,* **ករ-**

**ណីយា អនុសាសនី**, *អនុសាសនីរបស់ព្រះអង្គគួរយើងធ្វើតាម* **អលញ្ច បន នោ តុដ្ឋិយា**, *យើងទាំងឡាយគួរត្រេកអរ*, **អលំ អត្តមនតាយ**, *យើងទាំងឡាយគួររីករាយ*, **អលំ សោមនស្សាយ**, *យើងទាំងឡាយគួរសោមនស្សថា*, **សម្មាសម្ពុទ្ធោ ភគវា**, *ព្រះដ៏មានព្រះភាគព្រះអង្គត្រាស់ដឹងនូវព្រះធម៌ដ៏ប្រពៃដោយព្រះអង្គឯង*, **ស្វាក្ខាតោ ភគវតា ធម្មោ**, *ព្រះធម៌គឺព្រះដ៏មានព្រះភាគទ្រង់សម្ដែងប្រពៃហើយ*, **សុបដិបន្នោ សង្ឃោតិ**, *ព្រះសង្ឃលោកបដិបត្តិប្រពៃហើយ* ។

សីលុទ្ទេសបាឋ

**ភាសិតមិទំ តេន ភគវតា, ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន**, *ព្រះពុទ្ធជាម្ចាស់អង្គនោះ ព្រះអង្គឆ្ងាយចាកកិលេសហើយ, ត្រាស់ដឹងនូវព្រះធម៌ដ៏ប្រពៃដោយព្រះអង្គឯង, ទ្រង់ចែកធម៌ដល់សត្វទាំងឡាយ, កាលទ្រង់ជ្រាប ទ្រង់ឃើញ បានត្រាស់ទុកដូច្នេះថា* ៖

**សម្បន្នសីលា ភិក្ខវេ វិហរថ សម្បន្នបាតិមោក្ខា**, *ម្នាលភិក្ខុទាំងឡាយ, អ្នកទាំងឡាយចូរជាអ្នកបរិបូណ៌ដោយសីល បរិបូណ៌ដោយបាតិមោក្ខ*, **បាតិមោក្ខសំវរសំវុតា វិហរថ អាចារ-**

គោចរសម្បន្នា, *ចូរជាអ្នកសង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរ,* អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខថ សិក្ខាបទេសូតិ, *ចូរជាអ្នកឃើញភ័យក្នុងទោសយ៉ាងតូចហើយសមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ,* តស្មាតិហម្ហេហិ សិក្ខិតព្វំ, *ព្រោះហេតុនោះ ក្នុងសាសនានេះយើងទាំងឡាយគប្បីសិក្សាថា៖*

សម្បន្នសីលា វិហរិស្សាម សម្បន្នបាតិមោក្ខា, *យើងទាំងឡាយនឹងជាអ្នកបរិបូណ៌ដោយសីល បរិបូណ៌ ដោយបាតិមោក្ខ,* បាតិមោក្ខសំវរសំវុតា វិហរិស្សាម អាចារគោចរសម្បន្នា, *នឹងជាអ្នកសង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈ និងគោចរ,* អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខិស្សាម សិក្ខាបទេសូតិ, *នឹងជាអ្នកឃើញភ័យក្នុងទោសយ៉ាងតូច ហើយសមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ,* ឯវញ្ហិ នោ សិក្ខិតព្វំ, *យើងទាំងឡាយគប្បីសិក្សាយ៉ាងនេះឯង ។*

## មេត្តាភាវនា

អហំ សុខិតោ ហោមិ, *ខ្ញុំសូមជាអ្នកមានសេចក្ដីសុខ,*

**និទ្ទុក្ខា ហោមិ**, *សូមជាអ្នកមិនមានទុក្ខ*, **អវេរោ ហោមិ**, *សូមជាអ្នកមិនមានពៀរ*, **អព្យាបជ្ឈោ ហោមិ**, *សូមជាអ្នកមិនមានព្យាបាទ*, **អនីឃោ ហោមិ**, *សូមជាអ្នកមិនមានសេចក្តីចង្អៀតចង្អល់ចិត្ត*, **សុខី អត្តានំ បរិហរាមិ**, *សូមជាអ្នកមានសេចក្តីសុខរក្សានូវខ្លួន ។*

**សព្វេ សត្តា**, *សត្វទាំងឡាយទាំងពួង*, **សុខិតា ហោន្តុ**, *សូមជាអ្នកមានសេចក្តីសុខ*, **និទ្ទុក្ខា ហោន្តុ**, *សូមជាអ្នកមិនមានទុក្ខ*, **អវេរា ហោន្តុ**, *សូមជាអ្នកមិនមានពៀរ*, **អព្យាបជ្ឈា ហោន្តុ**, *សូមជាអ្នកមិនមានព្យាបាទ*, **អនីឃា ហោន្តុ**, *សូមជាអ្នកមិនមានសេចក្តីចង្អៀតចង្អល់ចិត្ត*, **សុខី អត្តានំ បរិហរន្តុ**, *សូមជាអ្នកមានសេចក្តីសុខរក្សានូវខ្លួន ។*

## ឧបេក្ខាភាវនា

**សព្វេ សត្តា**, *សត្វទាំងឡាយទាំងពួង* **កម្មស្សកា**, *មានកម្មជារបស់ខ្លួន*, **កម្មទាយាទា**, *ជាអ្នកទទួលនូវផលនៃកម្ម*, **កម្មយោនី**, *មានកម្មជាកំណើត*, **កម្មពន្ធូ**, *មានកម្មជាផៅពង្ស*, **កម្មបដិសរណា**, *មានកម្មជាទីពំនាក់អាស្រ័យ*, **យំ កម្មំ**

**ករិស្សន្តិ**, *នឹងធ្វើនូវកម្មណា*, **កល្យាណំ វា បាបកំ វា**, *ជាបុណ្យក្តីជាបាបក្តី*, **តស្ស ទាយាទា ភវិស្សន្តិ**, *នឹងជាអ្នកទទួលនូវផលនៃកម្មនោះ ។*

## អសុភភាវនា

**អយមេវ កាយោ**, *រីកាយនេះ*, **ឧទ្ធំ បាទតលា**, *ខាងលើអំពីបាតជើងឡើងទៅ*, **អធោ កេសមត្ថកា**, *ខាងក្រោមអំពីចុងសក់ចុះមក*, **តចបរិយន្តោ**, *មានស្បែកព័ទ្ធជុំវិញ*, **បូរោ នានប្បការស្ស អសុចិនោ**, *ដ៏ពេញដោយអាការៈមិនស្អាតមានប្រការផ្សេងៗ*, **អត្ថិ ឥមស្មឹ កាយេ**, *មានក្នុងកាយនេះគឺ*, **កេសា លោមា នខា ទន្តា តចោ**, *សក់ រោម ក្រចក ធ្មេញ ស្បែក*, **មំសំ នហារូ អដ្ឋី អដ្ឋិមិញ្ជំ វក្កំ**, *សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង ទាច*, **ហទយំ យកនំ កិលោមកំ បិហកំ បប្ផាសំ**, *បេះដូង ថ្លើម វាវ ក្រពះ សួត*, **អន្តំ អន្តគុណំ ឧទរិយំ ករីសំ**, *ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់*, **បិត្តំ សេម្ហំ បុព្វោ លោហិតំ សេទោ មេទោ**, *ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់*, **អស្សុ វសា ខេឡោ**

**សិង្ឃាណិកា លសិកា មុត្តន្តិ,** *ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសំបោរ ទឹករំអិល ទឹកមូត្រ ។*

## មរណស្សតិភាវនា

**អធុវំ មេ ជីវិតំ,** *សេចក្តីរស់នៅនៃយើងមិនទៀង,* **ធុវំ មរណំ,** *សេចក្តីស្លាប់ទៀង,* **អវស្សំ មយា មរិតព្វំ,** *យើងគង់ស្លាប់ដោយពិត,* **មរណាបរិយោសានំ មេ ជីវិតំ,** *សេចក្តីរស់នៅនៃយើងមានសេចក្តីស្លាប់ជាទីបំផុត,* **ជីវិតំ អធុវំ ធុវំ មរ-ណាន្តិ,** *សេចក្តីរស់នៅមិនទៀង សេចក្តីស្លាប់ទៀង ។*

## អភិណ្ហបច្ចវេក្ខណ

**ជរាធម្មោម្ហិ ជរំ អនតីតោ,** *យើងមានសេចក្តីចាស់ជរាជាធម្មតា, មិនកន្លងសេចក្តីចាស់ជរាទៅបានឡើយ,* **ព្យាធិធម្មោម្ហិ ព្យាធឹ អនតីតោ,** *យើងមានសេចក្តីឈឺចាប់ជាធម្មតា មិនកន្លងសេចក្តីឈឺចាប់ទៅបានឡើយ,* **មរណធម្មោម្ហិ មរណំ អនតីតោ,** *យើងមានសេចក្តីស្លាប់ជាធម្មតា, មិនកន្លងសេចក្តីស្លាប់ទៅបានឡើយ,* **សព្វេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ,** *យើងមានសេចក្តីព្រាត់ប្រាសចាកសត្វនិងសង្ខារ, ជាទី*

ស្រឡាញ់ជាទីគាប់ចិត្តទាំងពួង, **កម្មស្សកោម្ហិ**, យើងមានកម្មជារបស់ខ្លួន, **កម្មទាយាទោ**, ជាអ្នកទទួលនូវផលនៃកម្ម, **កម្មយោនិ**, មានកម្មជាកំណើត, **កម្មពន្ធុ**, មានកម្មជាផៅពង្ស **កម្មបដិស្សរណោ**, មានកម្មជាទីពំនាក់អាស្រ័យ, **យំ កម្មំ ករិស្សាមិ**, យើងនឹងធ្វើនូវកម្មណា, **កល្យាណំ វា បាបកំ វា**, ជាបុណ្យក្តី ជាបាបក្តី, **តស្ស ទាយាទោ ភវិស្សាមិ**, យើងនឹងជាអ្នកទទួលនូវផលនៃកម្មនោះ ។

## សំវេគវត្ថុបរិកិត្តនគាថា

**អចិរំ វតយំ កាយោ**, ឱកាយនេះមិនយូរសោះឡើយ, **បឋវឹ អធិសេស្សតិ**, នឹងដេកសង្កត់លើផែនដី, **ឆុឌ្ឌោ អបេតវិញ្ញាណោ**, មានវិញ្ញាណទៅប្រាសហើយបុគ្គលនឹងចោលនៅ, **និរត្ថំ វ កលិង្គរំ**, បីដូចជាអង្កត់ឧសរកប្រយោជន៍គ្មាន ។

**អនិច្ចា វត សង្ខារា**, ឱសង្ខារទាំងឡាយមិនទៀងសោះឡើយ, **ឧប្បាទវយធម្មិនោ**, មានសេចក្តីកើតឡើងនិងរលត់ទៅជាធម្មតា, **ឧប្បជ្ជិត្វា និរុជ្ឈន្តិ**, តែងកើតឡើងហើយរលត់ទៅ, **តេសំ វូបសមោ**, ការរម្ងាប់បង់នូវសង្ខារទាំងឡាយនោះ, **សុខោ** ជាទីនាំមកនូវសេចក្តីសុខ ។

**សព្វេ សត្តា**, *សត្វទាំងឡាយទាំងពួង*, **មរន្តិ ច**, *ស្លាប់ឥឡូវនេះផង*, **មរឹសុ ច**, *ស្លាប់ហើយផង*, **មរិស្សរេ**, *នឹងស្លាប់ឯមុខផង*, **តថេវាហំ មរិស្សាមិ**, *យើងនឹងស្លាប់ដូចសត្វទាំងឡាយនោះដែរ*, **ឯត្ថ មេ ឯត្ថ សំសយោ**, *សេចក្ដីសង្ស័យនៃយើងក្នុងរឿងស្លាប់នេះគ្មានឡើយ ។*

## ខេមាខេមស្សរណទីបិកាគាថា

**ពហុំ វេ សរណំ យន្តិ**, **បព្វតានិ វនានិ ច**, **អារាមរុក្ខចេត្យានិ**, **មនុស្សា ភយតជ្ជិតា**, *មនុស្សទាំងឡាយដ៏ច្រើនដែលភ័យគ្របសង្កត់ហើយ, រមែងយកភ្នំទាំងឡាយខ្លះព្រៃទាំងឡាយខ្លះ, អារាមនិងរុក្ខចេតិយទាំងឡាយខ្លះជាទីពឹង*, **នេតំ ខោ សរណំ ខេមំ**, **នេតំ សរណមុត្តមំ**, *នេះមិនមែនជាទីពឹងដ៏ក្សេមនិងមិនមែនជាទីពឹងដ៏ឧត្តម*, **នេតំ សរណមាគម្ម**, **សព្វទុក្ខា បមុច្ចតិ**, *អាស្រ័យនូវទីពឹងនេះហើយរមែងមិនរួចចាកទុក្ខទាំងពួង ។*

**យោ ច ពុទ្ធញ្ច ធម្មញ្ច**, **សង្ឃញ្ច សរណំ គតោ**, *លុះតែជនណាដល់ព្រះពុទ្ធព្រះធម៌ និងព្រះសង្ឃជាទីពឹង*, **ចត្តារិ អរិយ-**

សច្ចានិ, សម្មប្បញ្ញាយ បស្សតិ, *ហើយឃើញដោយប្រាជ្ញាដ៏ប្រពៃនូវអរិយសច្ចទាំងឡាយបួន,* ទុក្ខំ ទុក្ខសមុប្បាទំ, ទុក្ខស្ស ច អតិក្កមំ, *គឺទុក្ខ ១ តណ្ហាជាទីកើតឡើងនៃទុក្ខ ១, និងព្រះនិព្វានដែលកន្លងនូវទុក្ខ ១,* អរិយញ្ចដ្ឋង្គិកំ មគ្គំ, ទុក្ខូបសមគាមិនំ, *និងមគ្គមានអង្គប្រាំបីដ៏ប្រសើរ, ដែលជាផ្លូវទៅកាន់ព្រះនិព្វានជាទីរំលត់ទុក្ខ ១,* ឯតំ ខោ សរណំ ខេមំ, ឯតំ សរណមុត្តមំ, *នេះជាទីពឹងដ៏ក្សេម និងជាទីពឹងដ៏ឧត្តម,* ឯតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតីតិ, *អាស្រ័យនូវទីពឹងនេះហើយរមែងរួចចាកទុក្ខទាំងពួង ។*

## សច្ចកិរិយគាថា

នត្ថិ មេ សរណំ អញ្ញំ, *ទីពឹងដទៃរបស់ខ្ញុំមិនមាន,* ពុទ្ធោ មេ សរណំ វរំ, *ព្រះពុទ្ធជាម្ចាស់ជាទីពឹងដ៏ប្រសើររបស់ខ្ញុំ,* ឯតេន សច្ចវជ្ជេន, *ដោយការពោលនូវពាក្យសច្ចៈនេះ,* សោត្ថិ មេ ហោតុ សព្វទា, *សូមសួស្តីកើតមានដល់ខ្ញុំសព្វកាល ។*

នត្ថិ មេ សរណំ អញ្ញំ, *ទីពឹងដទៃរបស់ខ្ញុំមិនមាន,* ធម្មោ

មេ សរណំ វរំ, *ព្រះធម៌ជាទីពឹងដ៏ប្រសើររបស់ខ្ញុំ*, ឯតេន សច្ចវជ្ជេន, *ដោយការពោលនូវពាក្យសច្ចៈនេះ*, សោត្ថិ មេ ហោតុ សព្វទា, *សូមសួស្តីកើតមានដល់ខ្ញុំសព្វកាល* ។

នត្ថិ មេ សរណំ អញ្ញំ, *ទីពឹងដទៃរបស់ខ្ញុំមិនមាន*, សង្ឃោ មេ សរណំ វរំ, *ព្រះសង្ឃជាទីពឹងដ៏ប្រសើររបស់ខ្ញុំ*, ឯតេន សច្ចវជ្ជេន, *ដោយការពោលនូវពាក្យសច្ចៈនេះ* សោត្ថិ មេ ហោតុ សព្វទា, *សូមសួស្តីកើតមានដល់ខ្ញុំសព្វកាល* ។

## មហាការុណិកគាថា

មហាការុណិកោ នាថោ, អត្ថាយ សព្វបាណិនំ, បូរេត្វា បារមី សព្វា, បត្តោ សម្ពោធិមុត្តមំ, *ព្រះលោកនាថទ្រង់ប្រកបដោយករុណាដ៏ធំ, ទ្រង់បំពេញនូវបារមីទាំងពួង ដើម្បីប្រយោជន៍ដល់សព្វសត្វទាំងឡាយ, ហើយទ្រង់បានសម្រេចនូវសម្ពោធិញ្ញាណដ៏ឧត្តម*, ឯតេន សច្ចវជ្ជេន, មា ហោន្តុ សព្វុបទ្ទវា, *ដោយការពោលនូវពាក្យសច្ចៈនេះ សូមឧបទ្រពចង្រៃទាំងពួងកុំកើតមានឡើយ* ។

មហាការុណិកោ នាថោ, ហិតាយ សព្វបាណិនំ, បូរេត្វា បារមី សព្វា, បត្តោ សម្ពោធិមុត្តមំ, *ព្រះ*

*លោកនាថទ្រង់ប្រកបដោយករុណាដ៏ធំ, ទ្រង់បំពេញនូវបារមីទាំងពួងដើម្បីគុណដល់សព្វសត្វទាំងឡាយ, ហើយទ្រង់បានសម្រេចនូវសម្ពោធិញ្ញាណដ៏ឧត្តម,* **ឯតេន សច្ចវជ្ជេន, មា ហោន្តុ សព្វុបទ្ទវា,** *ដោយការពោលនូវពាក្យសច្ចៈនេះ, សូមឧបទ្រពចង្រៃទាំងពួងកុំកើតមានឡើយ ។*

**មហាការុណិកោ នាថោ, សុខាយ សព្វបាណិនំ, បូរេត្វា បារមី សព្វា, បត្តោ សម្ពោធិមុត្តមំ,** *ព្រះលោកនាថទ្រង់ប្រកបដោយករុណាដ៏ធំ, ទ្រង់បំពេញនូវបារមីទាំងពួងដើម្បីសេចក្តីសុខដល់សព្វសត្វទាំងឡាយ, ហើយទ្រង់បានសម្រេចនូវសម្ពោធិញ្ញាណដ៏ឧត្តម,* **ឯតេន សច្ចវជ្ជេន, មា ហោន្តុ សព្វុបទ្ទវា,** *ដោយការពោលនូវពាក្យសច្ចៈនេះ, សូមឧបទ្រពចង្រៃទាំងពួងកុំកើតមានឡើយ ។*

## បក្ខគណនាវិធានគាថា

**ឥទានិ ឆដ្ឋមីភូតេ, មហាន្តេយេវ សម្ពូហេ,** *ឥឡូវនេះមហាសម្ពូហៈទី ៦,* **ចតុត្ថស្សេវ ព្យូហស្ស, បញ្ចមេ សមុហេ អយំ,** *ព្យូហៈទី ៤ សមុហៈ ទី ៥,* **បឋមស្សេវ វគ្គស្ស, បក្ខោ បឋមសញ្ញិតេ,** *វគ្គទី ១ បក្ខបឋម,*

**បវត្តតិ បច្ចុប្បន្នោ, កាលោ កលិយុគលក្ខិតោតិ,**[១] *បច្ចុប្បន្នកាលដែលកំណត់ដោយកលិយុគ រមែងប្រព្រឹត្តទៅយ៉ាងនេះ ។*

**កាលោ ឃសតិ ភូតានិ, សព្វានេវ សហត្តនា,** *កាលតែងទំពាស៊ីនូវសត្វទាំងឡាយទាំងពួង មួយអន្លើដោយខ្លួនឯង,* **យោ ច កាលឃសោ ភូតោ, សភូតបចនឹ បចិ,** *បុគ្គលណាជាព្រះអរហន្តអ្នកស៊ីនូវកាល, បុគ្គលនោះបានដុតហើយនូវតណ្ហាដែលដុតនូវសត្វ ។* **អក្ខេយ្យសញ្ញិនោ សត្តា, អក្ខេយ្យស្មឹ បតិដ្ឋិតា,** *សត្វទាំងឡាយមានសេចក្ដីសម្គាល់ក្នុងខន្ធដែលគេសន្មតហៅ, ប្រតិស្ឋានហើយក្នុងខន្ធដែលគេសន្មតហៅ,* **អក្ខេយ្យមបរិញ្ញាយ, យោគមាយន្តិ មច្ចុនោតិ,** *ព្រោះតែមិនបានកំណត់ដឹងនូវខន្ធដែលគេសន្មតហៅ, ទើបមកកាន់ទីប្រកបការនៃមច្ចុរាជ ។*

*ចប់*

---

១ វិធីសូធ្យបក្ខគណនាវិធានគាថានេះ ត្រូវផ្លាស់ប្ដូរណាសំខ្យាទៅតាមកាលគឺ ថ្ងៃ-ខែ-ឆ្នាំ ដែលប្រព្រឹត្តកន្លងទៅជាលំដាប់ មានផ្លាស់ប័ក្ខរាល់កន្លះខែជាដើម ឯសេចក្ដីខាងលើនេះ គឺតម្រូវទៅតាមកាល គឺថ្ងៃ ១ ។ ៣ ឆ្នាំកុរត្រីស័ក ព-ស ២៥១៥ (១៦-១-១៩៧២) ។

# ទេវតាទិបត្តិទានគាថា

**អាកាសដ្ឋា ច ភុម្មដ្ឋា, ទេវា នាគា មហិទ្ធិកា,** *ទេវតាទាំងឡាយដែលឋិតនៅក្នុងអាកាសក្តី លើផែនដីក្តី, នាគទាំងឡាយដែលមានឫទ្ធិច្រើនក្តី,* **បុញ្ញំ តំ អនុមោទន្តុ, ចិរំ រក្ខន្តុ សាសនំ,** *សូមអនុមោទនានូវបុណ្យនោះ ហើយរក្សានូវព្រះពុទ្ធសាសនាអស់កាលដ៏យូរ ។*

**អាកាសដ្ឋា ច ភុម្មដ្ឋា, ទេវា នាគា មហិទ្ធិកា,** *ទេវតាទាំងឡាយដែលឋិតនៅក្នុងអាកាសក្តី លើផែនដីក្តី, នាគទាំងឡាយដែលមានឫទ្ធិច្រើនក្តី,* **បុញ្ញំ តំ អនុមោទន្តុ, ចិរំ រក្ខន្តុ រាជានោ,**[១] *សូមអនុមោទនានូវបុណ្យនោះ ហើយរក្សានូវព្រះរាជាទាំងឡាយអស់កាលដ៏យូរ ។*

**អាកាសដ្ឋា ច ភុម្មដ្ឋា, ទេវា នាគា មហិទ្ធិកា,** *ទេវតាទាំងឡាយដែលឋិតនៅក្នុងអាកាសក្តី លើផែនដីក្តី, នាគទាំងឡាយដែលមានឫទ្ធិច្រើនក្តី,* **បុញ្ញំ តំ អនុមោទន្តុ, ចិរំ រក្ខន្តុ មំ បរន្តិ,** *សូមអនុមោទនានូវបុណ្យនោះ ហើយរក្សានូវខ្ញុំនិងជនដទៃអស់កាលដ៏យូរ ។*

---

១- តាមសារាចរក្រសួងធម្មការលេខ ១ ក-ធ-ចុះថ្ងៃទី ១- ៣- ១៩៧១ បានកែរាជានោទៅជារដ្ឋកេវិញ ។ ដែលប្រែថា (នូវមហាជនក្នុងរដ្ឋទាំងឡាយឲ្យបានសុខចម្រើន) ។

## បត្តិទានគាថា

យង្កិញ្ចិ កុសលកម្មំ, កត្តព្វំ កិរិយំ មម, កាយេន វាចាមនសា, តិទសេ សុគតំ កតំ, *អំពើជាកុសលណាមួយដែលខ្ញុំគប្បីធ្វើដោយ កាយ វាចា ចិត្ត, គឺខ្ញុំធ្វើឲ្យជាអំពើគួរនាំទៅកើតក្នុងឋានតាវតិង្ស,* យេ សត្តា សញ្ញិនោ អត្ថិ, យេ ច សត្តា អសញ្ញិនោ, *សត្វទាំងឡាយណាមានសញ្ញាក្តី មិនមានសញ្ញាក្តី,* កតំ បុញ្ញផលំ មយ្ហំ, សព្វេ ភាគី ភវន្តុ តេ, *សូមសត្វទាំងឡាយទាំងពួងនោះបាននូវចំណែកផលនៃបុណ្យដែលខ្ញុំធ្វើហើយ,* យេ តំ កតំ សុវេទឹសុ[១], ទិន្នំ បុញ្ញផលំ មយា, *សត្វទាំងឡាយណាបានដឹងច្បាស់នូវអំពើជាកុសលនោះហើយ, សូមសត្វទាំងឡាយនោះបាននូវចំណែកផលនៃបុណ្យដែលខ្ញុំឲ្យហើយ,* យេ ច តត្ថ ន ជានន្តិ, ទេវា គន្ត្វា និវេទយុំ, *បើសត្វទាំងឡាយណាមិនដឹងច្បាស់ទេ, សូមទេវតាទាំង-ឡាយទៅប្រាប់សត្វទាំងឡាយនោះផង,* សព្វេ លោកម្ហិ យេ សត្តា, ជីវន្តាហារហេតុកា, *សត្វទាំងឡាយទាំងពួងណាក្នុងលោកដែលរស់នៅព្រោះអាហារ,* មនុញ្ញំ ភោជនំ សព្វេ, លភន្តុ

---

១- ក្នុងបាលីថា សុវិទិតំ ។

**មម ចេតសាតិ,** *សូមសត្វទាំងឡាយទាំងពួងនោះបាននូវភោជន ជាទីគាប់ចិត្ត, ដោយឧទ្ទិសចេតនារបស់ខ្ញុំ ។*

## ទេវតាទិបត្តិទានគាថា

**យា ទេវតា សន្តិ វិហារវាសិនី, ថូបេ ឃរេ ពោធិឃរេ តហឹ តហឹ,** *ទេព្តាទាំងឡាយដែលនៅក្នុងវិហារនាយ-រដ្ឋានព្រះថូបក្តី, នាយរដ្ឋានព្រះពោធិព្រឹក្សនិងក្នុងទីនោះៗ ក្តី,* **តា ធម្ម-ទានេន ភវន្តុ បូជិតា,** *ទេព្តាទាំងឡាយនោះ សូមបានទទួលនូវគ្រឿងបូជាដោយធម្មទាន,* **សោត្ថឹ ករោន្តេ វិហារមណ្ឌលេ,** *ហើយសូមធ្វើនូវសួស្តីក្នុងមណ្ឌលវិហារនេះ,* **ថេរា ច មជ្ឈា នវកា ច ភិក្ខវោ,** *ភិក្ខុទាំងឡាយដែលជាថេរៈក្តី កណ្តាលក្តី ទើបបួសថ្មីក្តី,* **សារាមិកា ទានបតី ឧបាសកា,** *ឧបាសក ឧបាសិកាទាំងឡាយដែលជាម្ចាស់ទាន ព្រមទាំងអារាមិកជនក្តី,* **គាមា ច ទេសា និគមា ច ឥស្សរា,** *អ្នកស្រុកអ្នកប្រទេសអ្នកនិគម និងឥស្សរជនក្តី,* **សប្បាណភូតា សុខិតា ភវន្តុ តេ,** *សូមជនទាំងឡាយនោះព្រមទាំងសត្វឯទៀតបាននូវសេចក្តីសុខ,* **ជលា-ពុជា យេបិ ច អណ្ឌសម្ភវា,** *សូម្បីសត្វទាំងឡាយណា ជាជលាពុជៈក្តី អណ្ឌជៈក្តី,* **សំសេទជាតា អថោបបាតិកា,**

ជាសំសេទជៈក្តី ឧបបាតិកៈក្តី, និយ្យានិកំ ធម្មវរំ បដិច្ចតេ, សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ, សូមសត្វទាំងឡាយនោះរួចចាកទុក្ខទាំងអស់គ្នា, ព្រោះអាស្រ័យនិយ្យានិកធម៌ដ៏ប្រសើរ, ឋាតុ ចិរំ សតំ ធម្មោ, ធម្មធរា ច បុគ្គលា, សូមព្រះសទ្ធម្ម និងបុគ្គលអ្នកទ្រង់ធម៌ទាំងឡាយ ឋិតនៅអស់កាលយូរ, សង្ឃោ ហោតុ សមគ្គោ វ, អត្ថាយ ច ហិតាយ ច, សូមព្រះសង្ឃព្រមព្រៀងគ្នា ដើម្បីប្រយោជន៍ ដើម្បីគុណ, អម្ហេ រក្ខតុ សទ្ធម្មោ, សព្វេបិ ធម្មចារិនោ, សូមព្រះសទ្ធម្មរក្សានូវយើងទាំងឡាយដែលប្រព្រឹត្តធម៌ទាំងអស់គ្នា, វុឌ្ឍឹ សម្បាបុណេយ្យាម, ធម្មេ អរិយប្បវេទិតេតិ, សូមយើងទាំងឡាយដល់នូវសេចក្តីចម្រើន, ក្នុងធម៌ដែលព្រះអរិយៈ សម្តែងហើយ ។

## បណិធានគាថា

ឥមិនា បុញ្ញកម្មេន, ដោយអំណាចបុញ្ញកម្មនេះផង, ឥមិនា ឧទ្ទិសេន ច, ដោយអំណាចនៃការឧទ្ទិសផលនេះផង, បញ្ចវេរានិ វជ្ជេយ្យំ, ខ្ញុំគប្បីវៀរផុតចាកវេរាទាំងប្រាំ, រមេយ្យំ សីលរក្ខណេ, គប្បីត្រេកអរតែក្នុងការរក្សាសីល, បញ្ច

**កាមេ អលគ្គោហំ**, *ខ្ញុំមិនគប្បីជាប់នៅក្នុងកាមគុណទាំងប្រាំឡើយ*, **វជ្ជេយ្យំ កាមបង្កតោ**, *គប្បីវៀរផុតចាកភក់គឺកាមគុណ*, **ទុទ្ទិដ្ឋិយា ន យុជ្ជេយ្យំ**, *ខ្ញុំមិនគប្បីប្រកបដោយទិដ្ឋិអាក្រក់ឡើយ*, **សំយុជ្ជេយ្យំ សុទិដ្ឋិយា**, *គប្បីប្រកបតែដោយទិដ្ឋិដ៏ល្អ*, **ចាបេ មិត្តេ ន សេវេយ្យំ**, *ខ្ញុំមិនគប្បីសេពគប់នូវមិត្តអាក្រក់ឡើយ*, **សេវេយ្យំ បណ្ឌិតេ សទា**, *គប្បីសេពគប់តែនឹងបណ្ឌិតសព្វកាល*, **សទ្ធាសតិហិរោត្តប្បា**, **តបខន្តិគុណាករោ**, *ខ្ញុំគប្បីប្រកបដោយគុណគឺ សទ្ធា ស្មារតី, សេចក្ដីខ្មាសខ្លើមបាប ខ្លាចបាប ព្យាយាមនិងខន្តី*, **អប្បសយ្ហោ វ សត្តូហិ**, *សត្រូវទាំងឡាយមិនគប្បីរឹបជាន់ខ្ញុំបានឡើយ*, **ហោយ្យំ អមន្ទមុយ្ហកោ**, *ខ្ញុំមិនគប្បីជាបុគ្គលល្ងង់វង្វេង*, **សព្វាយាចាយុចាយេសុ**, **ឆេកោ ជម្មត្ថកោវិទោ**, *ខ្ញុំគប្បីជាបុគ្គលឈ្លាសវៃក្នុងហេតុដែលនាំឲ្យចម្រើន និងហេតុដែលនាំឲ្យវិនាស, ព្រមទាំងឧបាយនិងហេតុផលទាំងពួង*, **ភវាភវេ សំសរន្តោ**, *កាលខ្ញុំអន្ទោលទៅក្នុងភពតូចនិងភពធំ*, **តេបិដកោ វិសារទោ**, *ខ្ញុំគប្បីឆ្លៀវឆ្លាតក្នុងព្រះបិដកទាំងបី*, **ជាតិស្សរោ មហាបញ្ញោ**, *ខ្ញុំគប្បីមានប្រាជ្ញាច្រើន អាចរលឹកនូវជាតិបាន*, **យាវ និព្វានមិជ្ឈតីតិ**, *ដរាបលុះសម្រេចព្រះនិព្វាន ។*

# វិធីឧបាសក-ឧបាសិកា

## វិធីសូមខមាទោស

អច្ចយោ មំ[១] ភន្តេ, អច្ចគមា, យថាពាលំ[២], យថាមុឡ្ហំ[៣], យថាអកុសលំ[៤] យោហំ / យាហំ[៥] ភន្តេ ជាតិតោ បដ្ឋាយ, បមាទំ វា អាគម្ម, អយោនិសោ, មនសិការំ វា អាគម្ម, កាយេន វា, វាចាយ វា, មនសា វា, ពុទ្ធេ វា, ធម្មេ វា, សង្ឃេ វា, អគារវំ

---

ឯវិធីសូមខមាទោសនិងវិធីថ្វាយខ្លួននេះ សម្រាប់តែគ្រហស្ថដែលចូលមកសុំធ្វើជា ឧបាសក-ឧបាសិកា ក្នុងព្រះពុទ្ធសាសនាជាដំបូង គប្បីធ្វើឲ្យប្រាកដក្នុងទីចំពោះមុខព្រះសង្ឃ, និងឧបាសកឧបាសិកាណា ដែលដាច់ព្រះត្រៃសរណគមន៍ក្តី សង្ស័យថាដាច់ក្តី សៅហ្មងក្តី គប្បីធ្វើជាថ្មី ដើម្បីឲ្យបានស្អាតបរិសុទ្ធផុតចាកទោស នឹងបានជា ឧបាសក ឧបាសិកា ពេញទីក្នុងព្រះពុទ្ធសាសនាឡើងវិញ ។

១- មំសម្រាប់មនុស្សម្នាក់ថា, បើមនុស្សច្រើនត្រូវថានោ។២-ពាលំសម្រាប់មនុស្សម្នាក់ថា, បើបុរសច្រើនត្រូវថាពាលេ, បើស្ត្រីច្រើនត្រូវថាពាលា ។ ៣- មុឡ្ហំ សម្រាប់មនុស្សម្នាក់ថា, បើបុរសច្រើនត្រូវថា មុឡ្ហេ, បើស្ត្រីច្រើនត្រូវថា មុឡ្ហា ។៤ អកុសលំ សម្រាប់មនុស្សម្នាក់ថា, បើបុរសច្រើនត្រូវថា អកុសលេ, បើស្ត្រីច្រើនត្រូវថា អកុស-លា ។ ៥- យោហំ សម្រាប់បុរសម្នាក់ថា, យាហំ សម្រាប់ស្ត្រីម្នាក់ថា, បើបុរសច្រើនត្រូវថាយេ មយំ, បើស្ត្រីច្រើនត្រូវថា, យា មយំ ។

**អកាវី[១], សម្មុខាបិ, បរម្មុខាបិ, សាធុ មេ[២] ភន្តេ សង្ឃោ, អច្ចយំ, អច្ចយតោ, បដិគ្គណ្ហាតុ, អាយតឹ សំវរាយ ។ ទុតិយម្បិ . . . ។ តតិយម្បិ . . . ។**

*បពិត្រព្រះសង្ឃដ៏ចម្រើន, វីទោសខុស, បានគ្របសង្កត់ហើយ, នូវខ្ញុំព្រះករុណា[៣], ដែលជាមនុស្សពាលយ៉ាងណា, ជាមនុស្សវង្វេងយ៉ាងណា, ជាមនុស្សមិនឈ្លាសយ៉ាងណា, បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណា, ចាប់ដើមតាំងពីកើតមក, អាស្រ័យហើយនូវសេចក្ដីប្រមាទខ្លះ, អាស្រ័យហើយនូវការមិនបានធ្វើទុកក្នុងចិត្ត ដោយឧបាយនៃប្រាជ្ញាខ្លះ, បានធ្វើហើយ នូវសេចក្ដីមិនគោរព ក្នុងព្រះពុទ្ធក្ដី, ក្នុងព្រះធម៌ក្ដី, ក្នុងព្រះសង្ឃក្ដី, ដោយកាយខ្លះ, ដោយវាចាខ្លះ, ដោយចិត្តខ្លះ, ចំពោះមុខខ្លះ, កំបាំងមុខខ្លះ, បពិត្រព្រះសង្ឃដ៏ចម្រើន, សូមព្រះសង្ឃ, ទទួលគឺអត់នូវទោសខុស, តាមទោសខុសនៃខ្ញុំព្រះករុណា ដើម្បីនឹងសង្រួម អស់កាលតរៀងទៅហោង ។*

---

១- **អកាវី** សម្រាប់មនុស្សម្នាក់ថា, បើមនុស្សច្រើនត្រូវថា **អកាវិម្ហា** ។ ២- មេ សម្រាប់មនុស្សម្នាក់ថា បើមនុស្សច្រើនត្រូវថានោ ។ ៣- បើតែម្នាក់ត្រូវថា ខ្ញុំព្រះករុណា, បើច្រើននាក់ត្រូវថា យើងខ្ញុំព្រះករុណា ។

## វិធីថ្វាយខ្លួន

**ឯសាហំ[១] ភន្តេ, សុចិរបរិនិព្វុតម្បិ, តំ ភគវន្តំ, សរណំ គច្ឆាមិ[២], ធម្មញ្ច, ភិក្ខុសង្ឃញ្ច, ឧបាសកំ[៣], មំ[៤] សង្ឃោ ធារេតុ, អជ្ជតគ្គេ, បាណុបេតំ[៥], សរណំ គតំ[៦], ។ ទុតិយម្បិ . . . ។ តតិយម្បិ . . . ។**

*បពិត្រព្រះសង្ឃដ៏ចម្រើន, ខ្ញុំព្រះករុណានេះ, សូមដល់នូវព្រះដ៏មានព្រះភាគអង្គនោះ, សូម្បីទ្រង់បរិនិព្វានហើយ, អស់កាលជាអង្វែង, នូវព្រះធម៌ផង, នូវព្រះសង្ឃផង, ជាទីពឹង, សូមព្រះសង្ឃចាំទុក, នូវខ្ញុំព្រះករុណា, ថាជាឧបាសក[៧], ដល់ហើយនូវព្រះត្រៃសរណគមន៍, ស្មើដោយជីវិត, ចាប់ដើមអំពីថ្ងៃនេះទៅហោង ។*

១- **ឯសាហំ** សម្រាប់មនុស្សម្នាក់ថា, បើបុរសច្រើនត្រូវថា **ឯតេ មយំ**, បើស្ត្រីច្រើនត្រូវថា **ឯតា មយំ** ។ ២- **គច្ឆាមិ** សម្រាប់មនុស្សម្នាក់ថា, បើមនុស្សច្រើនត្រូវថា **គច្ឆាម** ។ ៣- **ឧបាសកំ**, សម្រាប់បុរសម្នាក់ថា, បើស្ត្រីម្នាក់ត្រូវថា **ឧបាសិកំ**, បើបុរសច្រើនត្រូវថា **ឧបាសកេ**, បើស្ត្រីច្រើនត្រូវថា **ឧបាសិកាយោ** ។ ៤- មំ សម្រាប់មនុស្សម្នាក់ថា, បើមនុស្សច្រើនត្រូវថា **នោ** ។ ៥- ៦- **បាណុបេតំ**, **គតំ**, សម្រាប់បុរសឬស្ត្រីម្នាក់ថា, បើបុរសច្រើនត្រូវថា **បាណុបេតេ**, **គតេ** បើស្ត្រីច្រើនត្រូវថា **បាណុបេតា**, **គតា** ។ ៧- ឧបាសកសម្រាប់បុរសថា, បើស្ត្រីត្រូវថា ឧបាសិកា ។

# វិធីសមាទានសីលប្រែ

## ការសមាទាននិច្ចសីល និង សរណគមន៍

*ឯវិធីសមាទាននិច្ចសីលនិងព្រះត្រៃសរណគមន៍នេះ អ្នកសមាទានគប្បីធ្វើកិច្ចទី ១ ទី ២ ទី ៣ ឬទី ៤ តាមសមគួរដល់វេលា ឲ្យស្រេចជាមុនសិន សឹមសមាទានជាខាងក្រោយ ដោយបន្ទឹវាចានិងតាំងចេតនាឲ្យប្រាកដផង ដូចន័យខាងក្រោមនេះ ៖*

**អហំ(១) / មយំ } ភន្តេ, តិសរណេន សហ, បញ្ចង្គសមន្នាគតំ,**

**និច្ចសីលំ យាចា { មិ(២) / ម, ។** *បពិត្រព្រះករុណាដ៏ចម្រើន,*

*ខ្ញុំព្រះករុណា(៣) / យើងខ្ញុំព្រះករុណា } សុំនូវនិច្ចសីល, ដែលប្រកបដោយអង្គប្រាំប្រការ, ព្រមទាំងព្រះត្រៃសរណគមន៍(៤) ។*

*លោកអ្នកឲ្យ ត្រូវនាំសូធ្យនមស្ការព្រះរតនត្រ័យ សមាទានសរណគមន៍ សមាទានសីល ព្រមទាំងឲ្យឱវាទនិងប្រាប់អានិសង្សដូចតទៅនេះ៖*

---

១- **អហំ**, ២- **មិ**, ៣- ខ្ញុំព្រះករុណា សម្រាប់មនុស្សម្នាក់ថា, បើគ្នាច្រើនត្រូវថា មយំ, ម, យើងខ្ញុំព្រះករុណា ។ ៤- បាលីសមាទានសីលនិងសរណគមន៍ត្រូវសូធ្យបីដង ។

## នមស្ការព្រះរតនត្រ័យ

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស[១] ។**

*សូមនមស្ការចំពោះព្រះពុទ្ធជាម្ចាស់អង្គនោះ ព្រះអង្គឆ្ងាយចាកកិលេសហើយ, ត្រាស់ដឹងនូវព្រះធម៌ដ៏ប្រពៃដោយព្រះអង្គឯង, ទ្រង់ចែកធម៌ដល់សត្វទាំងឡាយ ។*

## សមាទានសរណគមន៍

**ពុទ្ធំ សរណំ គច្ឆាមិ,** *ខ្ញុំព្រះករុណាដល់នូវព្រះពុទ្ធជាទីពឹង,*
**ធម្មំ សរណំ គច្ឆាមិ,** *ខ្ញុំព្រះករុណាដល់នូវព្រះធម៌ជាទីពឹង,*
**សង្ឃំ សរណំ គច្ឆាមិ,** *ខ្ញុំព្រះករុណាដល់នូវព្រះសង្ឃជាទីពឹង ។*

**ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ,** *ខ្ញុំព្រះករុណាដល់នូវព្រះពុទ្ធជាទីពឹង អស់វារៈគម្រប់២ ដងផង,*
**ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ,** *ខ្ញុំព្រះករុណាដល់នូវព្រះធម៌ជាទីពឹង អស់វារៈគម្រប់២ ដងផង,*
**ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ,** *ខ្ញុំព្រះករុណាដល់នូវព្រះសង្ឃជាទីពឹង អស់វារៈគម្រប់ ២ ដងផង ។*

**តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ,** *ខ្ញុំព្រះករុណាដល់នូវព្រះពុទ្ធជាទីពឹង អស់វារៈគម្រប់៣ ដងផង,*

---

១- បាលីនមស្ការព្រះរតនត្រ័យ ត្រូវសូត្របីដង ឯសម្រាយនឹងសូត្រតែម្តងក៏គួរ

**តតិយម្បិ ធម្មំ សរណំ គច្ឆាមិ**, *ខ្ញុំព្រះករុណា ដល់នូវព្រះធម៌ ជាទីពឹង អស់វារៈគម្រប់៣ ដងផង*,

**តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ**, *ខ្ញុំព្រះករុណាដល់នូវ ព្រះសង្ឃជាទីពឹង អស់វារៈគម្រប់៣ ដងផង ។*

*(ទីបំផុតនេះ លោកអ្នកឲ្យ ត្រូវថា)* "**តិសរណាគមនំ និដ្ឋិតំ**, *ព្រះត្រៃសរណគមន៍ចប់ហើយ*" ។ *(អ្នកសមាទានត្រូវឆ្លើយថា)* "**អាម ភន្តេ** *ព្រះករុណា*" ។

## សមាទានសីល

១- **បាណាតិបាតា វេរមណីសិក្ខាបទំ សមាទិយាមិ**, *ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកសម្លាប់សត្វដោយខ្លួនឯង, និងប្រើអ្នកដទៃឲ្យសម្លាប់ ។*

២- **អទិន្នាទានា វេរមណីសិក្ខាបទំ សមាទិយាមិ**, *ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកលួចលាក់បំបាត់ទ្រព្យអ្នកដទៃដោយខ្លួនឯង, និងប្រើអ្នកដទៃឲ្យលួចលាក់បំបាត់ ។*

៣- **កាមេសុ មិច្ឆាចារា វេរមណីសិក្ខាបទំ សមាទិយាមិ**, *ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។*

៤- **មុសាវាទា វេរមណីសិក្ខាបទំ សមាទិយាមិ,** *ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកនិយាយកុហកអ្នកដទៃ ។*

៥- **សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ សមាទិយាមិ,** *ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ, គឺផឹកនូវសុរានិងមេរ័យ, ដែលជាគ្រឿងស្រវឹងផ្សេង ៗ ។*

## លោកអ្នកឲ្យ ត្រូវឲ្យឱវាទថា

**ឥមានិ បញ្ច សិក្ខាបទានិ និច្ចសីលវសេន សាធុកំ រក្ខិតព្វានិ,** *លោក-អ្នក គប្បីរក្សានូវសិក្ខាបទទាំងប្រាំនេះ, ឲ្យបានជានិច្ចសីលដ៏បរិសុទ្ធប្រពៃ ។ (អ្នកសមាទានត្រូវទទួលថា)* "**អាម ភន្តេ**, *ព្រះករុណា*" ។

## លោកអ្នកឲ្យ ត្រូវប្រាប់អានិសង្សថា

**សីលេន សុគតឹ យន្តិ,** *ជនទាំងឡាយ បានសុគតិដោយសារសីល,* **សីលេន ភោគសម្បទា,** *ជនទាំងឡាយបានភោគសម្ប័ទដោយសារសីល,* **សីលេន និព្វុតឹ យន្តិ,** *ជនទាំងឡាយបានព្រះនិព្វានដោយសារសីល,* **តស្មា សីលំ វិសោ-**

**ជយេ**, *ព្រោះហេតុនោះ គប្បីញ៉ាំងសីលឲ្យបរិសុទ្ធប្រពៃ ។*

*(អ្នកសមាទាន ត្រូវទទួលថា)* "**សាធុ**, *ប្រពៃហើយ*" ។

*លំដាប់អំពីនេះ អ្នកសមាទានសីលត្រូវសូត្រ* **កាយេន**..., *ទាំង ៣ ចប់, រួចហើយបើពុំមានកិច្ចអ្វីដែលត្រូវធ្វើបន្ទាប់ពីនោះទេ លោកអ្នកឲ្យសីលគប្បីអនុមោទនា គឺសូត្រ* **យថា**, **ភវតុ សព្វ**..., *លុះចប់អនុមោទនាហើយ អ្នកសមាទាន ត្រូវសូត្របត្តិទានគាថា គឺ* **អាកាសដ្ឋា**..., **យង្កិញ្ចិ**..., *ឬនឹងសូត្រ បណិធានគាថា គឺ* **ឥមិនា . . . ,** *ផងក៏បាន*

## ការសមាទានឧបោសថសីល និង សរណគមន៍

*ឯការសមាទានឧបោសថសីល និង សរណគមន៍នេះ អ្នកសមាទាន គប្បីធ្វើកិច្ចទី ១ ទី ២ ទី ៣ ឬ ទី ៤ តាមសមគួរដល់វេលាឲ្យស្រេចជាមុនសិន សឹមសមាទានជាខាងក្រោយ ដោយបន្ទឹវាចានិងតាំងចេតនាឲ្យប្រាកដផងដូចន័យខាងក្រោមនេះ ៖*

**អហំ** / **មយំ** } **ភន្តេ, តិសរណេន សហ, អដ្ឋង្គសមន្នាគតំ,**

**ឧបោសថំ យាចា** { **មិ**(១) / **ម** } ។ *បពិត្រព្រះករុណាដ៏ចម្រើន,*

---

១- បាលីសមាទានសីលនិងសរណគមន៍ ត្រូវសូត្របីដង ។

ខ្ញុំព្រះករុណា
យើងខ្ញុំព្រះករុណា } សុំនូវឧបោសថសីល ដែលប្រកបដោយអង្គប្រាំបី
ប្រការ, ព្រមទាំងព្រះរតនត្រ័យសរណគមន៍

លោកអ្នកឲ្យ គប្បីនាំសូធ្យនមស្ការព្រះរតនត្រ័យ និងសមាទានសរណគមន៍ ដូចក្នុងនិច្ចសីលដរាបដល់ចប់ ហើយគប្បីនាំសមាទាននូវឧបោសថសីល ដូចតទៅនេះ៖

១- **បាណាតិបាតា វេរមណីសិក្ខាបទំ សមាទិយាមិ,** ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកសម្លាប់សត្វដោយខ្លួនឯង, និងប្រើអ្នកដទៃឲ្យសម្លាប់ ។

២- **អទិន្នាទានា វេរមណីសិក្ខាបទំ សមាទិយាមិ,** ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកលួចលាក់បំបាត់ទ្រព្យអ្នកដទៃដោយខ្លួនឯង, និងប្រើអ្នកដទៃឲ្យលួចលាក់បំបាត់ ។

៣- **អព្រហ្មចរិយា វេរមណីសិក្ខាបទំ សមាទិយាមិ,** ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកសេពសមនូវមេថុនធម៌ ។

៤- **មុសាវាទា វេរមណីសិក្ខាបទំ សមាទិយាមិ,** ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកនិយាយកុហកអ្នកដទៃ ។

៥- **សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ**

**សមាទិយាមិ**, ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ, គឺផឹកនូវសុរានិងមេរ័យដែលជាគ្រឿងស្រវឹងផ្សេង ៗ ។

៦- **វិកាលភោជនា វេរមណីសិក្ខាបទំ សមាទិយាមិ**, ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកបរិភោគអាហារក្នុងវេលាខុស ។

៧- **នច្ចគីតវាទិតវិសូកទស្សនមាលាគន្ធវិលេបនធារណមណ្ឌន-វិភូសនដ្ឋានា វេរមណីសិក្ខាបទំ សមាទិយាមិ**, ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ គឺវៀរចាកច្រៀងរាំប្រគំតូរ្យតន្ត្រី, ព្រមទាំងមើលស្ដាប់ចម្រៀងរបាំតូរ្យតន្ត្រី, ដែលជាសត្រូវដល់កុសលធម៌, និងវៀរចាកប្រដាប់តាក់តែងរាងកាយ, ដោយកម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប និងគ្រឿងអលង្ការផ្សេង ៗ ។

៨- **ឧច្ចាសយនមហាសយនា វេរមណីសិក្ខាបទំ សមាទិយាមិ**, ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ គឺវៀរចាកទីដេក ទីអង្គុយដ៏ខ្ពស់, និងទីដេក ទីអង្គុយដ៏ធំនិងប្រសើរ ។

លោកអ្នកឲ្យ គប្បីនាំឲ្យធ្វើកាលបរិច្ឆេទថា

---

**ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ**

**ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ, សម្មទេវ អភិរក្ខិតុំ សមាទិ-យាមិ**, *ខ្ញុំព្រះករុណា សមាទាននូវឧបោសថ, ដ៏ប្រកបដោយអង្គប្រាំបីប្រការ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់បញ្ញត្តទុកមកនេះ, ដើម្បីរក្សាឲ្យបរិសុទ្ធបរិបូណ៌ប្រពៃ, កំណត់អស់ថ្ងៃមួយ យប់មួយមានវេលានេះជាដើម ។*

លោកអ្នកឲ្យ ត្រូវឲ្យឱវាទថា

**ឥមានិ អដ្ឋ សិក្ខាបទានិ, អជ្ជេកំ រត្តិន្ទិវំ, ឧបោសថ-សីលវសេន, តុម្ហេហិ**[១] **ឧបាសកឧបាសិកាភូតេហិ**[២] **សាធុកំ អខណ្ឌំ កត្វា អប្បមាទេន រក្ខិតព្វានិ**, *លោក-អ្នកជាឧបាសកឧបាសិកាទាំងឡាយ គប្បីរក្សានូវសិក្ខាបទទាំងប្រាំបីនេះ, ឲ្យបានជាឧបោសថសីលដ៏បរិសុទ្ធប្រពៃ, ដោយសេចក្តីមិនប្រមាទអស់ថ្ងៃនិងយប់នេះ កុំឲ្យដាច់និងសៅហ្មងឡើយ ។ (អ្នកសមា-ទានត្រូវទទួលថា)* " **អាម ភន្តេ**, *ព្រះករុណា* " ។

លោកអ្នកឲ្យ គប្បីប្រាប់អានិសង្សថា

**សីលេន សុគតឹ យន្តិ**, *ជនទាំងឡាយ បានសុគតិដោយ*

---

១- បើឧបាសក ឬឧបាសិកាតែម្នាក់ ត្រូវថា **តយា** ។

២-បើឧបាសកតែម្នាក់ថា **ឧបាសកភូតេន**, បើច្រើននាក់ថា **ឧបាសកភូតេហិ** បើឧបាសិកាតែម្នាក់ថា **ឧបាសិកាភូតាយ**, បើច្រើននាក់ថា **ឧបាសិកាភូតាហិ** ។

*សារសីល,* **សីលេន ភោគសម្បទា,** *ជនទាំងឡាយ បាន ភោគសម្ប័ទ ដោយសារសីល,* **សីលេន និព្វុតឹ យន្តិ,** *ជន ទាំងឡាយ បានព្រះនិព្វាន ដោយសារសីល,* **តស្មា សីលំ វិសោធយេ,** *ព្រោះហេតុនោះ គប្បីញ៉ាំងសីលឲ្យបរិសុទ្ធប្រពៃ ។ (អ្នកសមាទានត្រូវទទួលថា)* **សាធុ,** *ប្រពៃហើយ ។ (បើលោកអ្នក ឲ្យសីលនឹងប្រាប់អានិសង្សសីល ដោយពាក្យបាលី សម្រាយ ឲ្យបាន ច្រើនលើសនេះទៅទៀត ក៏រឹតតែប្រពៃ) ។*

*លំដាប់ពីនេះ អ្នកសមាទានសីលត្រូវសូត្រ* **កាយេន...** *ទាំង ៣ ចប់, រួចហើយបើពុំមានកិច្ចអ្វីដែលត្រូវធ្វើបន្ទាប់ពីនោះទេ លោកអ្នកឲ្យសីល, គប្បីអនុមោទនា គឺសូត្រ* **យថា... ភវតុ- សព្វ..,** *លុះចប់អនុមោទនាហើយ អ្នកសមាទាន ត្រូវសូធ្យបត្តិទាន- គាថាគឺ* **អាកាសដ្ឋា.., យន្ទិញ្ចិ..,** *ឬនឹងសូធ្យបណិធាន- គាថាគឺ* **ឥមិនា..,** *ផងក៏បាន ។*

<u>វិធីអារាធនាបរិត្ត</u>

*អាចារ្យគប្បីសូធ្យថា*

**វិបត្តិបដិពាហាយ, សព្វសម្បត្តិសិទ្ធិយា**
**សព្វទុក្ខវិនាសាយ, បរិត្តំ ព្រូថ មង្គលំ ។**

វិបត្តិបដិពាហាយ, សព្វសម្បត្តិសិទ្ធិយា,
សព្វភយវិនាសាយ, បរិត្តំ ព្រូថ មង្គលំ ។
វិបត្តិបដិពាហាយ, សព្វសម្បត្តិសិទ្ធិយា,
សព្វរោគវិនាសាយ, បរិត្តំ ព្រូថ មង្គលំ ។

## វិធីអារាធនាធម្មទេសនា

*អាចារ្យគប្បីសូធ្យថា*

ព្រហ្មា ច លោកាធិបតី សហម្បតិ
កតញ្ជលី អន្ធិវរំ អាយាចថ
សន្តីធ សត្តាប្បរជក្ខជាតិកា,
ទេសេតុ ធម្មំ អនុកម្បិមំ បជំ ។
ឯវញ្ហិ លោកាភិមតេន ព្រហ្មុនា,
អជ្ឈេសិតោ សោ ភគវា អនុត្តរោ,
សត្តេសុ ការុញ្ញត្តមោក្កមន្តតោ,
វោលោកយី លោកមិមំ សុចក្ខុនា ។
អទក្ខិ វេនេយ្យជនេ អនប្បកេ,
សន្តេវ លោកុត្តរពោធនារហេ,
វិញ្ញាបយេ អប្បរជក្ខជាតិកេ,

អថេវ មជ្ឈេសនមាជិវាសយិ ។
អបារុតា តេ អមតស្ស ទ្វារា,
យេ សោតវន្តោ បមុញ្ចន្តុ សទ្ធំ,
វិហឹសសញ្ញី បគុណំ ន ភាសឹ
ធម្មំ បណីតំ មនុជេសុ ព្រហ្មេ ។
តតោ មហាការុណិកោ មហេសី,
សម្ពុទ្ធកិច្ចំ ភគវា អកាសិ,
សទ្ធម្មចក្កស្ស បវត្តនាជី,
បវេសិ សោ សាសនធម្មសេដ្ឋំ ។
ធម្មេ ឥមំ មោចយិ ភព្វសត្តេ,
សំសារទុក្ខា ពហុកេបិ តេន,
សទ្ធម្មទីបំ តិវិធម្បិ លោកេ,
ហិតាយ សម្មា វ បវត្តយិត្វាតិ ។

ចាតុទ្ទសី បណ្ណរសី, យា ច បក្ខស្ស អដ្ឋមី,
កាលា ពុទ្ធេន បញ្ញត្តា, សទ្ធម្មស្សវនស្សិមេ ។
បណ្ណរសី[១]ខោ អយជ្ជាជិ, សម្បត្តា អភិលក្ខិតា,

១- បើថ្ងៃ ៨ កើត ៨ រោច ត្រូវថា អដ្ឋមី, បើថ្ងៃ ១៤ កើត ១៤ រោច ត្រូវថា ចាតុទ្ទសី, បើថ្ងៃ ១៥ កើត ១៥ រោច ត្រូវថា បណ្ណរសី ។

តេនាយំ បរិសា ធម្មំ, សោតុំ ឥធ សមាគតា ។
សាធុ អយ្យោ ភិក្ខុសង្ឃោ, ករោតុ ធម្មទេសនំ,
អយញ្ច បរិសា សព្វា, អដ្ឋិកត្វា សុណាតុ តំ ។

## វិធីវេរភត្តថ្វាយសង្ឃ

*ឯវិធីវេរភត្តថ្វាយសង្ឃនេះ មុនដំបូងពុទ្ធបរិស័ទគប្បីសូធ្យនមស្ការ* (នមោ...) *ព្រមគ្នា រួចហើយអាចារ្យគប្បីនាំសូធ្យវេរ មួយឃ្លា ឈប់បន្តិចម្តង ដើម្បីឲ្យបរិស័ទសូធ្យតាមគ្រប់ ៗ ឃ្លា ដែលមានកណ្តក-សញ្ញា* (,) *និងខណ្ឌ* (។) *ជាគ្រឿងសម្គាល់ ដូចន័យខាងក្រោមនេះ ៖*

អយំ ភោ ភន្តេ, បិណ្ឌចាតាភិហារោ, ធម្មិកោ ធម្មលទ្ធោ, ធម្មេនេវ, ឧប្បាទិតោ, មាតាបិតុអាទិកោ, គុណវន្តេ, ឧទ្ទិស្ស, ឥមំ, (សង្ឃភត្តំ)[១], សប្បរិវារំ, ឥធ ពុទ្ធប្បមុខស្ស, សង្ឃស្ស ទេម, តេ ឥមំ, អត្តនោ សន្តកំ វិយ, មញ្ញមានា, អនុមោទន្តុ, អនុមោ-ទិត្វា, យថិច្ឆិតសម្បត្តីហិ, សមិជ្ឈន្តុ, សព្វទុក្ខា, បមុញ្ចន្តុ, ឥមិនា និស្សន្ទេន ។ ទុតិយម្បិ . . . ។ តតិយម្បិ . . . ។

១- បើថ្វាយភត្តអ្វី គប្បីចេញឈ្មោះភត្តនោះ ។

បពិត្រព្រះសង្ឃដ៏ចម្រើន, រីអាហារបិណ្ឌបាត, នៃខ្ញុំព្រះករុណាទាំងឡាយ, ដែលនាំមកចំពោះនេះ, ប្រកបដោយធម៌, បានមកដោយធម៌, បង្កើតឡើងដោយធម៌, ខ្ញុំព្រះករុណាទាំងឡាយ, សូមឧទ្ទិសចំពោះ, ដល់លោកអ្នកដ៏មានគុណទាំងឡាយ, មានមាតាបិតាជាដើម, ហើយវេរថ្វាយ, នូវសង្ឃភត្ត[១] ព្រមទាំងបរិវារនេះ, ដល់ព្រះសង្ឃមានព្រះពុទ្ធរូបស្នងព្រះអង្គ, ជាប្រធានក្នុងទីនេះ, សូមលោកអ្នកដ៏មានគុណទាំងឡាយនោះ, សម្គាល់នូវសង្ឃភត្ត[២], ព្រមទាំងបរិវារនេះ, ថាដូចជារបស់នៃលោក, ហើយអនុមោទនា លុះអនុមោទនារួចហើយ, សូមសម្រេច, ដោយសម្បត្តិទាំងឡាយ, តាមដែលប្រាថ្នាចុះ, សូមរួចចាកទុក្ខទាំងពួង, ដោយផលានិសង្ស, ដែលហូរមកមិនដាច់នេះហោង ។

ចប់

---

១-២- បើវេរភត្តអ្វី គប្បីចេញឈ្មោះភត្តនោះតាមឈ្មោះភត្ត មានសង្ឃភត្ត, ឧទ្ទេសភត្ត, បក្ខិកភត្ត, និងសលាកភត្តជាដើម ដែលមានមកក្នុងបាលី ឬ អដ្ឋកថា ។

សៀវភៅវិធីថ្វាយបង្គំព្រះបាលី-ប្រែ ដែលបោះពុម្ពលើក ទី១ ទី២ ទី៣ ទី៤ ត្រូវកែតម្រូវតាមសៀវភៅលើកទី ៥ នេះ ។

# របៀបធ្វើមាឃបូជា

ទី ១- ថ្ងៃពេញបូណ៌មី នៃខែ មាឃ ពុទ្ធសាសនិកគួររៀបចំគ្រឿងសក្ការៈ បូជាចំពោះគុណព្រះរតនត្រ័យនៅព្រះវិហារ ឬកន្លែងដែលត្រូវធ្វើ អោយបានហើយជាស្រេចមុនពេលធ្វើ ។

ទី ២- មុននឹងធ្វើមាឃបូជា ត្រូវពុទ្ធបរិស័ទកាន់គ្រឿងសក្ការៈ ដើរប្រទក្សិណបីជុំព្រះវិហារ ឬកន្លែងដែលត្រូវធ្វើ "បើអាចធ្វើបាន" ដើម្បីគោរពចំពោះបូជនីយវត្ថុ ដែលមាននៅទីនោះ ។

ទី ៣- ប្រទក្សិណរួចហើយ ត្រូវចូលទៅក្នុងព្រះវិហារ ឬកន្លែងដែលត្រូវធ្វើនោះ ហើយគោរពដោយកាយទ្វារ និងថ្វាយគ្រឿងសក្ការៈ មានផ្កាភ្ញី ទៀន ធូបជាដើម ។

ទី ៤-ព្រះថេរៈមួយអង្គ ឬអាចារ្យមួយនាក់ ធ្វើពិធីប្រកាសមាឃបូជា ដោយពុទ្ធសាសនិកថាតាមផង បន្ទាប់មកព្រះថេរៈនាំព្រះសង្ឃ និងពុទ្ធបរិស័ទ សូត្រវិធីនមស្សការ ព្រះរតនត្រ័យសង្ខេប ឬពិស្តារតាមកាលវេលា ។ លុះនមស្សការរួចហើយ ត្រូវលោកអាចារ្យនាំឧបាសក ឧបាសិកា "អច្ចយោទោសថ្វាយខ្លួន" ចំពោះមុខព្រះសង្ឃ មានព្រះពុទ្ធរូបជាប្រធាន ព្រះសង្ឃត្រូវទទួលថា "សាធុ" ក្នុងពេលខមាទោស ថ្វាយខ្លួនចប់ ។ បន្ទាប់មកអាចារ្យនាំសមាទាន ត្រៃសរណគមន៍ និងសីលតទៅ ។

ទី៥- លោកអាចារ្យអារាធនាព្រះបរិត្ត រួចប្រកាសទេវតា ព្រះសង្ឃចម្រើនព្រះបរិត្តសង្ខេប ឬពិស្តារតាមការគួរ ។

ពេលចម្រើនព្រះបរិត្តចប់ ព្រះថេរៈនាំព្រះសង្ឃ ឧបាសក ឧបាសិកាសូត្រ "នមោ ៨ បទ" និងមាឃបូជា តាមរយៈនៃថ្ងៃនោះ ឬធម៌បទផ្សេង ៗ ទៀតជាបន្តបន្ទាប់ ដោយបទសរភញ្ញ ។

**សូមបញ្ជាក់:** កាលពីបុរាណ វិធីបុណ្យមាឃបូជាគឺ ធ្វើពីព្រលប់រហូតដល់ភ្លឺ ដូចនេះគួរពុទ្ធមាមិកជន យើងគួរធ្វើ យ៉ាងតិចម៉ោង ១២ យប់ដែរ ។

ជាកិច្ចបញ្ចប់ព្រះសង្ឃជូនពរជ័យ និងឧទ្ទិសកុសលផលបុណ្យ ថ្វាយប្រគេនជូនដល់បុព្វបុរសខ្មែរយើង ។

.................................................................................................................

ដោយមានការអនុញ្ញាត អំពីសម្តេចព្រះសង្ឃរាជ បួរ គ្រី **ព្រះធម្មត្រ័យលោកាចារ្យ ពុត សុភ័ក្ត្រ** បានដកស្រង់ និងសម្រួលខ្លះៗ ជាថ្មីឡើងវិញតាមច្បាប់ **សម្តេចព្រះសុគន្ធាសង្ឃរាជាធិបតី បញ្ញាសីលោ ចាន់** ដែលបាននិពន្ធទុកមកងាយចាត់ពិធីបុណ្យ មាឃបូជា អោយសមតាមប្រពៃណីព្រះពុទ្ធសាសនាជាតិខ្មែរយើង ។

# វិធីប្រកាសមាឃបូជា

(នមោ ៣.បទ សូត្រព្រមគ្នា)

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

សូមនមស្ការ ចំពោះព្រះភគវន្តមុនី អរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។

ថ្ងៃនេះ ជាតិថីពេញបូណ៌មី នៃខែមាឃ មានព្រះច័ន្ទពេញវង់ត្រូវនឹងថ្ងៃ នៃសាវកសន្និបាតរបស់ព្រះសក្យមុនី អរហន្តសម្មាសម្ពុទ្ធជាបរមគ្រូនៃយើង

សាវកសន្និបាតនោះ ប្រកបដោយអង្គ ៤ គឺ ថ្ងៃពេញបូណ៌មី ខែមាឃ ព្រះច័ន្ទចរចូលក្នុងមាឃនក្ខត្តឫក្ស នេះជាអង្គទី ១ ព្រះភិក្ខុសង្ឃ មានចំនួន ១ ២៥០ ឥតមានអ្នកណានិមន្ត ឬណាត់ពេលវេលាគ្នាសោះឡើយ ក៏ស្រាប់តែមកប្រជុំគ្នាក្នុងសំណាក់នៃព្រះបរមសាស្តា នាវត្តវេឡុវ័ន កលន្ទកនិវាបស្ថាន ក្រុងរាជគ្រឹះមគធរដ្ឋនៅវេលាថ្ងៃល្ងាច នេះជាអង្គទី ២ ព្រះភិក្ខុសង្ឃ ទាំង ១.២៥០អង្គនោះ សុទ្ធតែជាឯហិភិក្ខុ ដូចគ្នាទាំងអស់ នេះជាអង្គទី ៣ ព្រះភិក្ខុសង្ឃទាំង ១.២៥០ អង្គនោះ សុទ្ធតែជាខីណាស្រពទាំងអស់ នេះជាអង្គទី ៤ ព្រះសព្វញ្ញុពុទ្ធ ទ្រង់ត្រាស់សម្តែង នូវឱវាទបា្បតិមោក្ខក្នុងទីប្រជុំ នៃព្រះភិក្ខុសង្ឃនោះ ។ ការប្រជុំសាវ័កបែបនេះ ហៅថា "ចតុរង្គសន្និបាត" គឺជាការប្រជុំប្រកបដោយអង្គទាំង ៤ ក្នុងពុទ្ធកាលនៃព្រះសក្យមុនី បរមគ្រូរបស់យើង ទ្រង់មានព្រះជន្ម បើគិតតាមឈ្មោះខែ នៅខ្វះ ៤ខែ បើគិតតាមចំនួនថ្ងៃ នោះខ្វះតែ ៨៨ថ្ងៃទៀត នឹងគ្រប់ ៨០ឆ្នាំគត់ ព្រះអង្គទ្រង់កំណត់នូវព្រះជន្មាយុសង្ខារថា "ម្នាលភិក្ខុទាំងឡាយ គិតពីថ្ងៃនេះទៅនៅខ្វះតែ ៤ខែទៀតទេ តថាគតនឹងរំលត់ខន្ធ ចូលកាន់បរិនិព្វាន" ។ ការកំណត់ជន្មាយុនេះនៅថ្ងៃ ១៥ កើតខែមាឃដែរ ។ តិថីនេះជាឧបលក្ខិតសម័យមួយដ៏ឧត្តម ក្នុងព្រះពុទ្ធសាសនា គឺជាថ្ងៃសំរាប់ពុទ្ធមាមកជន ទាំងបព្វជិត ទាំងគ្រហស្ថ ប្រជុំគ្នាធ្វើសក្ការបូជាចំពោះព្រះសម្មាសម្ពុទ្ធអង្គនោះ ព្រមទាំងព្រះធម៌ ជាបរមពុទ្ធោវាទ និងព្រះអរិយ-សង្ឃ ជាសាវ័ករបស់ព្រះអង្គ ។

ឥឡូវនេះ យើងទាំងអស់គ្នា ជាពុទ្ធសាសនិកជន បានមកប្រជុំគ្នាបានរៀបគ្រឿងសក្ការបូជា មានទៀន ធូប និងផ្កាភ្ញីជាដើម ក្នុងទីនេះដែលមានព្រះពុទ្ធរូបស្នងព្រះអង្គ គង់ជាប្រធាន ហាក់ដូចជាព្រះបរមសាស្តាអង្គនោះ ទ្រង់ស្តេចមកគង់ ក្នុងទីចំពោះមុខ នៃយើងទាំងអស់គ្នា យើងខ្ញុំសូមថ្វាយនូវគ្រឿង

សក្ការបូជាទាំងនេះ ចំពោះព្រះសម្មាសម្ពុទ្ធ ព្រះអង្គនោះ ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ រតនត្រ័យទាំងបី ដោយសេចក្តីគោរព ។

បពិត្រព្រះសក្យមុនីបរមគ្រូ ព្រះអង្គជាបូជារហបុគ្គល របស់ទេវតា និងមនុស្សក្នុងលោកឥតមានបុគ្គលណាមួយ ត្រឹមស្មើនឹងព្រះអង្គឡើយ ទោះបីព្រះអង្គចូលបរិនិព្វាន បាត់ព្រះរូបព្រះកាយអស់កាលយូរអង្វែងទៅហើយ ក៏ពិតមែនប៉ុន្តែទ្រង់បានប្រតិស្ឋាន ព្រះវិសុទ្ធោវាទ គឺព្រះធម៌វិន័យដ៏បរិសុទ្ធវិសេស ទុកជាតំណាងព្រះអង្គ ទ្រង់ព្រះគុណរបស់ព្រះអង្គ ក៏នៅមានប្រាកដ ទាំងព្រះសារីរិកធាតុ និងព្រះពុទ្ធរូបស្នងព្រះអង្គ ក៏នៅមានប្រាកដដែរ សូមព្រះដ៏មានបុណ្យ ជាបរមសាស្តាទ្រង់ព្រះមេត្តាទទួលនូវគ្រឿងសក្ការបូជា របស់យើងខ្ញុំព្រះអង្គ ដែលរៀបចំថ្វាយក្នុងទីនេះ ដើម្បីជាផលានិសង្ស អោយយើងខ្ញុំព្រះអង្គ បានប្រកបដោយឥដ្ឋមនុញ្ញផល វិបុលសុខ និងសេចក្តីចម្រើន ដ៏ធំទូលាយ អស់កាលជាអង្វែងទៅហោង ។

.................................................................................................................

ព្រះសង្ឃ ឬអាចារ្យ ប្រកាសមួយសង្កាត់ម្តង ៗ អោយព្រះសង្ឃ និងបរិស័ទថាតាមផង (ធ្វើក្នុងវត្ត) បើធ្វើក្រៅវត្តថាតាមតែពុទ្ធបរិស័ទបានហើយ ។

# របៀបធ្វើវិសាខបូជា

ទី ១- ថ្ងៃពេញបូណ៌មី នៃខែវិសាខ ពុទ្ធសាសនិកគួររៀបចំគ្រឿងសក្ការៈបូជាចំពោះគុណព្រះរតនត្រ័យនៅព្រះវិហារ ឬកន្លែងដែលត្រូវធ្វើអោយបានហើយជាស្រេចមុនពេលធ្វើ ។

ទី ២- មុននឹងធ្វើវិសាខបូជា ត្រូវពុទ្ធបរិស័ទកាន់គ្រឿងសក្ការៈ ដើរប្រទក្សិណបីជុំព្រះវិហារ ឬកន្លែងដែលត្រូវធ្វើ "បើអាចធ្វើបាន" ដើម្បីគោរពចំពោះបូជនីយវត្ថុដែលមាននៅទីនោះ ។

ទី ៣- ប្រទក្សិណរួចហើយ ត្រូវចូលទៅក្នុងវិហារ ឬកន្លែងដែលត្រូវធ្វើនោះ ហើយគោរពដោយកាយទ្វារ និងថ្វាយគ្រឿងសក្ការៈ មានផ្កាភ្ញីទៀនធូបជាដើម ។

ទី ៤- ព្រះថេរៈមួយអង្គ ឬអាចារ្យមួយនាក់ ធ្វើពិធីប្រកាសវិសាខបូជាដោយពុទ្ធសាសនិក ថាតាមផង បន្ទាប់មកព្រះថេរៈ នាំព្រះសង្ឃ និងពុទ្ធបរិស័ទ សូត្រវិធីនមស្សការព្រះរតនត្រ័យសង្ខេប ឬពិស្តារទៅតាមកាលវេលា ។ លុះនមស្សការចប់ហើយត្រូវលោកអាចារ្យនាំឧបាសកឧបាសិកា "អច្ចយោទោសថ្វាយខ្លួន" ចំពោះមុខព្រះសង្ឃ មានព្រះពុទ្ធរូបជាប្រធាន ព្រះសង្ឃត្រូវទទួលថា "សាធុ" ក្នុងពេលខមាទោសថ្វាយខ្លួនចប់ ។ បន្ទាប់មកអាចារ្យនាំឮសមាទាន ត្រៃសរណគមន៍ និងសីលតទៅ ។

ទី ៥- លោកអាចារ្យអារាធនាព្រះបរិត្ត រួចប្រកាសទេវតា ព្រះសង្ឃចម្រើនព្រះបរិត្តសង្ខេប ឬពិស្តារតាមការគួរ ។

ពេលចម្រើនព្រះបរិត្តចប់ ព្រះថេរៈ នាំព្រះសង្ឃ ឧបាសកឧបាសិកាសូត្រ "នមោ ៨បទ" និងវិសាខបូជា តាមរយៈនៃថ្ងៃនោះៗ ឬធម៌បទផ្សេង ៗ ទៀតជាបន្តបន្ទាប់ ដោយបទសរភញ្ញ ។

បន្ទាប់មកទៀត លោកអាចារ្យ អារាធនាព្រះធម្មកថិក សម្តែងធម៌

ទេសនាដែលត្រូវតាមរឿងវិសាខបូជា និងបឋមសម្ពោធិកថា តាមការគួរដោយមានសូត្របទសរភញ្ញ តាមកណ្ឌនៃធម្មទេសនាផង ។

**សូមបញ្ជាក់ថា:** កាលពីបូរាណ វិធីបុណ្យវិសាខបូជាគឺ ធ្វើពីព្រលប់រហូតដល់ភ្លឺ ដូចនេះគួរពុទ្ធមាមកជនយើងគួរធ្វើយ៉ាងតិចម៉ោង ១២យប់ដែរ ។

ជាកិច្ចបញ្ចប់ ព្រះសង្ឃជូនពរជ័យ និងឧទ្ទិសកុសលផលបុណ្យ ថ្វាយប្រគេន ជូនដល់បុព្វបុរសខ្មែរយើង ។

..........................................................................................................

ដោយមានការអនុញ្ញាត អំពីសម្តេចសង្ឃរាជ **បួរ គ្រី**

**ព្រះធម្មត្រៃយលោកាចារ្យ ពុត សុភ័ក្រ្តិ៍** បានដកស្រង់ និងសំរួលខ្លះៗ ជាថ្មីឡើងវិញតាមច្បាប់ **សម្តេចព្រះសុគន្ធាសង្ឃរាជាធិបតី បញ្ញាសីលោ ចាន់** ដែលបាននិពន្ធទុកមកងាយស្រួលចាត់ពិធីបុណ្យវិសាខ-បូជា អោយសមតាមប្រពៃណីព្រះពុទ្ធសាសនាជាតិខ្មែរយើង ។

..........................................................................................................

ក្រសួងសម្តេចព្រះសង្ឃរាជអនុញ្ញាតអោយធ្វើបែបនេះ ។

# វិធីប្រកាសវិសាខបូជា

"ត្រូវព្រះសង្ឃ ឬឧបាសកម្នាក់ អានមួយសង្កាត់ម្តងៗ អោយព្រះសង្ឃ និងពុទ្ធស័ទថាតាមផង"

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

"នមោព្រមគ្នាបីដង"

"ក្រាបថ្វាយបង្គំម្តង"

ថ្ងៃនេះ ជាតិថីពេញបូណ៌មី នៃខែវិសាខ មានព្រះច័ន្ទពេញវង់ ត្រូវនឹងថ្ងៃដែលព្រះសក្យមុនី សម្មាសម្ពុទ្ធ ជាបរមគ្រូ ទ្រង់ប្រសូត្រ ទ្រង់បានត្រាស់ជាព្រះសព្វញ្ញុពុទ្ធ ប្រាកដឡើងក្នុងលោក និងថ្ងៃដែលរំលត់ខន្ធ ចូលកាន់បរិនិព្វាន តិថីនេះ ជាឧបលក្ខិតសម័យមួយដ៏ឧត្តម ក្នុងព្រះពុទ្ធសាសនា គឺជាថ្ងៃសម្រាប់ពុទ្ធមាមកជន ទាំងបព្វជិត ទាំងគ្រហស្ថ ប្រជុំគ្នាធ្វើសក្ការបូជាចំពោះព្រះសម្មាសម្ពុទ្ធព្រះអង្គនោះ ព្រមទាំងព្រះធម៌ ជាបរមពុទ្ធោវាទ និងព្រះអរិយសង្ឃ ជាសាវ័ករបស់ព្រះអង្គ ឥឡូវនេះ យើងទាំងអស់គ្នា ជាពុទ្ធសាសនិកជន បានមកប្រជុំគ្នា បានរៀបចំគ្រឿងសក្ការបូជា មានទៀនធូប និងផ្កាជាដើមក្នុងទីនេះ ដែលមានព្រះពុទ្ធរូបស្នងព្រះអង្គគង់ជាប្រធាន ហាក់ដូចជា ព្រះបរមសាស្តាអង្គនោះ ទ្រង់ស្តេចមកគង់ ក្នុងទីចំពោះមុខនៃយើងទាំងអស់គ្នា យើងខ្ញុំសូមថ្វាយនូវគ្រឿងសក្ការបូជាទាំងនេះ ចំពោះព្រះសម្មាសម្ពុទ្ធព្រះអង្គនោះ ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ រតនត្រ័យទាំងបី ដោយសេចក្តីគោរព ។

បពិត្រព្រះសក្យមុនីបរមគ្រូ ព្រះអង្គជាបូជារហបុគ្គល របស់ទេវតា និងមនុស្សលោក ឥតមានបុគ្គលណាមួយ ត្រឹមស្មើនឹងព្រះអង្គឡើយ ទោះបីព្រះអង្គទ្រង់ចូលបរិនិព្វាន បាត់ព្រះរូបព្រះកាយ អស់កាលអង្វែងទៅហើយ ក៏ពិតមែន ប៉ុន្តែទ្រង់បានប្រតិស្ថាន ព្រះវិសុទ្ធោវាទ គឺព្រះធម៌វិន័យ ដ៏បរិសុទ្ធវិសេស ទុកជាតំណាងព្រះអង្គ ទាំងព្រះគុណរបស់ព្រះអង្គ ក៏នៅមានប្រាកដ ទាំងព្រះបរមសារីរិកធាតុ និងព្រះពុទ្ធរូបស្នងព្រះអង្គ ក៏នៅមានប្រាកដដែរ សូមព្រះដ៏មានបុណ្យ ជាបរមសាស្តា ទ្រង់ព្រះមេត្តាប្រោសទទួល នូវគ្រឿងសក្ការបូជា របស់យើងខ្ញុំព្រះអង្គ ដែលបានរៀបចំថ្វាយក្នុងទីនេះ ដើម្បីជាផលានិសង្ស អោយយើងខ្ញុំព្រះអង្គ បានប្រកបដោយឥដ្ឋមនុញ្ញផល វិបុលសុខ និងសេចក្តីចម្រើន ដ៏

ទូលាយ    អស់កាលជាអង្វែងទៅហោង    ។

"ក្រាបថ្វាយបង្គំបីដង" ចប់វិធីប្រកាសវិសាខបូជា

# នមោ ៨ បទ

នមោ អរហតោ សម្មា    សម្ពុទ្ធស្ស មហេសិនោ
សូមថ្វាយបង្គំឆ្ពោះព្រះអរហន្ត    សម្ពុទ្ធភគវន្តកាលស្វែងរកធម៌
គឺពោធិញាណប្រសើរបវរ    បានត្រាស់ដឹងធម៌ដោយអរិយមគ្គ ។

នមោ ឧត្តមធម្មស្ស    ស្វាក្ខាតស្សេវ តេនិធ ។
សូមថ្វាយបង្គំព្រះធម៌ឧត្តម    ដែលព្រះបរមសម្ពុទ្ធសម្តែង
ដោយប្រពៃពិតប្រាកដជាក់ស្តែង    ព្រះធម៌នោះឯងទុកក្នុងសាសនា ។

នមោ មហាសង្ឃស្សាបិ    វិសុទ្ធសីលទិដ្ឋិនោ
សូមថ្វាយបង្គំព្រះសង្ឃប្រសើរ    ដែលលោកបានធ្វើទិដ្ឋិនិងសីល
អោយបានបរិសុទ្ធផុតចាកមន្ទិល    គឺទិដ្ឋិសីលលោកស្អាតអស់ហើយ ។

នមោ ឱមាត្យារទ្ធស្ស    រតនត្តយស្ស សាធុកំ ។
សូមថ្វាយបង្គំប្រជុំត្រ័យរត្ន    ប្រារព្ធដោយបទមានបីប្រការ
ព្រះពុទ្ធព្រះធម៌ព្រះសង្ឃឈ្នះមារ    ប្រសើរអស្ចារ្យថ្លឹងថ្លែងពុំបាន ។

នមោ ឱមកាតីតស្ស    តស្ស វត្ថុត្តយស្សបិ
សូមថ្វាយបង្គំភ្នំវត្ថុបី    ពិសេសពិសីប្រសើរថ្កើងថ្កាន
ព្រះពុទ្ធព្រះធម៌ព្រះសង្ឃសព្វឋាន    ថយឬកល្យាណដោយគុណគួរគាប់។

នមោ ការប្បភាវេន វិគច្ឆន្តុ ឧបទ្ទវា ។
សូមថ្វាយបង្គំត្រ័យរត្នសោភា ឧបទ្រពនានាចូរវិនាសបាត់
ដោយអានុភាពបុណ្យជួយកម្ចាត់ ធ្វើក្តីវិបត្តិអោយស្ងប់ស្ងូន្យទៅ ។

នមោ ការានុភាវេន សុវត្ថិ ហោតុ សព្វទា
សូមថ្វាយបង្គំត្រ័យរត្នទាំងបី សូមសុខសួស្តីកើតសព្វវេលា
ដោយអានុភាពធ្វើការវន្ទា គោរពបូជាឆ្ពោះព្រះត្រ័យរត្ន ។

នមោ ការស្ស តេជេន វិជិម្ហិ ហោមិ តេជវា ។
សូមថ្វាយបង្គំត្រ័យរត្នសោភា តេជះចេស្តាចូរមានដល់ខ្ញុំ
ក្នុងពិធីធ្វើកិច្ចថ្វាយបង្គំ តេជះបុណ្យធំសូមកើតមានឡើង ។

## វិធីសូត្រវិសាខបូជា

# ថ្ងៃពេញបូណ៌មី

វិសាខបុណ្ណមាយំ យោ ជាតោ អន្តិមជាតិយា
បត្តោ ច អភិសម្ពោធឹ អថោបិ បរិនិព្វុតោ ។
លោកេ អនុត្តរោ សត្ថា ទយាញាណានវាសយោ
នាយកោ មោក្ខមគ្គស្មឹ តិវិធត្ថូបទេសកោ ។
មហាការុណិកំ នាថំ មយន្តំ សរណំ គតា
អាមិសេហិ ច បូជេន្តា ធម្មេ ច បដិបត្តិយា ។
ឥមន្ទានិ សុនក្ខត្តំ អភិមង្គលសម្មតំ ។

# វិធីសូត្រមាឃបូជា
## ថ្ងៃពេញបូណ៌មី

មាឃនក្ខត្តយុត្តាយ បុណ្ណាយ បុណ្ណមាយំ យោ
អរហំ សម្មាសម្ពុទ្ធោ ភគវា គោតមវ្ហយោ ។
សុទ្ធានន្តនយោ ញាណោ សត្ថា លោកេ អនុត្តរោ
វិហរន្តោ រាជគហេ មកដានំ គិរិព្វជេ ។
វិហារេ វេឡុវនេ កលន្ទកនិវាបិយេ
សង្ឃស្ស សន្និបាតម្ហិ ឧត្តមេ ចតុរង្គិកេ ។
អឌ្ឍតេលសេហិ ភិក្ខុ សតេហិ បរិវារិតោ
តីហិ គាថាហិ សំខិប្ប សព្វំ ពុទ្ធានសាសនំ ។
សមោសារេហិ ឱវាទំ បាដិមោក្ខំ អនុត្តរំ
តមេវម្ហតសម្ពុទ្ធំ សវីណាសរសារកំ ។
ចិរកាលមតីតម្បិ បសាទេន អនុស្សរំ
អយម្បិ បរិសា សព្វា បសន្នា ធម្មគាមិនី ។
សម្បត្តា តាទិសំ កាលំ សុនក្ខត្តំ សុមង្គលំ
ទីបធូបាទិសក្ការេ អភិសជ្ជ យថាពលំ ។
តេហិ បូជេតវេហដ្ឋ តុដ្ឋា ឥធ សមាគតា
អភិវន្ទតិ បូជេតិ ភគវន្តំ សសាវកំ ។
កាលេន សម្មុខីភូតំ អតីតារម្មណត្តនា
ឱសារេន្តំ បាដិមោក្ខំ វិសុទ្ធត្ថមុបោសថេ ។

ឥតោ ជេន សុបុញ្ញេន សោត្ថិ ហោតុ សព្វទា ជោ
សាសនំ សត្ថុ អម្ហាកំ ចិរំ តិដ្ឋតុ តាទិនោតិ ។

## មាឃបូជាគាថា និដ្ឋិតំ

---

## ប្រែឃ្លោង ៧ ពាក្យ

ព្រះមានព្រះភាគអង្គឯណា ទ្រង់ព្រះនាមថាព្រះគោតម
កម្ចាត់កិលេសទាំងតូចធំ មិនអោយរួបរុំសន្ដាននៅ
ទ្រង់ត្រាស់ដឹងឯងដោយប្រពៃ ឥតគ្រូដទៃប្រៀនប្រដៅ
ទ្រង់មានចរិយាឥតហ្មងសៅ ករុណាឆ្ពោះទៅសត្វគ្រប់គ្នា
និងបញ្ញាគុណចាក់ធ្លុះធ្លាយ ជ្រៅឆ្ងាយទូលាយអនន្ដា
ព្រះអង្គជាគ្រូក្នុងលោកា ឥតមានគ្រូណាប្រៀបផ្ទឹមបាន
ទ្រង់គង់ក្នុងវត្តវេឡុវ័ន ជាទីកលន្ទនិវាស្ថាន
ជិតក្រុងរាជគ្រឹះដែនបុរាណ ដែលប្រាកដមានក្នុងមគធា
ភិក្ខុអរហន្ដដ៏ពណ្ណរាយ ពាន់ពីររយប្លាយហាសិបណា
ចូលទៅគង់គាល់នៅត្រៀបត្រា កបដោយនាថាដ៏ឧត្ដម
ហើយទើបព្រះអង្គទ្រង់សន្និបាត សម្ដែងឱវាទបាតិមោក្ខសម
ចំពោះភិក្ខុសង្ឃដ៏ឧត្ដម ដែលមកជួបជុំនៅពេលនោះ
ជាសាសនានៃព្រះពុទ្ធម្ចាស់ គ្រប់អង្គតែងត្រាស់ឥតមានមោះ
យ៉ាងខ្លីសង្ខេបល្អមពិរោះ ដោយគាថានោះតែបីបទ

ក្នុងថ្ងៃពេញបូណ៌មីមាឃា កបនក្ខត្តាល្អប្រាកដ
ហើយប្រជុំភិក្ខុកំណត់ ទ្រង់សម្តែងបទវិនយា

ជាច្បាប់សម្រាប់ភិក្ខុខ្វី ពោលគឺបាលីបាតិមោក្ខា
មានអត្ថបរិសុទ្ធដ៏ថ្លៃថ្លា សូត្រថ្ងៃឧបោសថាតាមវេណី

មួយទៀតកាលអង្គព្រះសុគត សម្រេចឥរិយាបថក្រុងវេសាលី
មានភិក្ខុចោមរោមជាប្រក្រតី ទ្រង់ប្រាប់សេចក្តីអោយដឹងដាន ។

ថានៅតែបីខែទៀតទេ ទ្រង់នឹងបែររេចូលនិព្វាន
បរិស័ទទាំងពួងយើងខ្ញុំមាន ក្តីប្រាថ្នាបានទាន់ធម៌គ្រប់

យើងខ្ញុំសូមលើកព្រះសម្ពុទ្ធ និងសង្ឃជាបុត្រខីណាស្រព
និព្វានកន្លងយូរថ្ងៃយប់ នឹកមិនមានឈប់ដោយជ្រះថ្លា

យើងខ្ញុំបានដល់នក្ខត្តឫក្ស មង្គលអ៊ឹកៈធឹកធំណាស់សា
បាននាំគ្នាធ្វើសក្ការា ទៀនធូបជាអាទិ៍តាមប្រឹងប្រែង ។

យើងខ្ញុំមានចិត្តត្រេកអរីករាយ ជួបជុំខ្វល់ខ្វាយទីនេះឯង
ដើម្បីសក្ការៈតាក់តែង បូជាកោតក្រែងដោយផ្ចិតផ្ចង់

សូមថ្វាយបង្គំសូមបូជា ឆ្ពោះព្រះភគវាសាវ័កសង្ឃ
តាមកាលឆ្ពោះភក្ត្រនៃព្រះអង្គ និព្វានយូរលង់នោះហើយក្តី

កាលដែលសម្តែងព្រះបាតិមោក្ខ ខែមាឃមានជោគបុណ្ណមី
ព្រះចន្ទចាំងចែងរឿងរង្សី ឧបោសថពិសីបរិសុទ្ធា

ដោយបុណ្យបូជាតាមសទ្ធា　　សួស្តីសោភាមានគ្រប់គ្រា
សាសនាសាស្តាយើងរាល់គ្នា　　ចុំចេ្រីងចិរាយុអវង្វែង ។
( បុរាណភាសិត ចប់ )

## ពាក្យសូត្រថ្វាយសក្ការៈក្នុង
## ថ្ងៃវិសាខបូជា

យមម្ហ ខោ មយំ ភគវន្តំ សរណំ គតា យោ នោ ភគវា សត្ថា យស្ស ច មយំ ភគវតោ ធម្មំ រោចេម ។ អហោសិ ខោ សោ ភគវា មជ្ឈិមេសុ ជនបទេសុ អរិយកេសុ មនុស្សេសុ ឧប្បន្នោ ខត្តិយោ ជាតិយា គោតមោ គោត្តេន សក្យបុត្តោ សក្យកុលា បព្វជិតោ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ និស្សំសយំ ខោ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា ។ ស្វាក្ខាតោ ខោ បន តេន ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហិ ។ សុបដិបន្នោ ខោ បនស្ស ភគវតោ សាវកសង្ឃោ ឧជុបដិបន្នោ ញាយបដិបន្នោ សាមីចិបដិបន្នោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ។

ចប់

ថូបោ
អយំ ខោ បន } តំ ភគវន្តំ
បដិមា

កតោ
ឧទ្ទិស្ស } យាវទេវ ទស្សនេន
កតា

តំ ភគវន្តំ អនុស្សរិត្វា បសាទសង្វេគបដិលាភាយ មយំ ខោ ឯតរហិ ឥមំ វិសាខបុណ្ណមីកាលំ តស្ស ភគវតោ ជាតិ-សម្ពោធិនិព្វានកាលសម្មតំ បត្វា ឥមំ ឋានំ សម្បត្តា ឥមេ ទណ្ឌទីបធូបបុប្ផាទិសក្ការេ គហេត្វា អត្តនោ កាយំ សក្ការូបធានំ ករិត្វា តស្ស ភគវតោ យថាភុច្ចេ គុណេ

ថូបំ
អនុស្សរន្តា ឥមំ } តិក្ខត្តុំ បទក្ខិណំ
បដិមំ

ករិស្សាម យថា គហិតេហិ សក្ការេហិ បូជំ កុរុមានា សាធុ នោ ភន្តេ ភគវា សុចិរបរិនិព្វុតោបិ ញាតព្វេហិ គុណេហិ អតីតារម្មណតាយ បញ្ញាយមានោ ឥមេ អម្ហេហិ គហិតេ សក្ការេ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ ហិតាយ សុខាយ ។

# សេចក្តីប្រែ

យើងខ្ញុំទាំងឡាយ ដល់ហើយនូវព្រះដ៏មាន ព្រះភាគឯណា ជាទីពឹង ទីរលឹក ព្រះដ៏មានព្រះភាគឯណាជាគ្រូនៃយើងខ្ញុំទាំងឡាយ យើងខ្ញុំទាំងឡាយ គាប់ចិត្តធម៌របស់ព្រះដ៏មានព្រះភាគឯណា ។ ព្រះដ៏មានព្រះភាគនោះ ព្រះអង្គ កើតហើយក្នុងមនុស្សពួកអរិយកៈ ក្នុងមជ្ឈិមជនបទ ព្រះអង្គជាក្សត្រិយ៍ដោយជាតិ ជាវង្សខ្ពស់ដោយគោត្រ ជាសក្យបុត្រ ស្តេចចេញចាកសក្យត្រកូល ទ្រង់បួស ហើយ ព្រះអង្គត្រាស់ដឹងឯងក្រៃពេកហើយនូវសម្មាសម្ពោធិញាណ មិនមានសេចក្តី ត្រាស់ដឹងដទៃប្រសើរជាងឡើយ មិនមានសេចក្តីសង្ស័យឡើយ ។ រីព្រះដ៏មាន ព្រះភាគនោះ ព្រះអង្គឆ្ងាយចាកកិលេស ត្រាស់ដឹងឯងប្រពៃហើយ ដល់ព្រម ដោយវិជ្ជា បញ្ញាត្រាស់ដឹងច្បាស់ និងចរណៈផ្លូវបដិបត្តិគ្រឿងដំណើរដល់នូវវិជ្ជា នោះបរិបូណ៌ ស្តេចយាងទៅប្រពៃហើយ ទ្រង់ជ្រាបច្បាស់នូវលោកប្រាកដហើយ ជាសារថីទូន្មាននូវបុរសដ៏គួរទូន្មានមិនមានអ្នកឯណាលើសបានឡើយ ជាគ្រូនៃ ទេវតានិងមនុស្សទាំងឡាយ ទ្រង់បំពេញពុទ្ធកិច្ចពេញបរិបូណ៌ហើយ ។

ព្រះធម៌ដែលព្រះដ៏មានព្រះភាគនោះ ទ្រង់សម្តែងទុកប្រពៃហើយ ជា ធម៌ដែលអ្នកបដិបត្តិអាចឃើញឯង ជាធម៌អោយផលមិនមានកំណត់កាលវេលា ជាធម៌មានអាការបីដូចជានឹងហៅអ្នកដទៃមកមើលផងបាន ជាធម៌គួរបង្អោនមក ទុកដាក់ក្នុងចិត្តបាន ជាធម៌ដែលវិញ្ញូជនគប្បីដឹងចំពោះខ្លួនបាន ។

ព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគនោះ លោកបដិបត្តិល្អហើយ បដិបត្តិត្រង់ហើយ បដិបត្តិដើម្បីចេញចាកវដ្តទុក្ខហើយ បដិបត្តិសមគួរនឹងព្រះ និព្វានហើយ ព្រះសង្ឃសាវ័កនោះមាន៤គូ បើរាប់រៀងបុរសបុគ្គលបាន ៨

ស្តូប
រីឯព្រះ } នេះអ្នកប្រាជ្ញបានសាងឡើងឧទ្ទិសចំពោះព្រះដ៏មាន
បដិមា

ព្រះភាគនោះ ដើម្បីជាទីរលឹកនូវព្រះដ៏មានព្រះភាគអោយកើតសេចក្តីជ្រះថ្លា និងសេចក្តីសង្វេគក៏ឥឡូវនេះយើងខ្ញុំទាំងឡាយ មកដល់ថ្ងៃពេញបូណ៌មីខែវិសាខដែលសន្មតថាជាថ្ងៃប្រសូត ថ្ងៃត្រាស់ដឹង និងថ្ងៃបរិនិព្វាននៃព្រះដ៏មានព្រះភាគនោះ ទើបព្រមគ្នាកាន់យកនូវគ្រឿងសក្ការៈទាំងឡាយ មានប្រទីបទៀនធូបនិងផ្កាឈើជាដើម ហើយធ្វើនូវកាយនៃខ្លួនអោយបីដូចជាគ្រឿងរងសក្ការៈ រលឹកនូវព្រះគុណដែលប្រាកដសល់នៅទាំងឡាយ របស់ព្រះដ៏មានព្រះភាគនោះ នឹងធ្វើ

ស្តូប
ប្រទក្សិណនូវព្រះ } នេះអស់វារៈ៣ជុំ ។ បពិត្រព្រះអង្គដ៏
បដិមា

ចម្រើនអើយពិតមែនជាព្រះអង្គបរិនិព្វានកន្លងទៅយូរអង្វែងហើយ ប្រាកដសល់នៅតែព្រះគុណទាំងឡាយ ដែលនឹងគប្បីដឹងដោយអតីតារម្មណ៍ សូមព្រះអង្គទ្រង់ទទួលយកនូវគ្រឿងសក្ការៈទាំងឡាយនេះ ដែលយើងខ្ញុំទាំងឡាយកាន់យកហើយ ដើម្បីអោយសម្រេចប្រយោជន៍ និងសេចក្តីសុខ ដល់យើងខ្ញុំទាំងឡាយអស់កាលវែងឆ្ងាយទៅហោង ។

ចប់

# ពាក្យសូត្រថ្វាយសក្ការៈក្នុងថ្ងៃមាឃបូជា

អជ្ជាយំ មាឃបុណ្ណមី សម្បត្តា មាឃនក្ខត្តេន បុណ្ណចន្ទោ យុត្តោ យត្ថ តថាគតោ អរហំ សម្មាសម្ពុទ្ធោ ចាតុរង្គិកេ សាវកសន្និបាតេ ឱវាទបាតិមោក្ខំ ឧទ្ទិសិ តទា ហិ អឌ្ឍតេឡសានិ ភិក្ខុសតានិ សព្វេសំយេវ ខីណាសវានំ សព្វេ តេ ឯហិភិក្ខុកា សព្វេបិ តេ អនាមន្តិតាវ ភគវតោ សន្តិកំ អាគតា វេឡុវនេ កលន្ទកនិវាបេ មាឃបុណ្ណមិយំ វឌ្ឍមានកច្ឆាយាយ តស្មិញ្ច សន្និបាតេ ភគវា វិសុទ្ធុបោសថំ អកាសិ ។ អយំ អម្ហាកំ ភគវតោ ឯកោយេវ សាវកសន្និបាតោ អហោសិ ចាតុរង្គិកោ ។ មយន្តានិ ឥមំ មាឃបុណ្ណមីនក្ខត្តសមយំ តក្កាលសទិសំ សម្បត្តា ចិរបរិនិព្វុតម្បិ តំ ភគវន្តំ អនុស្សរមានា ឥមស្មឹ តស្ស ភគវតោ សក្ខិភូតេ ចេតិយេ ឥមេហិ ទីបធូបបុប្ផាទិសក្ការេហិ តំ ភគវន្តំ តានិ ច អឌ្ឍតេឡសានិ ភិក្ខុសតានិ អភិបូជយាម សាធុ នោ ភន្តេ ភគវា សសាវកសង្ឃោ សុចិរបរិនិព្វុតោបិ គុណេហិ ធរមានោ ឥមេ សក្ការេ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ ហិតាយ សុខាយ ។

សេចក្តីប្រែ

រីឯថ្ងៃនេះជាតិថីថ្ងៃពេញបូណ៌មីខែមាឃ មកដល់ព្រមក្នុងថ្ងៃនេះហើយ ព្រះចន្ទពេញវង់ប្រកបហើយដោយមាឃឫក្ស ក្នុងតិថីថ្ងៃដូច្នេះព្រះតថាគតអរហំ

សម្មាសម្ពុទ្ធ បានទ្រង់សម្ដែងហើយនូវឱវាទបាតិមោក្ខ ក្នុងទីប្រជុំនៃព្រះសង្ឃសាវ័កព្រមដោយអង្គ ៤ ប្រការក្នុងកាលគ្រានោះភិក្ខុ ១.២៥០ អង្គជាព្រះខីណាស្រពទាំងអស់ ឧបសម្ប័ទហើយដោយឯហិភិក្ខុឧបសម្បទា ព្រះខីណាស្រពទាំងឡាយនោះមិនមានអ្នកឯណានិមន្តមក លោកមកកាន់សំណាក់ព្រះដ៏មានព្រះភាគ ឯវត្តវេឡុវនកលន្ទកនិវាបស្ថាន ដោយខ្លួនឯងទាំងអស់ ក្នុងវេលារសៀលថ្ងៃពេញបូណ៌មីខែមាឃ សម្ដេចព្រះដ៏មានព្រះភាគ បានទ្រង់ធ្វើហើយនូវវិសុទ្ធឧបោសថ គឺទ្រង់សម្ដែងឱវាទបាតិមោក្ខ ក្នុងទីប្រជុំព្រះសង្ឃសាវ័កនោះ ។ ការប្រជុំព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគរបស់យើងខ្ញុំទាំងឡាយ ប្រកបដោយអង្គ ៤ នេះ បានមានហើយតែម្ដងប៉ុណ្ណោះក៏ឥឡូវនេះ បណ្ដាពួកយើងរាល់គ្នាមកដល់នក្ខត្តសម័យថ្ងៃពេញបូណ៌មីខែមាឃនេះ ប្រាកដបីដូចជាថ្ងៃចតុរង្គសន្និបាតហើយ មករលឹកដល់ព្រះដ៏មានព្រះភាគ ពិតមែនជាព្រះអង្គបរិនិព្វានទៅយូរអង្វែងហើយ សូមគោរពបូជាដល់ព្រះដ៏មានព្រះភាគនោះ និងព្រះភិក្ខុសង្ឃអង្គព្រះខីណាស្រព ១.២៥០ អង្គនោះ ដោយគ្រឿងសក្ការៈទាំងឡាយមានប្រទីបទៀនធូប និង ផ្កាឈើជាដើមនេះឰដ៏ចេតិយ គឺព្រះស្តូបនិងព្រះពុទ្ធរូបនេះ ដែលជាគ្រឿងតំណាងនៃព្រះដ៏មានព្រះភាគនោះ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គព្រមទាំងព្រះសង្ឃសាវ័កសូម្បីបរិនិព្វានទៅយូរងអង្វែងហើយក្ដី ទ្រង់សល់នៅតែព្រះគុណទាំងឡាយ សូមទ្រង់អនុគ្រោះទទួលយកនូវគ្រឿងសក្ការៈរបស់យើងខ្ញុំទាំងឡាយនេះ ដើម្បីជាប្រយោជន៍ និងសេចក្ដីសុខដល់យើងខ្ញុំទាំងឡាយ អស់កាលវែងឆ្ងាយទៅហោង ។

ចប់

តតោ សក្ការំ អភិវាទនំ ការិម្ហា (សាធុ)

# ទេវតាទិបត្តិទានគាថា

(យំ[១] កិញ្ចារម្មណំ កត្វា ទជ្ជា ទានមមច្ឆរី) បុគ្គលមិនមានសេចក្តីកំណាញ់ គួរធ្វើនូវហេតុណាមួយអោយជាអារម្មណ៍ហើយ គប្បីអោយនូវទាន (បុព្វេ បេតេវ អារព្ភ អថ វា វត្ថុទេវតា) គឺប្រារព្ធនូវបុព្វបុរសទាំងឡាយដែលលះលោកនេះទៅហើយ ឬវត្ថុទេវតាទាំងឡាយ (ចត្តារោ វ មហារាជា លោកបាលា យសស្សិនោ) នូវស្តេចធំទាំងបួនដែលរក្សាលោក អ្នកមានយស (កុវេរញ្ច ធតរដ្ឋញ្ច វិរូបក្ខំ វិរុឡ្ហកំ) គឺព្រះបាទ កុវេរៈ ១ ធតរដ្ឋ ១ វិរូបក្ខ ១ វិរុឡ្ហកៈ ១ (តេចេវ បូជិតា ហោន្តិ ទាយកា ច អផលា) ជនទាំងឡាយនេះ ឈ្មោះថាជាបុគ្គល គឺទាយកនោះបានបូជាហើយ ឯទាយកមិនមែនជាមិនមានផលឡើយ ។

(ហិរិឱត្តប្បសម្បន្នា សុក្កធម្មសមាហិតា សន្តោ សប្បុរិសា លោកេ ទេវធម្មាតិ វុច្ចរេ) សប្បុរសទាំងឡាយអ្នកមានចិត្តស្ងប់រម្ងាប់ បរិបូណ៌ដោយ ហិរិ និង ឱត្តប្បៈ ជាអ្នកមានចិត្តតម្កល់នៅក្នុងធម៌សលោកពោលថា ទេវធម៌ ក្នុងលោក ។

---

១- នេះតាមឧបោសថកថា ។ បើតាមខុទ្ទកនិកាយ បេតវត្ថុថា យំកិញ្ចារម្មណំ កត្វា ។ល។ ហានសោ ឧបកប្បតិ ។ មើលអនុមោទនាវិធី

- ចម្លងចាកឧបាសកវណ្ណនា

## ៨២

# សរសើរព្រះរតនត្រៃសង្ខេប[១]

សាធុ ពុទ្ធស្ស សុពោធិតា សេចក្តីត្រាស់ដឹងនៃព្រះពុទ្ធប្រពៃហើយ

អោយសម្រេចប្រយោជន៍ ដល់សត្វទាំងឡាយ

សាធុ ធម្មស្ស សុធម្មតា សេចក្តីទ្រទ្រង់នៃព្រះធម៌ប្រពៃហើយ

អោយសម្រេចប្រយោជន៍ ដល់សត្វទាំងឡាយ

សាធុ សង្ឃស្ស សុបដិបត្តិ សេចក្តីបដិបត្តិនៃព្រះសង្ឃប្រពៃហើយ

អោយសម្រេចប្រយោជន៍ ដល់សត្វទាំងឡាយ

អហោ ពុទ្ធោ ព្រះពុទ្ធព្រះអង្គមានព្រះគុណជាអស្ចារ្យ

គួរជ្រះថ្លាមែនហើយ

អហោ ធម្មោ ព្រះធម៌មានគុណជាអស្ចារ្យ

គួរជ្រះថ្លាមែនហើយ

អហោ សង្ឃោ ព្រះសង្ឃមានគុណជាអស្ចារ្យ

គួរជ្រះថ្លាមែនហើយ ។

---

(១). ស្រង់យកបាលី ព្រមទាំងសេចក្តីប្រែពីច្បាប់ ពុទ្ធមាមកាវិធី ។

# ព្រះរាជប្រវត្តិនៃសម្ដេចព្រះសុគន្ធាធិបតី

# បញ្ញាសីលោ ចាន់

លំដាប់នេះ នឹងពណ៌នាគុណសម្បត្តិ នៃព្រះសុគន្ធាសង្ឃរាជាធិបតី ព្រះនាម បញ្ញាសីលោ ចាន់ ដែលទ្រង់បានទទួលច្បាប់រឿងនេះ មកប្រែរៀបរៀងជាខេមរភាសា ហើយផ្សាយវិន័យវង្សធម្មយុត្ត អោយថ្កើងរុងរឿងក្នុងកម្ពុជារដ្ឋតទៅ ។

សម្ដេចព្រះសុគន្ធាសង្ឃរាជាធិបតីអង្គនេះ ទ្រង់សម្ភពនៅថ្ងៃព្រហស្បតិ៍ ១ រោច ខែ កត្តិក ឆ្នាំ ច អដ្ឋស័ក ច.ស. ១១៨៨ ព.ស. ២៣៦៩ វេលាទៀបព្រឹក ជាមហាឫក្សមង្គលពិសេស ស្រុកកំណើតនៅឃុំ ព្រែកព្រះស្ដេច ខេត្តបាត់ដំបង ឯស្រុកកំនើតមាតាបិតាលោក នៅភូមិស្នោង ស្រុកស្នោង ខេត្តកំពង់ធំ ឃ្លាតទៅនៅបាត់ដំបងដោយចលាចលតេជោទែន ។

លុះព្រះជន្ម ១២ឆ្នាំ បានទ្រង់បព្វជ្ជាជាសាមណេរ នៅវត្តពោធិឃុំសង្កែ ខេត្តបាត់ដំបង បានមួយវស្សា ក៏មានសតិនឹកខ្មាសសេចក្ដីខ្លៅល្ងង់ ហើយក៏ចូលទៅក្រុងទេព សំណាក់នៅវត្តសៈកេត សង្វាតរៀនព្រះត្រៃបិដក តាំងពីព្រះជន្ម ១៣ លុះដល់ព្រះជន្ម ២១ ហើយបានបួសតាមលទ្ធិមហានិកាយ បានបួនវស្សា បានទ្រង់ព្រះបរិយត្តិ និងព្រះកម្មដ្ឋាន ក៏បានចេះចប់ចំណេះអាចារ្យ បានរៀនខាងផ្លូវស្មូតសូត្របទក៏ប្រាកដតាមបែបមហានិកាយគ្រប់យ៉ាង លុះឃើញអាចារវិបត្តិ នៃសង្ឃក្នុងវត្តសៈកេតនោះ មិនជាទីនាំមកនូវសេចក្ដីជ្រះថ្លា ក៏ស្លុតព្រះទ័យភ័យខ្លាចចតុរាបាយ ទើបប្រឹក្សានិងក្រុមម៉ឺនគូវឌិន ជាឧបដ្ឋាក គេក៏

យល់ព្រម ហើយបាននាំទៅថ្វាយសម្ដេចព្រះចមក្លាវ សម្ដេចព្រះចមក្លាវអោយទៅសិក្សាសិក្ខាវិន័យក្នុងសំណាក់ចៅឃុន ព្រះញាណរក្ខិត ចៅវត្តបរមនិវាស ក៏បានឃើញច្បាស់ថា វិន័យវង្សធម្មយុត្តិកៈនេះបរិសុទ្ធត្រឹមត្រូវតាមផ្លូវធម្មវិន័យពិតមែន ។

លុះថ្ងៃ ១ រោច ខែ អាសាធ ឆ្នាំរកា ឯកស័ក ព.ស. ២៣៩២ ក៏បានចូលបព្វជ្ជា ឧបសម្ប័ទក្នុងសំណាក់ នៃសម្ដេចព្រះចមក្លាវ សម្ដេចព្រះចមក្លាវជាព្រះឧបជ្ឈាយ៍ ចៅឃុនព្រះញាណរក្ខិតសុត និងព្រះអមរាភិរក្ខិតកើត ជាឧបសម្បទាចារ្យ បានញត្តិចតុត្ថកម្មត្រឹមត្រូវតាមអក្ខរុច្ចារណវិធីជាធម្មយុត្តិកៈ បាននាមក្នុងសាសនាថា បញ្ញាសីលោ ហើយចេញទៅគង់វត្តបរមនិវាសវិញ បានសុំនិស្ស័យក្នុងសំណាក់ចៅឃុនព្រះញាណរក្ខិត ជាអាចារ្យសិក្សាសិក្ខាវិន័យសេចក្ដីប្រតិបត្តិ ចេះចាំតាមបែបបទស្ទាត់ប្រាកដហើយ ទ្រង់ព្រះមហាវីរិយៈ ពិនិត្យផ្ទៀងផ្ទាត់ផ្លូវប្រតិបត្តិមិនអោយល្អៀង អំពីព្រះវិន័យទាំង ៥ គម្ពីរ និងព្រះសូត្រ ៥ គម្ពីរ ព្រះអភិធម្ម ៧ គម្ពីរ ញាំញីលទ្ធិខុសចេញអស់ ជាទីញ៉ាំងព្រហ្មចរិយធម៌ អោយល្អបរិសុទ្ធឡើង លុះចេញព្រះវស្សា បានចូលទៅប្រែប្រយោគ ក្នុងវត្តព្រះកែវហ្លួង ក្នុងក្រុងទេពបាន ៤ ប្រយោគ បានឡើងសមណស័ក្តិជាមហា ទ្រង់គ្រឿង មានបៀវត្សរ៍ ៤៨ បាទ ក្នុងមួយឆ្នាំ ។

លុះ ព.ស. ២៣៩៧ ឆ្នាំ ខាល ឆស័ក មានព្រះសុភអក្សរព្រះបាទសម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតី ព្រះចៅប្រទេសកម្ពុជា អោយទៅសុំវិន័យវង្សធម្មយុត្តិកៈ មកប្រដៅបរិស័ទក្នុងកម្ពុជរដ្ឋ ទើបសម្ដេចព្រះចមក្លាវ ថ្វាយគម្ពីរ ៨០ គម្ពីរ ហើយអារាធនាអោយចៅឃុន ព្រះអមរាភិរក្ខិត ជូនព្រះមហាប៉ាន និងព្រះសង្ឃ ៦ អង្គ មកតាំងវិន័យវង្សធម្មយុត្តិកៈ ក្នុងក្រុងឧត្តុង្គមានជ័យ នោះសម្ដេចព្រះសុគន្ធាសង្ឃរាជាធិបតី បានចម្លងយករតនកថា

និងបុព្វកសិក្ខាសង្ខេប បុព្វសិក្ខាវណ្ណនា អក្សរនីតិ ជារបស់នៃចៅឃុនអម-
រាភិរក្ខិត ជាអក្សរក្រសៀន រៀនទាំងអក្សរបុរាណ បានចេះស្ទាត់ទាំងគតិ
លោក គតិធម៌ ស្រេចហើយ ស្ដេចចេញពីក្រុងបាងកក មកតាមផ្លូវកំពត ព្រម
ដោយព្រះសង្ឃបរិស័ទ ៦ អង្គ មានព្រះពោធិវង្ស ចន្ទន៍ ជាដើម ឧបាសកបួន
នាក់ មានព្រះទិព្វអក្សរ មៈផ្លាប់ ជាដើម នោះព្រះបាទសម្ដេច ព្រះហរិ-
រក្សរាមាឥស្សរាធិបតី ទ្រង់ព្រះអំណរណាស់ ត្រាស់អោយទៅគង់នៅវត្ត
សាលាគូ ហើយថ្វាយចតុប្បច្ច័យ ឧបត្ថម្ភជានិច្ច គ្រានោះសម្ដេចព្រះ
សុគន្ធាសង្ឃរាជាធិបតី ព្រះអង្គទ្រង់ព្រះមហាវីរិយៈ ប្រកាសព្រហ្មចរិយៈ
វិន័យវង្សធម្មយុត្តិកៈ អោយបព្វជ្ជាឧបសម្ប័ទ ដល់កុលបុត្រដែលមានសទ្ធា
អនុគ្រោះ ត្រឹហាវាសដោយធម្មស្សវនោកាស ហើយញ៉ាំងកុលបុត្រអោយ
ទ្រទ្រង់ព្រះបរិយត្តិជាច្រើន ដាស់តឿនអោយប្រព្រឹត្តឧក្រិដ្ឋក្នុងធម្មវិន័យជានិច្ច
ទើបវិន័យវង្សធម្មយុត្តិកៈ ផ្សាយពេញក្នុងកម្ពុជរដ្ឋ អោយគុណសម្បត្តិ នៃសម្ដេច
ដរាបរៀងមក ។

ឯចៅឃុន ព្រះអមរាភិរក្ខិត បានរៀបចំឃើញថាមាំមួនហើយ លុះដល់
ព្រះសិរិសម្មតិវង្ស ជេត កាលនៅជាបរិស័ទ លើកធុតង្គមកដល់ក្រោយ គ្រប់
ជាអដ្ឋភិក្ខុហើយ ក៏ថ្វាយព្រះពរត្រឡប់ទៅក្រុងបាងកកវិញ ។

កាលព្រះសុគន្ធាសង្ឃរាជាធិបតី ទ្រង់គង់ជាគណាចារ្យនៃធម្មយុត្តិក-
វង្ស ប្រដៅសាសនាដោយឧក្រិដ្ឋនោះ ក្នុងវស្សាជាបឋមបានឡើងសមណសក្តិ
ជាព្រះអរិយវង្ស គម្រប់ពីរជាព្រះវិមលធម្មគម្រប់បីជាព្រះមហាវិមលធម្ម គម្រប់បួនបាន
អភិសេកជាស្ដេចសង្ឃ ទ្រង់ព្រះនាម សម្ដេចព្រះសុគន្ធាសង្ឃរាជាធិបតី ព្រះអង្គ
ជាព្រះឧបជ្ឈាយ៍ ដំបូងនៃវិន័យវង្សធម្មយុត្តិកនៃប្រទេសកម្ពុជា ដោយអំណាច

ដែលទ្រង់ចំណេះឈ្លាសវៃទាំងគតិលោក គតិធម៌ ចេះអក្សរភាសា សំស្ក្រឹត មគធៈ សៀម លាវ ភូមា មន លង្កា ខេមរៈបុរាណ ហើយបានរៀបរៀងប្រែរឿង អភិធានប្បទីបិកា អក្ខរាភិធានស័ព្ទ ព្រះរាជស័ព្ទ បុព្វសិក្ខា បុព្វ-សិក្ខាវណ្ណនា អាគារិយវិន័យ ជាប្រយោជន៍ដល់កុលបុត្រទាំងឡាយ បានសិក្សាជាផ្លូវបដិបត្តិមក ។

លុះព.ស. ២៤០៨ ឆ្នាំ ឆ្លូវ សប្តស័ក ព្រះបាទសម្តេចព្រះនរោត្តមបរមទេវាវតារ ព្រះចៅកម្ពុជាស្តេចមកតាំងក្រុងនៅភ្នំពេញ ក៏ទ្រង់ស្តេច មកសាងវត្តបទុមវតីរាជវរាម មានមហាសីមាទំហំទទឹង ៤ សិន (គឺ ១៦០ ម៉ែត្រ) បណ្តោយ ៥ សិន (គឺ ២០០ម៉ែត) ព្រះពោធិវង្ស គង់វត្តស្វាយពពៃ ។ ឯបំណាច់ក្នុងកិច្ចរាជការនោះ ទ្រង់បានទៅក្រុងទេព ជាមួយនឹងឧកញ៉ា ប្រសើរសូរ្យវង្ស កាលអញ្ជើញស្តេច ព្រះអង្គ យ៉ៃ ព្រះអង្គណយ បានទ្រង់ពន្យល់អក្សរភាសាខេមរៈបុរាណ អោយលោកអេម៉ូនីញេ៉រ លោកអេម៉ូនីញេ៉រ បានកត់ត្រាចុះសៀវភៅ ទៅបោះពុម្ពឯក្រុងបារីស នៅដល់សព្វថ្ងៃនេះផង ហើយទ្រង់បានសូមព្រះរាជានុញ្ញាតអោយព្រះសិរិកជេនធម្ម ចាប និងព្រះសង្ឃ ៤ អង្គ នាំសក្ការៈទៅផ្ទៀងសាសនាឯលង្កាទ្វីប កាលនោះព្រះសុភូតិមហាថេររាមញ្ញវង្ស បានអោយព្រះរតនសារត្ថេរសង្ឃលង្កា អញ្ជើញសក្ការៈតបវិញ គឺព្រះបរមសារីរិកធាតុ ១ ព្រះអង្គ ព្រះអរហន្តធាតុមួយព្រះអង្គ កូនព្រះពោធិព្រឹក្ស ១ ដើមទ្រង់បានអោយដាំទុកនៅមុខវត្តបទុមវតី នៅថ្ងៃ អង្គារ៍ ១០ រោច ខែ មាឃ ឆ្នាំ កុរ នពស័ក. ព.ស. ២៤៣០ គ.ស. ១៨៨៧ ជាចារិកព្រះពុទ្ធសាសនាតមក ឯព្រះបរមសារីរិកធាតុនោះទ្រង់កំពុងប្រារព្ធអោយសាងព្រះចេតិយធំ ១ ស្រាប់តែទ្រង់ព្រះឈួនចុកសៀតព្រះឧទរសោយព្រះទីវង្គតទៅនៅថ្ងៃសៅរ៍ ៤ រោច ខែមាឃ ឆ្នាំម្សាញ់បញ្ចស័ក ព.ស.២៤៣៦ គ.ស. ១៨៩៣ ក្នុងរវាងព្រះជន្ម ៦៨ឆ្នាំ ទ្រង់ព្រះផ្នួសបាន ៤៨ ព្រះវស្សា ។

ឯព្រះចេតិយធំនោះ បានសម្ដេចព្រះមង្គលទេពាចារ្យ អៀម ជាសិស្ស ផ្ទាល់ ដែលបានឡើងឋានន្តរស័ក្តិ ជាសម្ដេចព្រះសង្ឃនាយកទី ២ គ្រប់គ្រងវត្ត បទុមវតី បានឃោសនាធ្វើការនោះហើយស្រេច បានសម្ពោធតម្កល់ព្រះបរមសារី-រិកធាតុ ព្រះអរហន្ត និងព្រះធាតុសម្ដេចព្រះសុគន្ធាសង្ឃរាជាធិបតី នៅថ្ងៃពុធ ១រោជ ខែវិសាខ ឆ្នាំរកា ឯកស័ក ព.ស. ២៤៥២ ត្រូវនឹងថ្ងៃ ៨ ខែ ឧសភា ឆ្នាំ ១៩០៩ ជាចារិកព្រះពុទ្ធសាសនាតមកទៀត ។

ហេតុនេះ ទើបលោកសម្ដែងទុកថា ជីវិតនៃសត្វទាំងឡាយ តែង តែរលត់រលាយជាធម្មតា បើមិនបានធ្វើការអ្វីមួយជាប្រយោជន៍ទុកអោយដល់អ្នក ដទៃហើយ ជីវិតនោះក៏រកខ្លឹមសារគ្មាន លុះតែបានធ្វើកិច្ចការជា ប្រយោជន៍ប្រាកដ ដូច្នេះហើយទើបឈ្មោះថា បានធ្វើជីវិតអោយមានសារៈ ដូច្នេះ សម្ដេចព្រះសុគន្ធាសង្ឃរាជាធិបតី បញ្ញាសីលោ ទ៉ាង ព្រះអង្គទ្រង់មានព្រះ ជន្មាយុតែត្រឹម ៦៨ឆ្នាំប៉ុណ្ណោះ ក៏ឈ្មោះថារស់នៅដើម្បីប្រយោជន៍ដល់មហាជន ជាច្រើន ទាំងបព្វជិត ទាំងគ្រហស្ថ គួរជាទិដ្ឋានុគតិ នៃព្រហ្មចារីតទៅមុខនិង មានគុណូបការៈ ដល់សិស្សានុសិស្ស សាធុសប្បុរសទាំងពួងជាអនេកប្បការ ។

ចប់

................................................................................................................

រឿងវិន័យវង្សប្រវត្តិនេះ រៀបរៀងតាមព្រះរាជពង្សាវតារសៀម ព្រះរាជ-ប្រវត្តិមហាសាសនវង្ស និងដំណឹង ។

ព្រះទិព្វអក្សរ មះផ្លាប់ ជាសិស្សដើមរៀបរៀងទុកជាទីសណ្ដាប់តទៅ ។

# ព្រះឱវាទ

នៃសម្តេចព្រះសុគន្ធាសង្ឃរាជាធិបតី **បញ្ញាសីលោ ចាន់**

១- **លោកាសង្ឃ** លោកសង្ឃត្រូវរក្សាពូជពង្សខ្លួនជាអ្នកបួស ។

២- **លោកាសង្ឃ** លោកសង្ឃកុំធ្វើខ្លួនអោយដូចរុយ ដែលចូលចិត្តលាមក ។

៣- **លោកាសង្ឃ** លោកសង្ឃ កុំធ្វើខ្លួនអោយដូចជាស្ពាន ។

## សេចក្តីអធិប្បាយ

១- លោកសង្ឃ ត្រូវបដិបត្តិអោយល្អតាមធម៌វិន័យ ទើបទៅជាអ្នកបួសរក្សាពូជពង្សរបស់ខ្លួនជាបាន បើមិនបដិបត្តិ តាមធម៌វិន័យ មិនឈ្មោះថាអ្នកបួសទេ ជាអ្នកបំផ្លាញពូជអ្នកបួសចោល ។

២- លោកសង្ឃ កុំជាប់ជំពាក់នឹងលាភសក្ការៈ បើជាប់ជំពាក់ហើយ នឹងស្លាប់ខ្លួនដូចជារុយ ដែលចូលចិត្តលាមក តែកាលណាគេបន្ទោបង់ថៃមមកទៀត នឹងសង្កត់ស្លាប់មិនខាន ។

៣- ស្ពាន សម្រាប់ចម្លងពីម្ខាងទៅម្ខាង ប៉ុន្តែស្ពាននៅនឹងកន្លែងដដែលមិនទៅមុខទេ លោកសង្ឃមិនមែនតែជាកន្លែងសម្រាប់អោយឧបាសក ឧបាសិកា ឆ្លងទៅកាន់ស្ថានសួគ៌ និងនិព្វានទេ កុំនឹងនៅកន្លែងដដែល ត្រូវប្រឹងរកស្ថានសួគ៌ និងនិព្វានខ្លួនឯងផង ។

៨៩

## ពុទ្ធភាសិត

បើបង្អង់ថាចាំស្អែកសិន　　នឹងវិនាសហិនខូចទទេ
បើចាំថ្ងៃមុខសឹមរិះរេ　　ជោគលាភបានគេអសារបង់ ។

........................................................................................................

## ឧបទេសមាលា

ន ទៃវមបិសំចិន្ត្យ　　ត្យជេទុទ្យោគមាត្មនះ
អនុទ្យោគេន តៃលានិ　　តិលេភ្យោ ជាតុមហ៌តិ ។
ទុកជាគិតឃើញវាសនាស្មោះ　　មិនត្រូវបង់បោះសេចក្ដីប្រឹង
ត្រូវខំខ្នះខ្នែងពេញទំហឹង　　ព្រោះប្រឹងនិងបុណ្យជាគូគ្នា ។
គ្រាប់ល្ងបើគេមិនគិតកាញ់　　យកទៅចម្រាញ់ ឬស្លវា
នៅជាគ្រាប់សុទ្ធតាមធម្មតា　　ធ្វើដូចម្ដេចវ៉ានឹងបានប្រេង ។

........................................................................................................

## ពុទ្ធភាសិត

នត្ថិ　បញ្ញាសមា　អាភា
គ្មានពន្លឺស្មើ នឹងពន្លឺបញ្ញាទេ ។

........................................................................................................

## ពុទ្ធភាសិត

នត្ថិ　លោកេ　អនិន្ទិតោ
មិនមានអ្នកដែលគេមិននិន្ទាទេក្នុងលោកនេះ ។

# ពុទ្ធភាសិត

ភយមេថេវ	បុរិសោ	យាវ អត្ថស្ស	និប្ផទា

ជនជាតិជាប្រុសត្រូវតែប្រឹង	ព្យាយាមអោយតឹងកុំបន្ធូរ
ប្រះប្រាណដេកទៅកុំដេកយូរ	ក្រោកឡើងគិតគូររកប្រយោជន៍ ។

.........................................................................................................................

# សុភាសិត

ជាតិខ្លឹមចន្ទន៍ទោះបីស្ងិតក្រៀមក្រញ៉ង់	មិនលះបង់ក្លិនក្លែបសុគន្ធា
ដំរីសារទោះបីចូលសឹកយុទ្ធនា	មិនលះបង់លីលាល្អងក្រាយ ។
ជាតិអំពៅទោះបីនៅក្នុងយន្តឃ្នាប	មិនលះបង់សភាពរសផ្អែមសាយ
ជាតិបណ្ឌិតទោះមានទុក្ខនៅក្នុងកាយ	មិនជិនណាយលះបង់ព្រះធម៌ថ្លៃ ។

.........................................................................................................................

# ពុទ្ធភាសិត

អ្នកប្រាជ្ញប៉ិនមិនត្រូវឈានបានមួយហើយ
ធ្វើតោះតើយស្បើយឈប់ក្រៀមនឹងថ្កល់
ត្រូវតែឈានរៀនទៅមុខលុកអោយដល់
ចេះគ្មានសល់កលកិច្ចល្បិចតិចតួចឡើយ ។

# សុភាសិត

## គាថាក្នុងនិទានគណ្ឋិភេទកចោរ

**‹‹ ធម្មបទកថាភាគ ទី ៣ ទំព័រ ២០៨ ››**

យោ ពាលោ មញ្ញតិ ពាល្យំ បណ្ឌិតោ វាបិ តេន សោ

ពាលោ ច បណ្ឌិតមានី ស វេ ពាលោតិ វុច្ចតីតិ ។

**ប្រែថា:** អ្នកណាជាមនុស្សពាល ហើយដឹងនូវភាពនៃខ្លួនជាពាល អ្នកនោះនឹងហៅថាបណ្ឌិតបានខ្លះ ដោយហេតុដែលដឹងខ្លួនថាជាពាលនោះ ម្យ៉ាងទៀត អ្នកណាជាមនុស្សពាល មានសេចក្តីប្រកាន់ខ្លួនថាជាបណ្ឌិត អ្នកនោះឈ្មោះថាជាមនុស្សពាលដោយពិត ។

---

# សុភាសិត

កុំមើលងាយថាបញ្ញាតិច     រៀនទៅក្រែងភ្លេចមិនចម្រើន

សុតម័យបញ្ញាក្រវើន

យូរទៅគង់ច្រើនពេញហប្ញទ័យ     ដូចក្អមតម្កល់លើដំបូក

ភ្លៀងអុរជោក ៗ អចិន្ត្រៃយ៍

តំណក់តក់ ៗ តែរាល់ថ្ងៃ     អាស្រ័យយូរទៅគង់ពេញបាន ។

---

## សុភាសិត

ជាតិបណ្ឌិតពិតពេញប្រាជ្ញប្រត្យក្ស គ្មានគេសាក់សាកសួរការនានា
ដូចស្គរធំឥតគេដំគោះវាយវា បើគេសួរកាលណាដូចភ្លៀងធ្លាក់ ។
ជាតិពាលពិតឥតគេសួរឬសួរសង ក៏លាន់កងរំពងពោលឥតអាក់
និយាយច្រើនកើនហួសជ្រួសដំណាក់ ចុះក្នុងក្បួនហីនលក្ខណ៍ធ្លាក់សព្វកាល ។

---

## សុភាសិត

ខ្លៅប្រៀនរៀនត្រាប់ស្ដាប់តិចតួច សម្គាល់ថាខ្លួនស្រួចមិនចេះទាល់
មិនដឹងពុទ្ធពេចន៍នៅសេសសល់ ដូចកល់កង្កែបបែបកម្លៅ ។
នៅក្នុងអណ្ដូងរណ្ដៅទាល់ មិនដែលទៅស្គាល់សមុទ្រជ្រៅ
សម្គាល់អណ្ដូងដែលខ្លួននៅ ថាជ្រៅថាធំលើសនានា ។

---

## សុភាសិត

ខណោ មា វោ ឧបច្ចគា

កុំអោយកាលវេលាដើរទៅចោលអ្នកបាត់ឥតអំពើ ។

ភាសិតំ តទ្ធំ សរ សុបុត្តេណ កុលំ យថា

កូនល្អអប់វង្សត្រកូលអោយក្រអូប ដូចផ្កាមានក្លិន អប់ព្រៃទាំងពួង អោយក្រអូបឈ្ងុយ ។

៩៣

# សុភាសិត

សម្មាបណិហិតំ ចិត្តំ សេយ្យសោ នំ តតោករេ ។

ចិត្តតម្កល់ត្រូវ ប្រសើរជាងអ្វីទាំងអស់ ។

មិច្ឆាបណិហិតំ ចិត្តំ ចាបិយោ នំ តតោ ករេ ។

ចិត្តតម្កល់ខុស អាក្រក់ក្រៃលែងអាក្រក់ ។

................................................................................................................................

# លោកនីតិបករណ៍

អលសស្ស កុតោ សិប្បំ អសិប្បស្ស កុតោ ធនំ

អធនស្ស កុតោ មិត្តំ អមិត្តស្ស កុតោ សុខំ

អសុខស្ស កុតោ បុញ្ញំ អបុញ្ញស្ស កុតោ សិវំ ។

សិល្បសាស្ត្រមានពីណាដល់អ្នកខ្ជិល ទ្រព្យធនមានពីណាអ្នកឥតសិល្ប៍

មិត្រឯណាមានអ្នកមន្ទិលឥតធនធាន សុខឯណាមានដល់អ្នកប្រាសមិត្រ

បុញ្ញឫទ្ធិឯណាមានដល់អ្នកឥតក្សាន្ត សិវមោក្ខយោគកែព្រះនិព្វាន

មានពីណាដល់អ្នកគ្មានបុណ្យកសាង ។

................................................................................................................................

## លោកនីតិបករណ៍

សិប្បសមំ ធនំ នត្ថិ　　សិប្បំ ចោរា ន គណ្ហន្តិ
ឥធ លោកេ សិប្បំ មិត្តំ　　បរលោកេ សុខាវហំ

មានទ្រព្យមិនស្មើមានវិជ្ជា　　វិជ្ជាចោរលួចយកមិនបាន
វិជ្ជាទុកជាមិត្តសន្តាន　　ក្សាន្តក្នុងឥធលោកយោគបរលោក ។

---

## លោកនីតិបករណ៍

បណ្ឌិតោ សុតសម្បន្នោ　　យត្ថ អត្ថីតិ ចេ សុតោ
មហុស្សាហេន តំ ឋានំ　　គន្តព្វោវ សុតេសិនា ។

បើឮថាមានអ្នកប្រាជ្ញច្បាស់　　កបសូត្រសិល្បសាស្រ្តក្នុងទីណា
អ្នកស្វែងរៀនសូត្រខំឧស្សាហ៍　　យាត្រាចូលទៅទីនោះហោង ។

---

## លោកនីតិបករណ៍

ខុទ្ទោតិ ជាតិមញ្ញេយ្យ　　វិជ្ជំ វា សិប្បមថវា
ឯកំបិ បរិយោជាតំ　　ជីវិតកប្បការណំ ។

កុំមើលងាយមន្តសិល្បសាស្ត្រ　　គិតថាតិចតួចក្រែងមិនស្រេច
វិជ្ជាមួយមែនបើមិនភ្លេច　　គង់នឹងសម្រេចប្រយោជន៍បាន ។

៩៥

## ពុទ្ធាភាសិត

អត្តា ហិ អត្តនោ នាថោ កោ ហិ នាថោ បរោ សិយា

អត្តនា ហិ សុទន្តេន នាថំ លភតិ ទុល្លភំ ។

ខ្លួនទីពឹងខ្លួន អ្នកដទៃនឹងបានជាទីពឹងដូចម្តេចទៅហ្ន៎

ព្រោះថាគេមានខ្លួនទូន្មានល្អ បានទីពឹងក្រដែលគេក្របាន ។

---

## ពុទ្ធភាសិត

យោ ច វស្សសតំ ជីវេ ទុស្សីលោ អសមាហិតោ

ឯកាហំ ជីវិតំ សេយ្យោ សីលវន្តស្ស ឈាយិនោ

បុគ្គលទ្រុស្តសីល មិនតាំងចិត្តខ្ជាប់ គប្បីរស់រាប់អស់រយឆ្នាំក្រៃ

ពុំប្រសើរស្មើការរស់មួយថ្ងៃ នៃអ្នកសីលថ្លៃជាអ្នកមានឈាន ។

---

## ពុទ្ធភាសិត

យោ ច វស្សសតំ ជីវេ កុសីតោ ហីនវីរិយោ

ឯកាហំ ជីវិតំ សេយ្យោ វីរិយំ អារភតោ ទឡ្ហំ ។

អ្នកខ្ជិលមានព្យាយាមហីនមិនគាប់ គប្បីរស់រាប់អស់រយឆ្នាំក្រៃ

ពុំប្រសើរស្មើការរស់មួយថ្ងៃ នៃអ្នកតេជដៃផ្តើមព្យាយាមមាំ ។

# សុភាសិត

| | |
|---|---|
| សូវស្តាយបាន | ប្រសើរជាងស្តាយបង់ |
| សូវស្លាប់អង្គ | ប្រសើរជាងខូចឈ្មោះ ។ |
| សូវមើលសៀវភៅ | ប្រសើរជាងមើលរបាំ |
| សូវស្តាប់ធម៌ចាំ | ប្រសើរជាងស្តាប់ចម្រៀង ។ |
| សូវនិយាយពីធម៌ | ប្រសើរជាងនិយាយដៀង |
| សូវគិតធម៌មិនទៀង | ប្រសើរជាងគិតព្យាបាទ ។ |

.................................................................................................................

# សុភាសិត

| | |
|---|---|
| បើមើលឃើញចំណេញ | កុំភ្លេចរឿងខាត |
| បើមើលឃើញស្អាត | សូមកុំភ្លេចរឿងស្អប់ ។ |
| បើឃើញកំហុស | កុំភ្លេចគុណគាប់ |
| ធម្មតាថ្ងៃ និងយប់ | ជាគូនឹងគ្នា ។ |

.................................................................................................................

៩៧

# បុរាណសុភាសិត

និន្ទាសរសើរជាធម្មតា ចំពោះកិច្ចការអ្នកខិតខំ
កំហុសតែងស្ថិតនៅនិត្យ នេះជាធម៌ពិតនៃអ្នកធ្វើ ។

................................................................................................................................

បើទុកជាគិតឃើញវាសនាស្មោះ មិនត្រូវបង់បោះសេចក្ដីប្រឹង
ត្រូវខំខ្នះខ្នែងអោយពេញទំហឹង ព្រោះប្រឹងនិងបុណ្យជាគូគ្នា ។

................................................................................................................................

ក្រកិច្ច ក្រកល់! ក្រដឹង ក្រយល់ ក្រលៃច្នៃទាស់
ក្របានជាធំលើសគេទាំងអស់ ក្រចិត្តសប្បុរស នឹងមនុស្សផងគ្នា ។

................................................................................................................................

ត្រូវនឹកប្រមូលការគ្រប់មុខ មកពិនិត្យទុកមុន នឹងធ្វើ
ការណាយល់ថាគាប់ប្រសើរ ត្រូវប្រើព្យាយាម និងមានះ។

................................................................................................................................

ទ្រព្យស្មើដោយវិជ្ជានោះពុំមាន សត្រូវប្រាណមិនស្មើដោយព្យាធិ
ស្រឡាញ់ក្រៅមិនស្មើដោយកាយិន្ទ្រីយ៍ កម្លាំងអ្វីមិនស្មើកម្មបុរាណ ។

................................................................................................................................

ឈ្លោះគ្នាក្នុងគ្រួសារ ដូចស្រាតកាយាបង្ហាញញាតិ
ឈ្លោះគ្នាក្នុងសង្គមជាតិ ដូចលាតកំណប់បង្ហាញចោរ ។

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងសម្តេចព្រះសង្ឃរាជ ជាតិ សាសនា ព្រះមហាក្សត្រ

គណធម្មយុត្ត នៃកម្ពុជា

# សិទ្ធិការ

## គណៈធម្មយុត្តិកនិកាយ

### សម្តេចព្រះសុគន្ធាធិបតី ប៊ូរ គ្រី

### សម្តេចព្រះសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជា

យោងតាមបន្ទូល ក្នុងឱកាសមហាសន្និបាតមន្ត្រីសង្ឃលើកទី ៣ នាថ្ងៃទី ៦ ខែឧសភា ឆ្នាំ ១៩៩៤ ថ្លែងប្រគេនព្រះសង្ឃគ្រប់វត្ត នៃគណៈធម្មយុត្តទូទាំងប្រទេសកម្ពុជា ។ សូមអោយមានការឯកភាព ចំពោះគណៈសង្ឃទាំង-ឡាយគ្រប់ពេល និងរាល់ពិធីការនៃព្រះពុទ្ធសាសនា ដូចជា ៖

១- ពេលស្វាធ្យាយធម៌ អោយសីលដល់ក្រុមពុទ្ធបរិស័ទ ត្រូវលើកដៃប្រណម្យ (ត្រឹមឱរ៉ា) ដើម្បីអោយមានភាពសមរម្យ និងបញ្ជាក់អោយឃើញនូវការគោរពព្រះធម៌ នៃព្រះសម្មាសម្ពុទ្ធ ។

២- ភិក្ខុសង្ឃគ្រប់អង្គ ត្រូវប្រើចីវរពណ៌ស្រគាំ (អាចម៍សេះ) ព្រមទាំងមានអោយពាក់សង្ឃាដីជាប់ជាមួយផង រាល់ពិធីកម្ម និងកិច្ចការព្រះពុទ្ធ-សាសនា ។

៣- សាមណេរត្រូវប្រើចីវរពណ៌លឿង « កុំប្រើពណ៌ចីវរដូចភិក្ខុ »

៤- ទាំងភិក្ខុសាមណេរ ត្រូវមានសុទ្ធិប័ត្រ « ប័ណ្ណសម្គាល់ខ្លួន » ដោយមានប្រថាប់ត្រា និង ព្រះហស្តលេខាអំពីសម្តេចព្រះសង្ឃរាជ

គណៈធម្មយុត្ត ។

៥- រាល់កិច្ចការព្រះពុទ្ធសាសនាទាំងឡាយណា ដែលទាក់ទិន នឹងគណៈសង្ឃក្តី ច្បាប់រដ្ឋក្តី ពុំទាន់មានព្រះរាជានុញ្ញាតក្តី សូមព្រះចៅអធិការអាចារ្យ មកទំនាក់ទំនង នឹងក្រសួងសម្តេចផ្ទាល់ ។

៦- កិច្ចថ្វាយបង្គំត្រូវលុតជង្គង់ លើកដៃប្រណម្យត្រឹមឱ៊រអោយត្រង់ខ្លួន រួចឱនសិរសាដល់ប្រអប់ដៃទាំងពីរ គួយដៃទល់ក្បាលជង្គង់ ទើបជាការគួរ (ក្រាប ៣ ដង) ។

៧- កិច្ចនមស្ការ ព្រមទាំងពិធីការផ្សេង ៗ ដើម្បីអោយមានការឯកភាព និងងាយស្រួលដល់ពុទ្ធសាសនូបត្ថម្ភក្នុងការរៀនសូត្រ សូមមេត្តាយកតាមសៀវភៅថ្វាយបង្គំព្រះ សង្ឃបណ្ណាល័យវត្តបទុមវតីរាជវរារាមទាំងអស់ ហើយជាការចាំបាច់ គួរសិក្សាសេចក្តីប្រែផង ។

៨- ភិក្ខុ សាមណេរ គ្រប់វត្ត ដែលត្រូវផ្លាស់ប្តូរទីលំនៅ សូមមានសុទ្ធិប័ត្រ និងលិខិតបញ្ជាក់ពីចៅអាវាសរៀង ៗ ខ្លួន ។ ជៀសវាងភាពរហេតរហូតពុំមានសណ្តាប់ធ្នាប់ ដែលជាហេតុបង្កលក្ខណៈ អោយខូចគណៈសង្ឃ និងប្រាសចាកព្រះធម៌វិន័យ ព្រះសម្មាសម្ពុទ្ធ ។

៩- ភិក្ខុ សាមណេរ ឧបាសក ឧបាសិកា ហាមឆាន់ពិសាបារី ក្នុងពេលប្រារព្ធពិធីបុណ្យទានផ្សេង ៗ ដូចជាពេលចម្រើនព្រះបរិត្តសមាទានសីល ស្តាប់ធម្មទេសនា ឬក្នុងពិធីការ និងពេលត្រាច់ចរតាមលង្វែកភូមិ ។ ល ។

ព្រះរាជក្រឹត្យ ដូចបានប្រគេន និងជម្រាបខាងលើ សូមព្រះចៅអធិការអាចារ្យ មេត្តាទទួលចាត់ការអោយបានល្អប្រសើរ និងជាការបញ្ជាក់អោយឃើញ

នូវសមានច្ឆន្ទៈ គឺការឯកភាព សាមគ្គីភាព គណៈសង្ឃព្រះពុទ្ធសាសនាតរៀងទៅ ។

សូមប្រគេននូវព្រះពុទ្ធពរទាំង ៥ ប្រការ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩១

ចាត់ការ

ពុត សុភ័ក្ត្រ

---

# គាថាអាឡវកយក្ខ

១- **កឹសុធវិត្តំ បុរិសស្ស សេដ្ឋំ** អ្វីជាទ្រព្យប្រសើរក្រៃលែងជាងទ្រព្យទាំងពួងក្នុងលោកនេះ

សទ្ធីធវិត្តំ បុរិសស្ស សេដ្ឋំ សទ្ធាជាទ្រព្យប្រសើរក្រៃលែង ជាងទ្រព្យទាំងពួងក្នុងលោកនេះ ។

២- **កឹសុ សុចិណ្ណោ សុខមាវហាតិ** សន្សំអ្វីនាំមកនូវសេចក្ដីសុខក្នុងលោកនេះ

ធម្មោ សុចិណ្ណោ សុខមាវហាតិ សន្សំធម៌នាំមកនូវសេចក្ដីសុខក្នុងលោកនេះ ។

៣- **កឹសុហវេ សាធុតរំ រសានំ** អ្វីជារសពិសាក្រៃលែង ជាងរសទាំងពួងក្នុងលោកនេះ

សច្ចំហវេ សាធុតរំ រសានំ  សច្ចៈជារសពិសាក្រៃលែង ជាងរស
ទាំងពួងក្នុងលោកនេះ ។

៤- កឹំសុជីវី ជីវិតមាហុ សេដ្ឋំ អ្វីជាជីវិតប្រសើរក្រៃលែងជាង
ជីវិតទាំងពួងក្នុងលោកនេះ
បញ្ញាជីវី ជីវិតមាហុ សេដ្ឋំ បញ្ញាជាជីវិតប្រសើរក្រៃលែងជាង
ជីវិតទាំងពួងក្នុងលោកនេះ ។

៥- កថំសុ តរតិ ឱឃំ នឹងឆ្លងអន្លង់ឱឃៈបានដោយ
ហេតុអ្វី
សទ្ធាយ តរតិ ឱឃំ នឹងឆ្លងអន្លង់ឱឃៈបានដោយ
សទ្ធា ។

៦- កថំសុ តរតិ អណ្ណវំ នឹងឆ្លងអន្លង់ គឺវដ្តសង្សារបាន
ដោយហេតុអ្វី
អប្បមាទេន តរតិ អណ្ណវំ នឹងឆ្លងអន្លង់ គឺវដ្តសង្សារបាន
ដោយអប្បមាទ ។

៧- កថំសុ ទុក្ខំ អច្ចេតិ នឹងឆ្លងទុក្ខបានដោយហេតុអ្វី
វីរិយេន ទុក្ខំ អច្ចេតិ នឹងឆ្លងទុក្ខបានដោយព្យាយាម ។

៨- កថំសុ បរិសុជ្ឈតិ នឹងបរិសុទ្ធបានដោយហេតុអ្វី
បញ្ញាយ បរិសុជ្ឈតិ នឹងបរិសុទ្ធបានដោយបញ្ញា ។

៩- កឹំសុ យាវ ជរា សាធុ អ្វីគួររក្សាដរាបដល់ជរា
ញុំាងប្រយោជន៍អោយសម្រេច ។
សីលំ យាវ ជរា សាធុ សីលគួររក្សាដរាបដល់ជរា
ញុំាងប្រយោជន៍អោយសម្រេច ។

១០- កឹសុ សាធុ បតិដ្ឋិតំ អ្វីគួរតម្កល់ទុកក្នុងចិត្ត ញ៉ាំងប្រយោជន៍អោយសម្រេច

សទ្ធា សាធុ បតិដ្ឋិតំ សទ្ធាគួរតម្កល់ទុកក្នុងចិត្ត ញ៉ាំងប្រយោជន៍អោយសម្រេច ។

១១- កឹសុ នរានំ រតនំ អ្វីជាកែវដ៏ប្រសើរនៃនរជនទាំងឡាយ

បញ្ញា នរានំ រតនំ បញ្ញាជាកែវដ៏ប្រសើរ នៃនរជន ទាំងឡាយ ។

១២- កឹសុ ចោរេហិ ទូហរន្តិ អ្វីគឺចោរទាំងឡាយ នាំទៅបានដោយក្រ

បុញ្ញំ ចោរេហិ ទូហរន្តិ បុណ្យ គឺចោរទាំងឡាយ នាំទៅបានដោយក្រ ។

១៣- កថំសុ លភតេ បញ្ញំ នឹងបាននូវបញ្ញា បានដោយហេតុអ្វី

សុស្សូសំ លភតេ បញ្ញំ អប្បមត្តោ វិចក្ខណោ ឧស្សាហ៍ស្តាប់ៗ ហើយមិនធ្វេសប្រហែស យកទៅពិចារណា នឹងបាននូវបញ្ញា ។

១៤- កថំសុ វិន្ទតេ ធនំ នឹងបាននូវទ្រព្យ បានដោយហេតុអ្វី

បដិរូបការិធុរវា ឧដ្ឋាតា វិន្ទតេ ធនំ មានពីព្យាយាម មិនលះធុរៈបង់ រមែងបាននូវលោកិយទ្រព្យ និងលោកុត្តរទ្រព្យ ។

១៥- ការំ មិត្តានិកន្ដតិ នឹងចងអ្នកដទៃមកជាមិត្តបាន ព្រោះហេតុអ្វី

ទទំ មិត្តានិកន្ដតិ នឹងចងអ្នកដទៃមកជាមិត្តបាន ព្រោះអោយ គួរអោយធម៌ក៏អោយធម៌ គួរអោយវត្ថុ ក៏អោយវត្ថុ ទើបនឹងចងអ្នកដទៃមកជាមិត្តបាន ។

១៦- កថំសុ កិត្តឹ បប្បោតិ នឹងបាននូវកិត្តិស័ព្ទ បានដោយហេតុអ្វី

សច្ចេន កិត្តឹ បប្បោតិ នឹងបាននូវកិត្តិស័ព្ទ បានដោយពាក្យសត្យ ។

១៧- អស្មា លោកា បរំ លោកំ កថំ បេច្ច ន សោចតិ បុគ្គលទៅចាកលោកនេះ នឹងទៅកាន់លោកខាងមុខ នឹងមិនសោយសោក ព្រោះអាស្រ័យធម៌ប៉ុន្មានប្រការ

យស្សេតេ ចតុរោ ធម្មា សទ្ធស្ស ឃរមេសិនោ សច្ចំ ធម្មោ បរិច្ចាគោ សវេ បេច្ច ន សោចតិ បុគ្គលទៅចាកលោកនេះ នឹងទៅកាន់លោកខាងមុខ នឹងមិនសោយសោក ព្រោះអាស្រ័យធម៌ ៤ ប្រការគឺ សច្ចៈ ១ សុចរិតធម៌ ១ បញ្ញា ១ បរិច្ចាគ ១ ទើបនឹងមិនសោយសោក ។

« គាថាអាឡវកយក្ខំ និដ្ឋិតំ »

ចប់

# បេមតោ

បេមតោ ជាយតេ សោកោ បេមតោ ជាយតេ ភយំ
បេមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ
សេចក្តីទុក្ខសោកមកពីស្រឡាញ់ សេចក្តីខឹងខ្នាញ់មកពីស្នេហា
នឹងផុតទុក្ខសោករោគភ័យនេះណា ត្រូវលះស្នេហាចោលចេញអោយផុត ។
រតិយា ជាយតេ សោកោ រតិយា ជាយតេ ភយំ
រតិយា វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ
សេចក្តីទុក្ខសោកមកពីតម្រេក អស់ភ័យបាត់ត្រេកព្រោះគ្មានស្នេហា
នឹងផុតទុក្ខសោករោគភ័យនេះណា ត្រូវលះស្នេហាគ្រឿងត្រាំចោលចេញ ។
កាមតោ ជាយតេ សោកោ កាមតោ ជាយតេ ភយំ
កាមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ
សេចក្តីទុក្ខសោកមកពីតួកាម ភ័យស្អប់ជាប់តាមមកពីស្នេហា
នឹងផុតទុក្ខសោករោគភ័យនេះណា ត្រូវលះកាមាសារចោលចេញ ។
តណ្ហាយ ជាយតេ សោកោ តណ្ហាយ ជាយតេ ភយំ
តណ្ហាយ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ
សេចក្តីទុក្ខសោកមកពីតណ្ហា ភ័យស្អប់ឬស្យាមកពីចិត្តចង់
នឹងផុតទុក្ខសោករោគភ័យឃ្លាតបង់ ត្រូវលះចំណង់តណ្ហាចោលចេញ ។

ចប់

# គណៈកម្មការបោះពុម្ពផ្សាយ
# សៀវភៅធម៌

សូមអភ័យទោសអំពីសំណាក់ព្រះករុណាគ្រប់ព្រះអង្គ ក្រុមពុទ្ធបរិស័ទ ដែលពោរពេញទៅដោយសមានច្ឆន្ទៈ ជឿជាក់ក្នុងគុណបុណ្យព្រះរតនត្រ័យ ទាំងឡាយ ដែលបានជួយឧបត្ថម្ភបោះពុម្ពផ្សាយសៀវភៅធម៌ មានក្រុមពុទ្ធបរិស័ទវត្តឧទុម្ពរ វត្តបទុមវតីរាជវរារាម វត្តស្វាយពពែ វត្តទិព្វ-សម្បត្តិ វត្តព្រះស៊ីសុវត្ថិរតនារាម ព្រមទាំងវត្តនានាជាច្រើនទៀត ជាពិសេសក្រុមពុទ្ធបរិស័ទនៅរាជធានីភ្នំពេញទាំងអស់ ។

ព្រះនាម នាម ដែលបានកំណត់ថា ចុះក្នុងសៀវភៅ

តទៀវនេះពុំបាន ចុះក្នុងសៀវភៅវិញទេ ។

ពីព្រោះឈ្មោះត្រូវមានចំនួនជិតប្រហែល នឹង ទំព័រនៃអត្ថបទធម៌ ទៅហើយ (ច្រើនពេក) ។

គណៈកម្មការ ជឿជាក់ថា ព្រះករុណា អស់លោកអ្នកប្រាកដជា មានមេត្តាសន្ដោសប្រោសប្រណី ព្រមទាំងជួយសម្រួល ដល់កំហុសខុសឆ្គងដែលបានកំណត់កន្លងមក ។

ដោយអំណាចនៃការយោគយល់នេះ សូមបានសម្រេចនូវប្រយោជន៍ ជាន់ខ្ពស់គ្រប់ ៗ ព្រះអង្គ និងគ្រប់ ៗ គ្នា ។

បាត់ដំបង, ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៩៥

ពុត សុភ័ក្រ្ត

**សូមអរព្រះគុណ សូមអរគុណ**

# រៀបចំវាយអក្សរឡើងវិញនិងពិនិត្យតាមច្បាប់ដើមដោយ

# គណៈកម្មការពុទ្ធិកវប្បធម៌អង្គការមូលនិធិវត្តបញ្ញាធំ

ការវាយអក្សរ  និងបោះពុម្ពសាឡើងវិញនូវសៀវភៅធម៌ដែលជាស្នាដៃចាស់ៗ របស់អ្នកនិពន្ធជំនាន់មុនគឺអាស្រ័យ ដោយការមើលឃើញ នូវកត្តាចាំបាច់មួយចំនួន ដូចខាងក្រោម ៖

- ឯកសារដើម ត្រូវបានថតចម្លងច្រើនសា ធ្វើឲ្យមានលក្ខណៈមិនច្បាស់ ពិបាកក្នុងការអាន
- រក្សាស្នាដៃវប្បធម៌ព្រះពុទ្ធសាសនាឲ្យគង់វង្សស្ថិតស្ថេរ
- តម្រូវការរបស់សិក្ខាកាមអ្នកប្រាថ្នាចង់យល់ដឹងនូវខ្លឹមសារពុទ្ធសាសនា
- ផ្សាយនូវធម្មទាន ធ្វើឲ្យព្រះពុទ្ធសាសនាកាន់តែមានភាពរីកចម្រើនរុងរឿងក្នុងលោក


ក្នុងករណីដែលលោកអ្នកអានបានពើបប្រទះនូវកំហុសឆ្គងណាមួយ<br>
ចង់ឲ្យយើងកែតម្រូវ ឬចង់បានសៀវភៅធម៌យកទៅអាន<br>
សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋានដូចខាងក្រោមៈ<br>
វត្តបញ្ញា សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ<br>
លេខទូរស័ព្ទ: (៨៥៥) ១២ ៩៦១ ៩២៩, (៨៥៥) ៨៨៧ ៩៦១ ៩២៩<br>
អ៊ីមែល: maha.panna@gmail.com<br>
គេហទំព័រ: http://www.mahapanna.org

# DEDICATION OF MERIT

May the merit and virtue
accrued from this work
adorn Amitabha Buddha's Pure Land,
repay the four great kindnesses above,
and relieve the suffering of
those on the three paths below.

May those who see or hear of these efforts
generate Bodhi-mind,
spend their lives devoted to the Buddha Dharma,
and finally be reborn together in
the Land of Ultimate Bliss.
Homage to Amita Buddha!

**NAMO AMITABHA**

**南無阿彌陀佛**

《東埔寨文：How to salute Three Gems，禮敬三寶》

財團法人佛陀教育基金會 印贈
台北市杭州南路一段五十五號十一樓
Printed and donated for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
Mobile Web: m.budaedu.org
**This book is strictly for free distribution, it is not to be sold.**
សម្រាប់ចែកជាធម្មទាន
Printed in Taiwan
10,000 copies; March 2015
CA047 - 13028